ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 07-Jun-2017, 10:30
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្ដីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៥**

**ម៉ោង ០៩:០៩នាទី**

**សវនាការលើកទី៣៤៤**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាធូវ ម៉ាកាធី *(Mr.Matthew Mccarthy)*

កញ្ញា ជា ស៊ីវហ័ង

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

លោក សេង ប៊ុនឃាង

លោក ចូសេហ្វ អេនឌ្រូ ប៊យលី
*(Mr. Joseph Andrew BOYLE)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

លោក លីវ សុវណ្ណា

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក វ៉េន ពៅ

លោកស្រី ទី ស្រ៊ីនណា

កញ្ញា លីម៉ា ង្វៀន *(Ms.Lyma NGUYEN)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោក សេង លាង | ខ្មែរ |
| លោក ចូសេហ្វ អេនឌ្រូ បិយលី | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| កញ្ញា លីម៉ា ង្វៀន | អង់គ្លេស |
| លោកស្រី សៅ សាក់ (2-TCW-886) | ខ្មែរ |
| លោក ជឿង យ៉ាំង ចែត (2-TCCP-241) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោកស្រី សៅ សាក់** (2-TCW-886)

សួរបន្តដោយលោក នីកូឡាស គូមជែន ផ្តើមពី ........................................ទំព័រ ៣
សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្តើមពី ........................................ទំព័រ ៨
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី........................................ទំព័រ ១៤
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី........................................ទំព័រ ២១
សួរដោយលោក គង់ សំអុន ផ្តើមពី ........................................ទំព័រ ២៣

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ឡឿង យ៉ាំង ច្រើត ឬ ឡឿង យ៉ាំង ចែត**

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........................................ទំព័រ ២៥
សួរដោយកញ្ញា លីម៉ា ង្វៀន ផ្តើមពី ........................................ទំព័រ ២៧
សួរដោយចៅក្រម ក្លូឌា ហ្វេនស៍ ផ្តើមពី........................................ទំព័រ ៤៣
សួរដោយកញ្ញា លីម៉ា ង្វៀន ផ្តើមពី ........................................ទំព័រ ៤៥
សួរដោយលោក ចូសេហ្វ អេនឌ្រូ បីយលី ផ្តើមពី ........................................ទំព័រ ៥៨
សួរដោយចៅក្រម ក្លូឌា ហ្វេនស៍ ផ្តើមពី........................................ទំព័រ ៦៨
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី........................................ទំព័រ ៦៩

# **កិច្ចដំណើរការនីតិវិធី**

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៩:២៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការបន្តស្តាប់សក្ខីកម្ម សៅ សាក់ ហើយនិងផ្តើមស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-241។

ក្រឡាបញ្ជីសវនាការ កញ្ញា ជា ស៊ីវហ៊ង ឡើងរាយការណ៍ពីស្ថានភាពវត្តមាន អវត្តមានភាគីនិងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលនឹងត្រូវមកផ្តល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះគឺលោកស្រី សៅ សាក់។ លោកស្រីមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ នៅថ្ងៃនេះដែរ មានដើមបណ្តឹងរដ្ឋប្បវេណីបម្រុងមួយរូបដែលមានរហស្សនាម 2-TCCP-241។ សូមអរគុណលោកប្រធាន។

[០៩:១០:៥៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយមុននឹងផ្តល់វេទិកាជូនទៅភាគីសួរដេញដោលសាក្សីរូបនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៥ ដែលបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមាន

ប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៥។

មេធាវីការពារក្តីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថាជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៥ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅព្រឹកនេះថា មានអាការៈ ឈឺចង្កេះ និងខ្នង មិនអាចអង្គុយយូរបាន និងបានផ្តល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុងអ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅភាគីសហព្រះរាជអាជ្ញា ហើយសូមបញ្ជាក់ថាសហព្រះរាជអាជ្ញារួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលមួយវគ្គនៃសវនាការព្រឹកនេះក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

[០៩:១៣:០៧]

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរ លោក លោកស្រីចៅក្រម មេធាវី និងភាគីទាំងអស់។

**បន្តការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកស្រីសាក្សី ខ្ញុំនឹងបន្តសួរសំណួរលោកស្រីតទៅទៀតអំពីមនុស្សមួយចំនួន<ផ្សេងទៀតដែលមកពី>ភូមិរបស់លោកស្រី <និងពីកន្លែងផ្សេងទៀត>ដែលលោកស្រីអាចស្គាល់ ឬមិនស្គាល់ ថាតើលោកស្រីមានព័ត៌មាន <ឬ>បានឃើញ ឬក៏<បានឮព័ត៌មានអំពី>ជោគវាសនារបស់ពួកគេដែរ ឬអត់? ហើយបើសិនជាលោកស្រីដឹង អញ្ជើញថាដឹង។ កាលពី<ល្ងាច>ថ្ងៃព្រហស្បតិ៍ យើងសួរអំពីឈ្មោះ <ឃុន មុ៉ន> ហើយនិងប្រពន្ធរបស់គាត់។ ហើយលោកស្រីថាស្គាល់ពួកគាត់ ប៉ុនមិនដឹងជោគវាសនារបស់គេទេ។ តើ<លោកស្រីបានដឹងទេអំពី>ម្ដាយរបស់ប្រពន្ធ <ឃុន មុ៉ន>ឈ្មោះ លី ធីហាយ ហ្នឹង <>ហើយនិង<>បងប្អូនបង្កើតរបស់គាត់ តើលោកស្រីបានដឹងពីជោគវាសនារបស់អ្នកទាំងនោះទេ?

**លោកស្រី សៅ សាក់៖**

**ឆ៖** សូមទោស សួរ មុំ ណា? អត់ស្គាល់។ មុ៉ន ប្ដីឈ្មោះ មុ៉ន – មុ៉ន, ហួ ហ្នឹងឬក៏យ៉ាងម៉េច? អត់ច្បាស់សំណួរ។

**ស៖** <អគុណ។>ហើយខ្ញុំយោងឈ្មោះ ឃុន មុ៉ន ដែលមានប្រពន្ធ ដែលឪពុកប្រពន្ធរបស់គាត់ <កាត់ចិន>ឈ្មោះ សេង ហើយម្ដាយជនជាតិវៀតណាម លី ធីហាយ។ <> ឈ្មោះ សេង ហួ <ជា> ប្រពន្ធរបស់គាត់។ តើលោកស្រីនៅចាំឈ្មោះនេះដែរឬទេ?

**ឆ៖** បាន ខ្ញុំចាំ។ សេង ហួ ហ្នឹងនៅក្បែរផ្ទះខ្ញុំមែន ប៉ុន្តែគាត់រៀបការប្ដីគាត់ឈ្មោះ មុ៉ន ហ្នឹង បានទៅនៅឃុំស្វាយអន្ទរ ដែលខ្ញុំមិនបានដឹងសភាពការណ៍គាត់យ៉ាងម៉េច ឬគ្រួសារគាត់ទុក្ខធូរ៉យ៉ាងម៉េច ក៏ខ្ញុំមិនបានដឹងដែរ។ ព្រោះដាច់ឆ្ងាយពីគ្នា តាំងពីហ្នឹងរហូតមក។

[០៩:១៥:១៦]

**ស៖** តើលោកស្រីធ្លាប់បានឃើញប្រពន្ធ ឬក៏ម្ដាយរបស់ សេង ហួ ដែលជាម្ដាយក្មេករបស់ <ឃុន> មុ៉ន <ឬបងប្អូនបង្កើតខាងប្រពន្ធគាត់តាំងពីរបបកម្ពុជាប្រជាធិប្បតេយ្យដែរទេ>?

**ឆ៖** ចាស ក្រោយមកក៏បែកគ្នារហូត មិនដែលជួបគ្នាទេ តាំងពីគាត់ការគាត់មក គាត់ចេញផុតពីភូមិនុ៎ង ពីភូមិខ្ញុំរហូតមក ខ្ញុំមិនបានដឹង។

**ស៖** ខ្ញុំសួរថាតើក្រោយមកទៀត តើលោកស្រីបានឃើញពួកគាត់មកកន្លែងភូមិហ្នឹងវិញដែរឬទេ <ចាប់ពីឆ្នាំ១៩៧៩នោះមក>?

**ឆ៖** ចាស គាត់មិនដែលមកទេ បែកគ្នារហូតមកដល់សព្វថ្ងៃហ្នឹង ក៏គាត់មិនដែលមកដែរ បាត់រហូតហ្នុង។

**ស៖** ឃួន ម៉ុន បាននិយាយពីរឿងនេះនៅក្នុង<ឯកសារ> E3/2589 ដែលគាត់ផ្ដល់បទសម្ភាសន៍ឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា។ គាត់និយាយថា នៅទំព័រខ្មែរ 00224670, បារាំង 00623348, ភាសាអង់គ្លេស ERN 00224673។ <>ក្រោយមកដែលគាត់យល់<>អំពីមូលហេតុដែលគេចាប់ប្រពន្ធរបស់គាត់<។ “បើមាននរណាម្នាក់>ជាប់សាច់ឈាមជាជនជាតិវៀតណាម ហើយអ្នកនោះត្រូវគេយកទៅសម្លាប់។ គាត់និយាយពី សេង វ៉ាន់ ជា<>បងថ្លៃប្រុស ហើយសមាជិកទាំងអស់ ត្រូវបានគេសម្លាប់ <សល់>តែកូនប្រុសម្នាក់ឈ្មោះ ម៉ៅ <ដែលរួចជីវិត ដោយសារពួននៅក្នុងចម្ការពោត>។ <>បងប្អូន ឃុន ម៉ុន ហើយនិងអ្នកជិតខាងបញ្ជាក់ថា <ពួកគាត់មិនបានធ្វើអ្វីខុសសោះ តែគេសម្លាប់ប្រពន្ធវៀតណាម និងកូនៗរបស់គាត់ចោលអស់។> លី ធីហាយ ជាម្ដាយក្មេករបស់គាត់ ហើយ<បងថ្លៃ>ស្រី សេង ទៀង ហើយបង<ថ្លៃ>ប្រុស សេង កែ ក៏ត្រូវបានគេសម្លាប់<ផង>ដែរ”។ តើលោកស្រីធ្លាប់បានដឹងព័ត៌មាន ឬក៏ដំណឹងបែបនេះទេ ឬក៏លោកស្រីនឹកឃើញពីអ្វីចង់បន្ថែមនូវអ្វីដែលខ្ញុំបានអានជម្រាបនេះទេ?

[០៩:១៨:០៩]

**ឆ៖** គ្រួសារ អ៊ីហាយ – ហេង ហាយ ហ្នឹង ខ្ញុំដឹងតែឈ្មោះ វ៉ាន់ មួយទេ វ៉ាន់ៗ ឪពុករបស់ក្មួយម៉ៅហ្នឹង។ ហ្នឹងដឹងថាគាត់មានប្រពន្ធមានខ្មែរ ហើយកូនៗគេយកទៅសម្លាប់មែន។ តែចំណែក សេង ហាយ ហ្នឹង ម្ដាយ ហើយនិងអ្នកស្រី ម៉ុន ហួ ហ្នឹង ខ្ញុំមិនបានដឹងទេ ព្រោះបែកគ្នារហូតមែន។ ដឹងតែឈ្មោះ វ៉ាន់ ឡាយ ហ្នឹង ឪពុក វ៉ាន់ ម៉ៅ ហ្នឹងទេ ដែលខ្ញុំបានដឹង។

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំបន្តទៅមុខទៀត។ ខ្ញុំសួរមនុស្សពីរបីនាក់ទៀត ដែល<> ឃុន ម៉ុន <បានប្រាប់ឈ្មោះ។> នៅក្នុងឯកសារ <E3/5325> ហើយ 00824184 ហើយនិង -- អានេះជាភាសាអង់គ្លេស, ហើយភាសាខ្មែរ ERN 004551643 <ស៊ីក>, ហើយបារាំង ERN 00869284។ តើថាអ្នកថ្មីម្នាក់ឈ្មោះ តា<ប្រ៉ុញ> ស្គាល់ដែរទេ ដែល<សម្បុរ>ខ្មៅ ហើយគាត់មានប្រពន្ធវៀត-ណាម។ តើលោកស្រីដឹងពីឈ្មោះនេះទេ ឬក៏អាចនឹកឃើញអ្វីខ្លះពីឈ្មោះនេះ?

**ឆ៖** ខ្ញុំអត់បានស្គាល់ផង តាព្រឿង ដឹងនៅភូមិណាផង។

**ស៖** សំណួរមួយទៀត ហើយទៅទំព័រមួយទៀត។ ភាសាទាំងបីទំព័របន្ទាប់<។ ខ្ញុំត្រូវការសហ

ភាតាខ្ញុំជួយអានឈ្មោះហ្នឹង។>

**<លោក សេង លាង>**

<ឈ្មោះ ឡាច នី>

**<លោក នីកូឡាស គូមជែន>**

<**ស៖** តើលោកស្រីស្គាល់ឈ្មោះហ្នឹងទេ?>

**ឆ៖** ឈ្មោះ ឡាច លី ក៏ខ្ញុំមិនបានស្គាល់ដែរ អត់ដឹងនៅភូមិណាផង។

**ស៖** <ឥឡូវនេះ> ខ្ញុំនឹងបន្តទៅមុខ<ទៀត ហើយ>សួរអំពីឈ្មោះមនុស្សមួយចំនួនទៀតដែល<ស្ត្រីម្នាក់ឈ្មោះ> យឹម មួយ <បានប្រាប់>។

**<លោក សេង លាង>**

<ឈ្មោះ យឹម មួយ។>

**<លោក នីកូឡាស គូមជែន>**

ហើយឯកសារហ្នឹងគឺ E3/7783។ មុននឹងសួរសំណួរនេះ ដើម្បីបញ្ជាក់ថាលោកស្រីស្គាល់គាត់ដែរឬទេ គ្រួសាររបស់គាត់នៅក្នុងអន្លង់ទ្រា <ក្នុងទសវត្សរ៍>ឆ្នាំ១៩៦០ ហើយម្ដាយឈ្មោះ <ហាយ កាត់>រៀតណាម។ តើលោកស្រីស្គាល់ឈ្មោះគាត់ហ្នឹងទេ?

**ឆ៖** អត់ច្បាស់ មួយ ហ្នឹង កូនយាយហាយ ឬក៏សំណួរហ្នឹងអត់ច្បាស់ ខ្ញុំអត់យល់។<>

**ស៖** បាទ អ៊ីចឹងមែន។

**ឆ៖** ចាស យាយមួយ ហ្នឹងកូន យាយហាយ ស្គាល់ ប៉ុន្តែគាត់មានគ្រួសារទៅនៅឯជ្រៃគ្រហឹម តែឥឡូវគាត់ស្លាប់ហើយ កូនគាត់នៅភ្នំពេញហ្នឹងដែរ។

[០៩:២២:២៦]

**ស៖** តើលោកស្រីដឹងថាមានរឿងអីកើតឡើងចំពោះប្អូនប្រុសរបស់គាត់ឈ្មោះ កែ, ប្អូនស្រីឈ្មោះ ទៀង, ម្ដាយរបស់គាត់ឈ្មោះ ហាយ ហើយប្អូនស្រីមួយទៀតឈ្មោះ <ហួ ទេ>?

**ឆ៖** ក្រោយពី ៧៩ មក បែកគ្នា ខ្ញុំអត់បានដឹងគ្រួសារគាត់យ៉ាងម៉េចទេ ព្រោះចូលក្នុងសង្គ្រាមហើយ បែកគ្នារហូត អត់មានដែលជួបគ្នាសោះ។ គ្រាន់តែឮដឹងថាគេសម្លាប់ បងហួ ហ្នឹង តាំងពីហ្នឹងមក អត់ដែលជួបមុខគ្នារហូតទាល់មកសព្វថ្ងៃហ្នឹង។ អត់បានដឹង។

**ស៖** បាទ ដូច្នេះ ខ្ញុំនឹងអានពីចម្លើយដែលលោកស្រីបានឆ្លើយ។ ខ្មែរទំព័រ 00238898, បារាំង

00281807, ហើយអង់គ្លេស 0024216 <(ស៊ីក), គាត់>និយាយថា ប្រហែលជានៅឆ្នាំ១៩៧៧ <គាត់បានទៅស្ទួង>សំណាប<។> កូន<គាត់>ទាំង<ប្រាំពីរនាក់នៅផ្ទះជាធម្មតាទេ។> ហើយប្តីរបស់គាត់ជា<ជាង>កាត់ដេរនៅភូមិជ្រៃគ្រហឹម ហើយថ្ងៃមួយនៅក្នុងឆ្នាំនោះ គឺបុរសម្នាក់ឈ្មោះ អាន (ចឹកអាន) ជាអ្នកភូមិម្នាក់នៅភូមិពោធិ៍<រៀង ដែលធ្វើដំណើរទៅមក ពីទីនោះទៅភូមិស្វាយអន្ទរ គាត់បានប្រាប់ប្តីថា "គ្រួសារប្រពន្ធរបស់ឯងទាំងអស់>ត្រូវបានគេសម្លាប់<ហើយ>"។ <អ្នកដែលត្រូវគេសម្លាប់មានដូចជា ប្អូនប្រុសរបស់ យឹម មួយ ឈ្មោះ កែ, ប្អូនស្រីគាត់ឈ្មោះ ទៀង ដែលធ្វើការនៅក្នុងកងចល័តត្រូវសម្លាប់មុនគេ។>ហើយម្តាយរបស់គាត់ឈ្មោះ ហាយ ហើយប្អូនស្រីឈ្មោះ<ហួ និង>ប្រពន្ធរបស់ យុន <ម៉ុន ជាមួយក្មួយប្រុស ក្មួយស្រីបីនាក់ទៀត ត្រូវយកទៅ>សម្លាប់ប្រហែលជា<ពីរឬបី>ថ្ងៃក្រោយមក។

<តើ>លោកស្រី<មានទទួលព័ត៌មានអំពីរឿងហ្នឹងទេ? ខ្ញុំគិតថា លោកស្រីបានប្រាប់ពួកយើងថា លោកស្រីបានឮដំណឹងពីប្អូនប្រុសម្នាក់?>

**ឆ៖** ខ្ញុំមិនបានជួបគ្នាទេនៅពេលនោះ ខ្ញុំមិនបានដឹងអីទាំងអស់ ព្រោះនៅភូមិដោយខ្លួន។ ភូមិពាំងនោះ ស្រុកជ្រៃគ្រហឹម ខ្ញុំនៅអន្លង់ទ្រា ម៉េចនឹងដឹងឆ្ងាយ។ ហើយដូច ម៉ុន គាត់នៅស្វាយអន្ទរ ក៏មិនបានទាក់ទងគ្នាដែរឆ្ងាយជំនាន់នោះ ដូចដឹងស្រាប់ហើយសឹងតែវាស់ដីឲ្យដើរ គ្មានអ្នកណាហ៊ានឆ្លងទៅទាក់ទងសួរគ្នាបានទេ ការងារដោយឡែកៗ ព្រលឹមឡើងការងារៗ អត់ដែលបានជួបអ្នកណាម្នាក់សោះ។ សូមអស់យោបល់។

**ស៖** សូមអរគុណលោកស្រីចំពោះអ្វីដែលពន្យល់ពីអ្វីដែលលោកស្រីបានដឹង ឬក៏មិនបានដឹង។ ហើយខ្ញុំសួរបន្ទាប់ទៅទៀត គឺនៅក្នុងចម្លើយមួយផ្សេងទៀត នេះៗមកពីឯកសារ<>របស់បុគ្គលម្នាក់ដែលថាអាចនឹងអាយុ៧០ ហើយគាត់ឈ្មោះ មុំ ឈួយ ប្រពន្ធរបស់គាត់ឈ្មោះ នាង ផាន់។

**លោក សេង លាង៖**

--ហើយនិង នាង ផាន់ – ផាន់។

**អ្នកបកប្រែ៖**

បាទ មុំ ឆើយ -- ឈ្មោះ មុំ ឈួយ តើលោកស្រីស្គាល់ទេ?

**លោកស្រី សៅ សាក់៖**

**ឆ៖** ខ្ញុំអត់បានស្គាល់ផង ដឹងនៅភូមិណាផង មុំ – មុំ ឆើយ ហ្នឹង។

[០៩:២៦:៥០]

**លោក នីកូឡាស គូមជែន៖**

**ស៖** មុំ ឆឹយ ហើយប្រពន្ធ នាង ផាន់។ តើលោកស្រីស្គាល់ឆ្មបម្នាក់ទេ នៅក្នុងភូមិអន្លង់ទ្រា ដែលឈ្មោះថា យាយអ៊ិច។

**លោក សេង លាង៖**

ឈ្មោះ យាយដាក់។

**អ្នកបកប្រែ៖**

អ៎! យាយដាក់ បាទ។

**លោក សេង លាង៖**

យាយឌឹក។

**លោកស្រី សៅ សាក់៖**

**ឆ៖** ហ្នឹង យាយឌឹក កូនគាត់ឈ្មោះយាយបា។ យាយម៉ែយាយបា ហ្នឹង ឈ្មោះយាយ ឌឹក គាត់ធ្វើឆ្មបនៅភូមិខ្ញុំហ្នឹង គាត់ជួយសង្គ្រោះមនុស្សរាប់ៗរយ រាប់ម៉ឺននាក់ មិនមែនតែម្នាក់ ពីរនាក់ទេ គាត់ជួយសង្គ្រោះជនជាតិខ្មែរ គឺថាមួយភូមិអន្លង់ទ្រា មិនមែនតែភូមិអន្លង់ទ្រា បាក់ដោក វាលព្រៅ គាត់ជួយសង្គ្រោះ គាត់ឆ្មបចាស់មែន ប៉ុន្តែគាត់ជួយសង្គ្រោះប្រជាជនភូមិអន្លង់ទ្រាស្ទើរតែគ្រប់គ្នាពីម្ដាយទៅកូន ពីកូនដល់ចៅទៀត គាត់ធ្វើឆ្មបខ្មែរ តែគាត់គេយកគាត់ទៅសម្លាប់ដោយប្រជាជនមិនបានដឹងអី សូម្បីតែបន្តិច ស្ងាត់ៗបាត់គាត់ពីផ្ទះ សល់តែផ្ទះទទេ។

[០៩:២៨:០៨]

**លោក នីកូឡាស គូមជែន៖**

**ស៖** បាទ លោកស្រីដឹងជាតិ<ពន្ធុ>របស់គាត់ទេ <ស្ត្រី>ដែលគេយកគាត់ទៅសម្លាប់<>?

**ឆ៖** ដើមកំណើតគាត់ជនជាតិវៀតណាម។ ខ្ញុំកើតមកឃើញតែគាត់នៅភូមិហ្នឹង មិនដឹងគាត់ស្រុកកំណើតគាត់នៅឯណាផង តែខ្ញុំដឹងកើតមក ដឹងក្ដីមកឃើញតែគាត់នៅហ្នឹង ហើយគាត់ជួយប្រជាជនខ្មែរនៅភូមិខ្ញុំហ្នឹង។

**ស៖** ហើយដែលគាត់ៗសង្គ្រោះ<ជីវិតអ្នក>ទាំងអស់នោះ ថាតើអ្នកទាំងអស់ហ្នឹងជាជនជាតិវៀតណាម<ឬ? តើពួកគេហ្នឹងជាជនជាតិអ្វីដែរ>?

**ឆ៖** គឺគាត់ជួយសង្គ្រោះគ្មានប្រកាន់ថាវៀតណាម ឬខ្មែរទេ ឱ្យតែទៅរកគាត់ៗជួយទាំងអស់។

**ស៖** តើលោកស្រីចាំពេលណាមួយ នៅពេលដែលកម្មាភិបាលមូលដ្ឋាននៅតំបន់លោកស្រីនៅក្នុងព្រៃវែង គឺមានកម្មាភិបាលផ្សេងទៀតមកពីតំបន់ផ្សេងមកជំនួសពួកកម្មាភិបាលនៅមូលដ្ឋានហ្នឹងដែរទេ?

**ឆ៖** ខ្ញុំមិនបានដឹងទេលោកគ្រូ មិនបានដឹងសោះ ឃើញតែគេមកៗមិនដឹងពីណាពីណីទេ អត់ស្គាល់ទេច្បាស់ទេ យើងប្រជាជនមិនអាចហ៊ានសួរគេដឹងទេ គ្រាន់តែឃើញមកហ្នឹង មុខឈ្ងោកមុខហើយ មិនហ៊ានមើលមុខគេផង។

**ស៖** តើលោកស្រីអាចពន្យល់ដែលថា លោកស្រីបានឃើញពួកគេមក តើ<មានអ្វីកើតឡើងខ្លះនៅពេលពួកនោះមកដល់?>

**ឆ៖** និយាយថារួមប្រជាជន គេសួរឱ្យជួបផង ហើយខ្ញុំមិនសូវបាននៅក្នុងភូមិទេ ច្រើនតែទៅធ្វើការងារនៅវាល ព្រលឹមឡើងចេញទៅវាលហើយ ទាល់តែម៉ោងមួយដណ្តប់ បានគេឱ្យមកហូបបាយរួម។ ខ្ញុំមិនដែលបានជួបគេទេ មិនដឹងគេធ្វើសកម្មភាពយ៉ាងម៉េចក៏ខ្ញុំមិនបានដឹង។

**ស៖** តើអ្នកទាំងអស់នោះ<>និយាយ<តុងសំឡេងដូចអ្នកភូមិរបស់លោកស្រី ឬក៏ខុសគ្នា>?

[០៩:៣១:០២]

**ឆ៖** មិនដែលជួបផង មិនដែលជួបគេនិយាយគ្នាផង។ ជួបតែអាពួកអ្នកឃុំព្រែកជ្រៃ ហើយនិងអន្លង់ទ្រា ហ្នឹងជាប្រជាជននៅតាមភូមិហ្នឹង ខ្ញុំដឹងសុទ្ធតែជាប្រជាជនខ្មែរ។

**ស៖** តើការបាត់ខ្លួនជនជាតិវៀតណាម ឬក៏កូនកាត់វៀតណាម ដែល<យើងបានជជែកគ្នាតាំងតែពីថ្ងៃព្រហស្បតិ៍ តាម>លោកស្រី<ដឹង តើរឿងនេះបន្តមាន ក្រោយ>ពីពួកកម្មាភិបាលថ្មីមកជំនួសកម្មាភិបាលចាស់ដែរឬទេ? <តើលោកស្រីដឹងដែរទេ?>

**ឆ៖** ការចេះតែបាត់បន្តបន្ទាប់ៗ ទាល់តែយើងជិតបែក ជិតវៀតណាម ឮថាវៀតណាមចូលជិតៗហ្នឹងបានឈប់តែម្តង។

**លោក នីកូឡាស គូមជែន៖**

សូមអរគុណ។ លោកប្រធាន ខ្ញុំនឹងផ្តល់វេទិកាក្នុងការសួរសាក្សីនេះទៅមេធាវីដើមបណ្តឹងរដ្ឋប្បវេណី មេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី។ សូមអរគុណលោកស្រីសាក្សី។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[០៩:៣២:៣៤]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** ជម្រាបសួរលោកស្រីសាក្សី ខ្ញុំឈ្មោះ ម៉ារី ហ្គីរ៉ូដ៍ ខ្ញុំជាតំណាងឲ្យក្រុមដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរខ្លីៗមួយចំនួន ដើម្បីសួរលោកស្រី គឺជាសំណួរដែលសុំការបញ្ជាក់បន្ថែមពីអ្វីដែលលោកស្រីបានពន្យល់កាលពីថ្ងៃព្រហស្បតិ៍សប្តាហ៍មុន។ កាលពីសប្តាហ៍មុន នៅថ្ងៃព្រហស្បតិ៍ លោកស្រីបាននិយាយថា មានកូនកាត់ និងកូនដែលកើតចេញពីប្តីប្រពន្ធ ដែលចម្រុះជាតិសាសន៍នៅភូមិអន្លង់ទ្រា ដូច្នេះ ខ្ញុំចង់ដឹងថា បើមើលតាមអាការៈខាងក្រៅនោះ យើងអាចមើលដឹងថា កូនណាជាកូនកាត់ដែរឬទេ? ហើយបើសិនជាមានមែននោះ តើគេមើលយ៉ាងម៉េចបានដឹងថាកូនហ្នឹងជាកូនកាត់ ហើយខុសពីកូនផ្សេងៗទៀត?

**លោកស្រី សៅ សាក់៖**

**ឆ៖** ចាស នៅក្នុងភូមិហ្នឹង គឺដឹងតែនៅក្នុងភូមិអន្លង់ទ្រាហ្នឹង គឺមានដូចថាជាប់សាច់ឈាមអីស្គាល់ពីម៉ែ ពីកូនអី ដឹងអ៊ីចឹង មានប្រពន្ធ មានកូនទៅ បានខ្ញុំដឹង។ បើថានៅស្រុកផ្សេងទៀត មិនបានដឹងទេមិនបានសម្គាល់ទេ ព្រោះដឹងតែនៅក្នុងភូមិហ្នឹង។ ដូច វ៉ាន់ ម៉ៅ អ៊ីចឹង វ៉ាន់ ម៉ៅ ហ្នឹងដឹងថាគាត់មានប្រពន្ធខ្មែរអ៊ីចឹង បានដឹងថាគាត់ជាកូនកាត់ ហើយនាងណាត អ៊ីចឹងដឹងថា កូនហ្នឹងគាត់សុំពីវៀតណាមមកចិញ្ចឹម ៗហើយគាត់មានប្តីខ្មែរ ហើយកូនហ្នឹងវាត្រូវមានកូនកាត់អ៊ីចឹងហើយនៅក្នុងភូមិ ដឹងតែនៅក្នុងភូមិ តែនៅក្រៅភូមិទៀតអត់បានដឹង។

**ស៖** សូមអរគុណលោកស្រី ខ្ញុំសួរហ្នឹង គឺសួរតែនៅក្នុងភូមិលោកស្រីទេ គឺភូមិអន្លង់ទ្រា ខ្ញុំចង់ដឹងថានៅក្នុងភូមិលោកស្រីហ្នឹង តើយើងមើលដឹងភ្លាមៗទេថា អ្នកណាជាខ្មែរ អ្នកណាជាវៀតណាមរូបរាងកាយហ្នឹង គឺមើលទៅដូចគ្នា ឬក៏មានលក្ខណៈខុសៗគ្នា?

**ឆ៖** ចាស មានរូបរាងកាយដូចគ្នា ខ្មៅៗអ៊ីចឹង ប៉ុន្តែគ្រាន់តែចំណាំថា កូនហ្នឹងឪពុកវាយួននេះកូនហ្នឹង ឪពុកវាខ្មែរ -- អ៎! ម្តាយវាខ្មែរ គ្រាន់តែប៉ុណ្ណឹងឯង។

[០៩:៣៥:០០]

**ស៖** លោក<ស្រី>និយាយថា អ្នកហ្នឹងមើលទៅខ្មៅ ស្បែកខ្មៅ ខ្មៅហ្នឹងលោក<ស្រី>សំដៅ <កូនកាត់ ឬក៏កូនដែលមាន>ឪពុកម្ដាយ<ជាជនជាតិខ្មែរ មែនទេ>?

**ឆ៖** សំដៅលើឪពុកម្ដាយៗ វៀតណាមយើងនាំគ្នាថា កូនហ្នឹងកាត់វៀតណាម មានសំខាន់អី រឿងស រឿងខ្មៅអីទេ។ បើឪពុកគេវៀតណាម ចេះតំណាលៗគ្នា អេ៎! អាហ្នឹងកូនកាត់យួន អានេះកូនកាត់ ម៉ែវាយួន ឪវាយួនអ៊ីចឹងទៅ។ ចេះតែតំណាលៗគ្នាទៅ។

**ស៖** ពាក់ព័ន្ធនឹងពណ៌សម្បុរ ដើម្បីឲ្យយល់ច្បាស់អំពីចម្លើយរបស់លោកស្រី ខ្ញុំចង់សួរលោកស្រីថា កូនកាត់ដែលមានឪពុក ឬម្ដាយជាជនជាតិវៀតណាមហ្នឹងមានសម្បុរ<ខ្មៅ>ជាងកូនផ្សេងៗទៀត ឬក៏មានសម្បុរយើងមើលទៅដូចៗតែគ្នាទេ?

[០៩:៣៦:១៣]

**ឆ៖** បើនិយាយពីសម្បុរវិញ ដូចខ្ញុំអ៊ីចឹង ដូចថាកាត់ទៅម្ដាយទៅសទៅ ដូចអ្នកខ្លះទៅកាត់ទៅឪពុកទៅខ្មៅ។ ដូច វ៉ាន់ ម៉ៅ ហ្នឹងខ្មៅតែម្ដង បើអស់លោកឃើញមិនមែនថាកូនវៀតណាមទេ ខ្មៅមែនទែន ខ្មៅជាងខ្ញុំឆ្ងាយណាស់។ បានថារកសម្គាល់ថា ស បានកូនវៀតណាម ខ្មៅមិនមែនកូនវៀតណាម។ វាអត់ ចំណាំអត់បាន។

**ស៖** សូមអរគុណលោកស្រី។ ឥឡូវនេះ ខ្ញុំយល់ច្បាស់ហើយ។ អ៊ីចឹងនៅក្នុងភូមិហ្នឹងគេដឹងយ៉ាងម៉េចថាអ្នកណាមានឪពុក ឬម្ដាយវៀតណាម ឬក៏មានឪពុក ឬក៏ម្ដាយខ្មែរនោះ? គេធ្វើយ៉ាងម៉េចនៅក្នុងភូមិលោកស្រីហ្នឹង <គឺភូមិអន្លង់ទ្រាហ្នឹង> ទើបដឹងថា អ្ហូ! អ្នកនេះជាជនជាតិវៀតណាម អ្នកនេះជាជនជាតិខ្មែរអ៊ីចឹង?

**ឆ៖** បើតាមខ្ញុំគិតខ្លួនទេ ប្រហែលជាប្រធានភូមិហ្នឹងគេធ្វើស្ថិតិអី គេកត់អីក៏មិនដឹង ប៉ុន្តែខ្ញុំបើតាមមើលថា នៅក្នុងភូមិហ្នឹងគឺចំណាំអ៊ីចឹង។ ចំណាំថា -- ព្រោះក្នុងដឹង ក្នុងភូមិហ្នឹងអ្នកណាមានប្រពន្ធខ្មែរ អ្នកណាមានប្ដីខ្មែរ ប្ដីយួនអី គឺដឹងទាំងអស់អ៊ីចឹង។ ប៉ុន្តែក្នុងអង្គការគេហ្នឹងតាមភូមិអីប្រហែលជាគេធ្វើស្ថិតិ ក៏ខ្ញុំប្រហែលជាអ៊ីចឹងមែន ប៉ុន្តែខ្ញុំមិនបានដឹងៗ ប្រហែលជាគេធ្វើស្ថិតិបានថ្នាក់លើដឹងថា កូនខ្មែរ កូនយួនអ៊ីចឹងណ៎ា ប្រហែលជាអ៊ីចឹងហើយភូមិ ឃុំគេហ្នឹងចុះធ្វើស្ថិតិហើយ។ តែរូបខ្ញុំផ្ទាល់មិនបានដឹងទេ ដឹងថាឪពុកកូនហ្នឹងកើត -- ដណ្ដឹងប្រពន្ធខ្មែរអ៊ីចឹងទៅ ស្គាល់ទៅ បងហ្នឹងបើមានកូន អត់មានកូន អ៊ីចឹងសុំកូនយួនមកចិញ្ចឹមទៅ ដឹងប្រវត្តិតាមៗប្រវត្តិដែលខ្មែរយើងទៅសុំកូនមកចិញ្ចឹម ដែលគាត់

គ្មានកូនហ្នឹង។ ត្រង់ហ្នឹងស្គាល់ប៉ុណ្ណឹង។

**ស៖** នៅពេលដែលលោកស្រីនិយាយថាលោកស្រីគិតថាមេភូមិធ្វើស្ថិតិហ្នឹង <តើ>លោកស្រីធ្លាប់ឮគេនិយាយ<អ៊ីចឹង កាលនៅជំនាន់នោះ ថាមានរបាយការណ៍ ឬបញ្ជីអ្វីដែរ ឬទេ?>

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាល់ទាន់ឆ្លើយតប។ សូមអញ្ជើញមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោកស្រីចៅក្រម។ ខ្ញុំ<សូម>ផ្តល់ការសង្កេតតាំងពីមុន <ដោយសារ>ខ្ញុំឮសាក្សី<ឆ្លើយ>ទៅនឹងសំណួរដំបូង "តាមគំនិតរបស់ខ្ញុំ ប្រធានភូមិអាចបានធ្វើបែបនេះ ឬបែបនោះ"។ ខ្ញុំយល់ពីសំណួរបន្ថែម ប៉ុន្តែការធ្វើបែបនេះគឺថាអាចជាផលប្រយោជន៍ដល់ ភាគីផ្សេងទៀតដើម្បីមានការណែនាំដល់សាក្សីឱ្យនិយាយអ្វីដែលគាត់ពិតជាបានដឹងជាជាងផ្តល់ជាគំនិត<យោបល់>ថាតាមអ្វីដែលគាត់គិត ឬក៏ថាអាចបែបនេះ អាចបែបនោះ។ បាទ សូមអរគុណ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

នេះគឺខ្លឹមសារនេះសំណួររបស់ខ្ញុំហើយលោកប្រធានអម្បាញ់មិញនេះ។ ខ្ញុំចង់សួរបញ្ជាក់គាត់ឱ្យបានច្បាស់ថាគាត់ដឹងដោយផ្ទាល់ ឬក៏គ្រាន់តែគាត់យល់ថាយ៉ាងអ៊ីចឹង។ អ៊ីចឹងហើយបានជាខ្ញុំសួរបែបហ្នឹងនុ៎ង។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** លោកស្រីសាក្សី ខ្ញុំសួរបញ្ជាក់លោកស្រីម្តងទៀត។ លោកស្រីដឹងដោយផ្ទាល់ទេថាមេភូមិនៅសម័យនោះគាត់បានធ្វើស្ថិតិ។ លោក<ស្រី>ដឹងថាមានការធ្វើបែបហ្នឹងទេ?

**លោកស្រី សៅ សាក់៖**

**ឆ៖** ដឹងគេធ្វើស្ថិតិខ្មែរ ប៉ុន្តែត្រង់ថាវៀតណាមហ្នឹង មិនបានដឹងទេ។

**ស៖** លោកស្រីបាននិយាយ<អំពី>ម្តាយរបស់លោកស្រីកាលពីថ្ងៃព្រហស្បតិ៍ លោកស្រីថាម្តាយលោកស្រីជាកូនកាត់ គឺវៀតណាមពាក់កណ្តាល ខ្មែរពាក់កណ្តាល។ ដូច្នេះខ្ញុំចង់ដឹងថា តើម្តាយលោក<ស្រីចេះ>និយាយភាសាវៀតណាមទេ?

**ឆ៖** គាត់មិនដែលនិយាយភាសាវៀតណាមទេ ប៉ុន្តែគ្រាន់ថាវៀតណាមនិយាយមក គាត់ដឹង។

**ស៖** កាលពីថ្ងៃព្រហស្បតិ៍ លោកស្រីក៏បាននិយាយអំពីកូនកាត់ផ្សេងទៀតដែលរស់នៅភូមិអន្លង់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទ្រា។ លោកស្រីដឹងថាកូនកាត់ទាំងអស់ហ្នឹងនិយាយភាសាវៀតណាមទេនៅសម័យខ្មែរក្រហមនោះ?

[០៩:៤១:១២]

**ផ៖** កូនក្មេងទាំងអស់ ដែលកូនកាត់ៗហ្នឹង គ្មានអ្នកណាចេះវៀតណាមមួយម៉ាត់ទេ តែមួយម៉ាត់ក៏មិនចេះផង។ តាំងពីកើតមករហូតមកទាល់ឥឡូវហ្នឹង គ្មានអ្នកណាចេះទេ។

**ស៖** សូមអរគុណ។ កាលពីថ្ងៃព្រហស្បតិ៍ នៅពេលដែលលោកស្រីឆ្លើយទៅសំណួររបស់សហព្រះរាជអាជ្ញារងអន្តរជាតិ លោកស្រីថាជនជាតិវៀតណាម និងកូនកាត់នៅភូមិរបស់លោកស្រីត្រូវបានគេនាំចេញទៅ ទៅភាគខាងក្រោម<នៃប្រទេសកម្ពុជា> ហើយ<បន្ទាប់មក>លោកស្រីថា តាមពិតទៅគឺគេបញ្ជូនទៅវៀតណាម។ ដូច្នេះ ខ្ញុំចង់អាននូវចម្លើយរបស់លោកស្រីកាលពីថ្ងៃព្រហស្បតិ៍ បន្ទាប់មកខ្ញុំនឹងសួរសំណួរពាក់ព័ន្ធនឹងចំណុចនេះ។ គឺម៉ោង ០៣:២០:១៥នាទី លោកស្រីឆ្លើយថា "ខ្ញុំឃើញគេប្រមូលផ្តុំពួកគេ ហើយបញ្ជូនទៅខាងក្រោម។ អ្នកណាមកពីគ្រួសារចម្រុះ<ជាតិសាសន៍> គេចេះតែប្រមូលទៅ ហើយបញ្ជូនដឹកតាមទូកទៅ។ ហើយបើអ្នកណាជាគ្រួសារចម្រុះជាតិ<សាសន៍>ហ្នឹង គេបញ្ជូនម្តងមួយគ្រួសារទៅតែម្តង ហើយពួកគេបាត់ខ្លួន"។

<តើ>លោកស្រីចាំទេថា កាលពីថ្ងៃព្រហស្បតិ៍សប្តាហ៍មុនហ្នឹង លោកស្រីបានឆ្លើយបែបនេះ?

**ផ៖** ចាស ខ្ញុំបានឆ្លើយបែបហ្នឹងមែន។

**ស៖** លោកស្រីអាចពន្យល់ជូនអង្គជំនុំជម្រះបានទេថា <តាមលោកស្រីចាំច្បាស់> តើគេប្រមូលផ្តុំ <និងបញ្ជូន>អ្នកទាំងអស់ហ្នឹងយ៉ាងដូចម្តេច? លោកស្រីចាំអ្វីខ្លះពីហេតុការណ៍នៃការប្រមូលផ្តុំអ្នកទាំងអស់ហ្នឹង?

[០៩:៤៣:០៣]

**ផ៖** គេប្រមូលបញ្ជូនទៅ ខ្ញុំមិនបានឃើញច្បាស់នូវដែលគេយកទៅហ្នឹង ឮប្រមូល ដូចថាហៅអ៊ីចឹងទៅមួយគ្រួសារៗអ៊ីចឹងទៅ ទៅបាត់ទៅៗ គេមិនឲ្យយើងឃើញទេ ជួនកាលទៅយប់ ជួនកាលទៅថ្ងៃ។ យើងនៅធ្វើការមិនអាចដឹង គ្រាន់តែដឹងថាពីរបីថ្ងៃទៅបាត់គ្រួសារហ្នឹង ចេះតែលួចសួរ គេថាយកទៅក្រោមបាត់ហើយៗ យើងមិនអាចដឹងថាគេយកទៅឯណា។

**ស៖** លោកដឹងទេថា អ្នកណាជាអ្នកប្រមូលគ្រួសារទាំងអស់ហ្នឹង<កាលនោះ>? ជាកម្មាភិបាល <ឬ>ឈ្លប នៅភូមិអន្លង់ទ្រា ឬក៏មានមនុស្សមកពីខាងក្រៅជាអ្នកមកប្រមូលគ្រួសារទាំងអស់ហ្នឹងយកចេញទៅ? លោកស្រីមានចាំទេ?

**ឆ៖** ខ្ញុំមិនបានដឹងទេ អត់បានដឹងអ្នកណាៗមកយកទេ។ ព្រោះដឹងថាបាត់ៗតែម្តង។

[០៩:៤៤:១៦]

**ស៖** នៅក្នុងភូមិរបស់លោកស្រី លោកស្រីធ្លាប់ឮគេនិយាយអំពីការធ្វើតេស្ត ដើម្បីឱ្យដឹងថាអ្នកណាចេះវៀតណាម ឬក៏អត់ទេ លោកស្រីធ្លាប់ឮគេនិយាយអំពីការតេស្តបែបហ្នឹងទេ នៅសម័យនោះ?

**ឆ៖** អត់មានផង។ អត់មានធ្វើតេស្តអីទាំងអស់។

**ស៖** កាលពីថ្ងៃព្រហស្បតិ៍លោកស្រីបាននិយាយថា អ្នកដែលត្រូវបានប្រមូល ហើយនិងជម្លៀសចេញទៅហ្នឹង គឺគេបញ្ជូនទៅវៀតណាម។ លោកស្រីបានព័ត៌មានហ្នឹងមកពីណា? ហើយ<នៅថ្ងៃនេះ> ហេតុអីបានជាលោកស្រីប៉ាននិយាយថាគេប្រមូលក្រុមគ្រួសារទាំងអស់ហ្នឹងបញ្ជូនទៅវៀតណាម?

**ឆ៖** ចេះតែឮតៗគ្នាថា គេបញ្ជូនទៅក្រោម បញ្ជូនទៅវៀតណាម។

**ស៖** លោកស្រីឮតៗគ្នាហ្នឹង ឮតពីអ្នកណា? ពីអ្នកនៅភូមិអន្លង់ទ្រាហ្នឹង ឬក៏អ្នកណាផ្សេង? <កាលនោះ>អ្នកភូមិនាំគ្នានិយាយនៅក្នុងភូមិហ្នឹងថា គេប្រមូលក្រុមគ្រួសារទាំងអស់ហ្នឹងបញ្ជូនទៅវៀតណាម ឬក៏លោកស្រីដឹងរឿងនេះក្រោយមកទេ គឺចប់របបកម្ពុជាប្រជាធិបតេយ្យហើយទេទើបដឹង?

**ឆ៖** ចេះឮតៗគ្នានៅក្នុងភូមិហ្នឹង ឃើញគេយកទៅថា ហ៊ឺ! គេបញ្ជូនទៅវៀតណាមហើយអ្នកដែលនៅក្នុងភូមិយើងហ្នឹង គេឱ្យទៅស្រុកកំណើតវៀតណាមវិញ ចេះឮតែអ៊ីចឹងទៅទាំងអស់តែគ្នាហ្នឹង។

**ស៖** សំណួរចុងក្រោយ<របស់ខ្ញុំចំពោះ>លោកស្រីសាក្សី លោកស្រីនិយាយថា អ្នកភូមិនិយាយគ្នាថា គេបញ្ជូនគ្រួសារទាំងអស់នោះទៅវៀតណាម។ ដូច្នេះខ្ញុំចង់ដឹងថា លោកស្រីធ្លាប់ឮកម្មាភិបាល ឬក៏ឈ្លបណា គេនិយាយថាគេបញ្ជូនគ្រួសារទាំងហ្នឹងទៅវៀតណាមទេ?

**ឆ៖** គ្មានដែលឮឈ្លបណានិយាយប្រាប់ទេ ប៉ុន្តែឮតែគ្នាឯងហ្នឹងថា ហ៊ឺ! គេបញ្ជូនឱ្យទៅស្រុកកំណើតវិញហើយ ព្រោះគេមិនឱ្យនៅទេវៀតណាម។ ដឹងតែប៉ុណ្ណឹង ដឹងតែប្រជាជននិយាយគ្នា។

[០៩:៤៦:៥២]

**ស៖** សូមអរគុណលោកស្រីសាក្សី។

លោកប្រធាន ខ្ញុំអស់សំណួរហើយ។ ហើយខ្ញុំសូមបញ្ជាក់ថា ក្នុងការបកប្រែជាភាសាបារាំងប្រហែលជាកំហុស។ អ៊ីចឹងគួរតែសួរសំណួរឡើងវិញ។

លោកស្រីបាននិយាយថា <លោកស្រីបានឮចាស់ៗនៅក្នុងភូមិនិយាយថា> ជនជាតិវៀត

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

E1/363.1

ណាមហ្នឹងមិនមានសិទ្ធិរស់នៅវៀតណាម<ទេ>អម្បាញ់មិញនេះ។ ខ្ញុំឮតាមរយៈការបកប្រែជាភាសាបារាំង។ លោកស្រីនិយាយអ៊ីចឹង ឬក៏ប្រហែលជាគេបកប្រែខុសទៅជាភាសាបារាំងនោះ?

**ឆ៖** ប្រជាជនដែលគេបញ្ជូនទៅហ្នឹង គេថាឲ្យទៅនៅវៀតណាមវិញ។ ខ្ញុំនិយាយតែប៉ុណ្ណឹង មិនមែនថាគេមិនឲ្យនៅឯណា។ អំមិញនិយាយខុស។ ខ្ញុំនិយាយថា ប្រជាជនគេបញ្ជូនៗទៅ គេឲ្យទៅនៅភូមិកំណើតស្រុកវៀតណាមវិញ។ នាំគ្នានិយាយអ៊ីចឹង ថាគេបញ្ជូនៗទៅហ្នឹង ប្រហែលឲ្យទៅនៅស្រុកវៀតណាមវិញហើយ។ ខ្ញុំនិយាយប៉ុណ្ណឹង។

**ស៖** ខ្ញុំយល់ច្បាស់ហើយលោកស្រីសាក្សី។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

<ប្រសើរណាស់។> សូមអរគុណលោកប្រធាន។ ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តី។ ដំបូងនេះ ផ្តល់វេទិកាទៅក្រុមសហមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

មានបញ្ហាបកប្រែភាសា លោក អរុណ!

បាទ តទៅនេះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សីរូបនេះ។ បាទ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** អរុណសួស្តីលោកស្រីសាក្សី។ ខ្ញុំមិនមានសំណួរច្រើនប៉ុន្មានទេ មានតិចតួចទេដែលត្រូវសួរលោកស្រីនៅព្រឹកនេះ។ ខ្ញុំសូមចាប់ផ្តើមសួរនូវសំណួរដូចតទៅនេះ។ លោកស្រីកើតនៅក្នុងឆ្នាំ១៩៥៣ មានន័យថាលោកស្រីមានអាយុ១៧ឆ្នាំ នៅឆ្នាំ១៩៧០។ ត្រឹមត្រូវដែរទេ?

**លោកស្រី សៅ សាក់៖**

**ឆ៖** ចាស ត្រឹមត្រូវ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** នៅចន្លោះពីឆ្នាំ១៩៧០ ដល់ ៧៥ តើលោកស្រីធ្លាប់ធ្វើដំណើរចេញទៅក្រៅភូមិរបស់លោកស្រីទេ ដូចជាមកភ្នំពេញ ចន្លោះឆ្នាំ១៩៧០ ដល់ ឆ្នាំ១៩៧៥ហ្នឹង លោកស្រីដែលដើរចេញទៅណាក្រៅភូមិទេ?

**ឆ៖** ចាស ខ្ញុំអត់ដែលបានដើរចេញពីភូមិអន្លង់ទ្រាហ្នឹងទេ នៅតែភូមិអន្លង់ទ្រា។

**ស៖** តើលោកស្រីមានសាច់ញាតិគ្រួសារនៅភ្នំពេញ ឬក៏ដូចជានៅតាកែវ អីជាដើម មានទេ?

**ឆ៖** ចាស អត់មានទេ។

**ស៖** តើលោកស្រីមានបានដឹងថាមានអ្វីកើតឡើងនៅក្រៅភូមិរបស់លោកស្រីចន្លោះពីឆ្នាំ១៩៧០ ដល់១៩៧៥ ឧទាហរណ៍ ដូចជាអ្វីដែលកើតឡើងទៅដល់ប្រជាជនដែលមានជនជាតិដើមជាវៀតណាមនោះ?

[០៩:៥១:២១]

**ឆ៖** ខ្ញុំមិនបានដឹងទេ ដឹងតែពេលដែលគេឲ្យទៅ ក្រោយមកហ្នឹង គេឲ្យបញ្ជូនបណ្ដើរៗហ្នឹង ដឹងតែប៉ុណ្ណឹង។ ត្រង់ថា មានសកម្មភាពអីខាងក្រៅ គឺគ្មាន មិនបានដឹង។

**ស៖** លោកស្រីដែលឮស្វរម្ដាយរបស់លោកស្រីនិយាយអំពីការសម្លាប់ជនជាតិវៀតណាមក្នុងទ្រង់ទ្រាយធំដែរទេ នៅក្នុងឆ្នាំ១៩៧០? <ឬ>ការចាប់ចងជនជាតិវៀតណាមទ្រង់ទ្រាយធំ សម្លាប់ទ្រង់ទ្រាយធំ ក្នុងឆ្នាំ១៩៧០? ឬក៏មានការឃោសនាណាមួយដែលប្រឆាំងទៅនឹងអ្នកដែលមានសញ្ជាតិដើមជាវៀតណាម ដែលដឹងទេ? <តើលោកស្រីដឹងដែរទេ?>

**ឆ៖** ចាស ខ្ញុំមិនបានដឹងទេ។

**ស៖** ខ្ញុំសូមត្រឡប់ទៅសួរនូវអ្វីដែលលោកស្រីបានឆ្លើយកាលពីថ្ងៃ<ព្រហស្បតិ៍>សប្ដាហ៍មុន នៅម៉ោង១៤:<៣៣>នាទី។ សំណួរដូចតទៅ ខ្ញុំគិតថា សំណួរនេះ គឺជាសំណួរមកពីតំណាងសហព្រះរាជអាជ្ញាជាតិ។ “តើលោកស្រីអាចជម្រាបជូនតុលាការបានទេ <ថា>តើ<អ្នកមូលដ្ឋាន>ចាត់ទុកវៀតណាម<យ៉ាងម៉េចដែរ> ហើយតើមានប្រព្រឹត្តខុសគ្នាដែរឬទេ មកលើជនជាតិវៀតណាមនៅមុនឆ្នាំ១៩៧៥ និងក្រោយ៧៥?” ចម្លើយរបស់លោកស្រីឆ្លើយថា <ខ្ញុំដកស្រង់>៖ “មុនឆ្នាំ១៩៧៥ យើងមានទំនាក់ទំនងធម្មតា។ ក្រោយមកគេក៏ស្រាវជ្រាវ រកជនជាតិវៀតណាម<នៅពេលនោះ>”។<បញ្ចប់ការដកស្រង់។> ចម្លើយរបស់លោកស្រីកាលថ្ងៃព្រហស្បតិ៍នុ៎ង តើលោកស្រីកម្រិតចម្លើយនេះ តែចំពោះតែប្រជាជន<ដើមកំណើត>វៀតណាមនៅក្នុងភូមិរបស់លោកស្រី<ទេ ឬយ៉ាងម៉េច>?

**ឆ៖** ជនជាតិវៀតណាម ហើយជនជាតិខ្មែរ បានទំនាក់ទំនងដែលគ្មានការទំនាស់ទាស់ទែងអីគ្នាទេ ហើយបើគេយកទៅ ក៏ប្រជាជនខ្មែរក៏មិនដឹងថាគេយកទៅពេលណា ហើយគេទាក់ទងអីគ្នាយ៉ាងម៉េច ក៏ខ្ញុំមិនដឹង។

[០៩:៥៤:០៨]

**ស៖** តែនៅពេលដែលលោកស្រីឆ្លើយកាលពីថ្ងៃព្រហស្បតិ៍កន្លងទៅនេះ ទៅនឹងសំណួរពាក់ព័ន្ធទៅនឹងការប្រព្រឹត្តមកលើជនជាតិវៀតណាមមុនឆ្នាំ១៩៧៥ លោកស្រីបានឆ្លើយកម្រិតតែអ្វីដែលបានកើតឡើងនៅក្នុងភូមិរបស់លោកស្រីទេ ខាងក្រៅភូមិរបស់លោកស្រី លោកស្រីមិនដឹងទេ ដឹងតែក្នុងភូមិទេ។ អ៊ីចឹងមែនទេ?

**ឆ៖** ក្នុងភូមិហ្នឹងក៏គ្មានសកម្មភាពអ្វីប្លែកដែរ។

**ស៖** សុំបញ្ជាក់ឲ្យបានច្បាស់ លោកស្រីមិនធ្លាប់ឮអំពីការសម្លាប់ជនជាតិវៀតណាមទ្រង់ទ្រាយធំទេឬនៅក្នុងរបបលន់ នល់?<>

**ឆ៖** ចាស ខ្ញុំមិនបានឮទេ ព្រោះកិច្ចការនេះ មិនមែនកិច្ចការប្រជាជនទេ។ ប្រជាជនគិតតែរកស៊ីចិញ្ចឹមកូន អត់បានគិតរឿងផ្សេង។

**ស៖** ខ្ញុំសូមផ្តល់ឧទាហរណ៍មួយជូនទៅលោកស្រី។ ការសម្លាប់<ពលករ>វៀតណាមទ្រង់ទ្រាយធំចំនួន៨០០នាក់ ហើយសាកសពរបស់ជនជាតិវៀតណាមទាំង៨០០នាក់ហ្នឹងត្រូវបានគេទម្លាក់ចូលទៅក្នុងទន្លេ<បាសាក់ នៅក្នុងឆ្នាំ១៩៧០>។ លោកស្រីធ្លាប់បានឮរឿងនេះទេ?<>

**ឆ៖** ចាស ខ្ញុំអត់បានឮសោះ អត់បានដឹង។ ដូចខ្ញុំជម្រាបលោកតុលាការអ៊ីចឹងថា ខ្ញុំប្រជាជនមិនអាចគិតអ្វីរឿងផ្សេងក្រៅពីចិញ្ចឹមគ្រួសារ ហើយនិងការភ័យខ្លាចគ្រាប់ផ្លោងគ្រាប់បែកទេជំនាន់នោះ។

**ស៖** ចុះលោកស្រីធ្លាប់ស្តាប់ឮតាមការផ្សាយតាមវិទ្យុថា <រដ្ឋាភិបាល>លន់ នល់<>បានសារភាពថាបានចាប់វៀតណាម ៣០.០០០នាក់ ហើយដាក់គុកចំនួន ៧០០០នាក់ <ក្រោមការសង្ស័យថាក្បត់ជាតិ>។ លោកស្រីបានឮរឿងនេះទេ?

**ឆ៖** ចាស ខ្ញុំមិនដែលឮទេ ព្រោះខ្ញុំ ផ្ទះខ្ញុំក្រគ្មានវិទ្យុស្តាប់ផង។

**ស៖** ដូច្នេះខ្ញុំសន្មតថា លោកស្រី<មិនដែលឮ>ការសម្លាប់<ទ្រង់ទ្រាយធំលើ>ជនជាតិវៀតណាមនៅតាកែវ មុនឆ្នាំ១៩៧៥ទេ។ លោកស្រីអត់ដែលឮរឿងនេះទេឬ?

**ឆ៖** ចាស ខ្ញុំមិនដែលបានឮទេ។

[០៩:៥៧:១០]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

លោកប្រធាន ខ្ញុំសូមដាក់សំណើមួយ។ តើយើងអាចមានលេខយោងឯកសារដែលមេធាវីគាត់យកមកសួរ<សាក្សី>ហ្នឹងបានទេលោកប្រធាន?

**លោក វ៉ិចទ័រ កូប៉េ៖**

<ពិតជាបាន> លោកប្រធាន<។ ប៉ុន្តែតាមការអនុវត្តកន្លងមក ខ្ញុំ>សួរជាសំណួរ<បើក>សិនបន្ទាប់មក ទើបខ្ញុំបង្ហាញអំពីប្រភពនៃព័ត៌មានរបស់ខ្ញុំដែលបានយកមកសួរនេះ។ <ទុកឱ្យខ្ញុំសួរសំណួរចុងក្រោយមួយនេះសិន បន្ទាប់មកខ្ញុំនឹងប្រាប់ប្រភពដែលខ្ញុំយោង។>

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** <តើ>លោកស្រីដែលឮសួរការឃោសនាប្រឆាំងទៅនឹងជនជាតិចិន<នៅទីក្រុងភ្នំពេញ>នៅមុនឆ្នាំ១៩៧៥ ដែរទេ? គឺប្រជាជនដែលជាប់សាច់ឈាមជាជនជាតិចិតតាំងពីដូនតាហ្នឹងមក ត្រូវ<រងការគំរាមសម្លាប់ជាទ្រង់ទ្រាយធំ>។ លោកស្រីធ្លាប់ឮទេ?

[០៩:៥៨:១៥]

**លោកស្រី សៅ សាក់៖**

**ឆ៖** ចាស ខ្ញុំមិនបានធ្លាប់ឮទេ។ មិនបានដឹងទាំងអស់។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំយោងទៅសៀវភៅមួយក្បាលដែលសរសេរ<ដោយបុគ្គលម្នាក់ ដែលតុលាការចាត់ទុកគាត់ថា>ជាអ្នកជំនាញ<ម្នាក់។ ក្នុង>សៀវភៅរបស់ អេលីហ្សាបេត បេកយ័រ គឺឯកសារ E3/20, ERN អង់គ្លេស 00237829 ដល់ 30, ខ្មែរ 00232165 ដល់ 66, បារាំង 00638396-97, និយាយអំពីការឃោសនាប្រឆាំងទៅនឹងជនជាតិវៀតណាម។ ជាការឃោសនារបស់របបលន់ នល់ ពាក់ព័ន្ធទៅនឹងការសម្លាប់<ទ្រង់ទ្រាយធំទៅលើ>ជនជាតិវៀតណាម <និងការឃុំខ្លួន>ក្នុងទ្រង់ទ្រាយធំ ហើយក្នុងនោះក៏មានការគំរាមកំហែងទៅដល់អ្នកជាកូនចៅចិន<ដោយជោគវាសនាគេដូចទៅនឹង>ជនជាតិ<ចិននៅ>ឥណ្ឌូនេស៊ីនៅក្នុង<>ឆ្នាំ<១៩៦៥ ដែលពួកគេត្រូវបានកម្ទេចទ្រង់ទ្រាយធំ ដោយរដ្ឋាភិបាលគាំទ្រពួកបស្ចិមប្រទេសនៅក្នុងប្រទេសឥណ្ឌូនេស៊ី។> អ៊ីចឹងឯងបានជាខ្ញុំយកសំណួរទាំងអស់នេះមកសួរ។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** <ខ្ញុំយល់ លោកស្រីសាក្សី>នៅមុនឆ្នាំ១៩៧៥ លោកស្រីមិនដែលបានដឹង<អំពីការប្រព្រឹត្តមកលើ>ជនជាតិវៀតណាមទេ។ អ៊ីចឹងមែនទេ?

**ឆ៖** ចាស ខ្ញុំមិនបានដឹងមែន។

**ស៖** ចុះលោកស្រីធ្លាប់<ឮអំពី>ទស្សនាវដ្តី ឬក៏កាសែតដែលគេហៅថា "ទស្សនាវដ្តីទង់បដិវត្ត"។ លោកស្រីដែលឮឈ្មោះទស្សនាវដ្តីនេះទេ?

**ឆ៖** មិនដែលឃើញផង។ ខ្ញុំនៅជនបទឆ្ងាយ មិនដែលឃើញទេ។

**ស៖** ចុះចន្លោះពីឆ្នាំ១៩៧៥ ដល់ ៧៩ លោកស្រីធ្លាប់បានស្តាប់វិទ្យុផ្សាយចេញពីទីក្រុងភ្នំពេញរបស់របបនោះដែរឬទេ?

**ឆ៖** របបនោះកាន់តែស្ងាត់ទៀតហើយ មិនដែលឲ្យប្រជាជនដឹងផង។

[១០:០១:១៥]

**ស៖** ប៉ុន្តែ <ខ្ញុំគិតថា>វិទ្យុផ្សាយសំឡេងពីទីក្រុងភ្នំពេញ ជាវិទ្យុផ្លូវការរបស់របបកម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំយល់ឃើញថាគេអនុញ្ញាតឲ្យស្តាប់ការផ្សាយសំឡេងចេញពីទីក្រុងភ្នំពេញ<នោះ>។ តើលោកស្រីធ្លាប់បានស្តាប់ ការផ្សាយវិទ្យុផ្សាយចេញពីទីក្រុងភ្នំពេញ ឬក៏<លោកស្រីស្គាល់>អ្នកណាម្នាក់ធ្លាប់បានស្តាប់ដែរទេ លោកស្រីដឹងទេ?

**ឆ៖** ចាស ខ្ញុំមិនបានដឹងទេ ដូចខ្ញុំជម្រាបប្រាប់ហើយថាក្នុងគ្រួសារមួយៗគិតតែផ្គត់ផ្គង់កូនៗច្រើនមិនបានទៅគិតការងារនយោបាយអីទេ ដឹងតែពីការប្រឹងរកចិញ្ចឹមកូន ព្រោះកូនច្រើន កូនខ្ញុំដល់ទៅប្រាំបួននាក់ ស្លាប់ពីរនាក់ នៅប្រាំពីរនាក់។ ដូច្នេះ មេគ្រួសារហ្នឹង គឺត្រូវប្រឹងប្រែងគិតតែយ៉ាងម៉េចផ្តល់ជីវភាពឲ្យកូនដែលផុតពីរបបអត់ឃ្លានប្រឹងលូន ប្រឹងក្រាប ដើររក ដូរទិញយកមកទុកផ្គត់ផ្គង់តែកូនទេ មិនបានស្តាប់រឿងអ្វីទាំងអស់។

**ស៖** បាទ ខ្ញុំយល់ហើយលោកស្រីសាក្សី។ អ៊ីចឹង តើត្រឹមត្រូវទេ បើខ្ញុំនិយាយថាបញ្ហាដែលលោកស្រីជួបប្រទះនោះគឺ ដំណើរការរបស់របបកម្ពុជាប្រជាធិបតេយ្យ គឺលោកស្រីដឹងតែអំពីកម្មាភិបាលមូលដ្ឋានរបស់លោកស្រីទេ។ លោកស្រីដឹងថាកម្មាភិបាលមូលដ្ឋានដែលលោកស្រីធ្លាប់ទំនាក់ទំនង និងធ្លាប់និយាយជាមួយហ្នឹង គឺជាកម្មាភិបាលតំណាងឲ្យរបបកម្ពុជាប្រជាធិបតេយ្យ ឬមិនមែនទេ?

**ឆ៖** ជាតំណាងនៅៗក្នុងភូមិខ្ញុំហ្នឹង ជាកម្មាភិបាលនៅ គេថាគ្រប់គ្រងនៅក្នុងភូមិខ្ញុំហ្នឹង។

[១០:០៣:២៥]

**ស៖** ដូច្នេះ ត្រឹមត្រូវទេ បើខ្ញុំនិយាយថានៅពេលនោះ លោកស្រីមិនបានដឹងថាគោលនយោបាយរបស់របបនោះមានគោលនយោបាយអ្វីខ្លះទេ ឬក៏ថាលោកស្រីមិនបានដឹងរបបកម្ពុជាប្រជាធិបតេយ្យ ឬបក្សកុម្មុយនីស្តកម្ពុជាហ្នឹងគឺថាមានការទំនាស់គ្នាជាមួយនឹងវៀតណាមទេឬ?

**ឆ៖** ចាស ត្រឹមត្រូវហើយ ខ្ញុំមិនបានដឹងទេ។

**ស៖** លោកស្រី នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកស្រី លោកស្រីបានយោង<លើអ្វីដែលលោកស្រីហៅថា>៖ "ព្រឹត្តិកាណ៍របស់ សោម ភឹម។" <> និយាយឲ្យចំតែម្តងពាក្យនេះជាភាសាអង់គ្លេសគឺ 00235511, ខ្មែរ00233296, បារាំង 00250600, "ចំពោះខ្ញុំ<ផ្ទាល់ ខ្ញុំ>ត្រូវ<ដកស្ទូង> ហើយខ្ញុំក៏ធ្វើត្រីឆ្អើរ ប្រហុក <កិនស្រូវ ជាន់អង្ករ ទៅតាមរដូវ។ ក្រោយមកប្រហែលមួយឆ្នាំ ឬពីរឆ្នាំ> មានព្រឹត្តិការណ៍<>សោ ភឹម ដែលក្នុងនោះក៏មាន<ទាហានបាក់ទ័ព និងប្រពន្ធអតីតទាហាន> លន់នល់ <ព្រមទាំងអ្នកជាប់និន្នាការ ត្រូវបានប្រមូលទៅខាង>មជ្ឈិម ហើយក៏បាត់ខ្លួនទៅ។"<ខ្ញុំចង់សួរសំណួរជាក់លាក់អំពី>ព្រឹត្តិការណ៍របស់ សោ ភឹម<។ តើ>លោកស្រីចង់និយាយថាម៉េច<ពេលលោកស្រីនិយាយបែបហ្នឹងប្រាប់អ្នកស៊ើបអង្កេត>?

**ឆ៖** ក្រោយពីសភាពការណ៍នៅ ហៅថា សោ ភឹម អង្កាល់ហ្នឹង ប្រជាជន -- អ៎! ន៎ែ កងទ័ពបាក់ទ័ព ដែលរត់មកផ្ទះហ្នឹង គេប្រមូលហៅទៅ។ ហើយអ្នកជាប់និន្នាការអីមក ទាហាននៅទីក្រុងភ្នំពេញ និងប្រជាជនថ្មីអី ក៏គេប្រមូលហៅថាឲ្យទៅរៀនសូត្រ។ ដឹងតែប៉ុណ្ណឹងឯង។

[១០:០៦:០៧]

**ស៖** សោ ភឹម ជានរណា លោកស្រី?

**ឆ៖** ខ្ញុំមិនបានដឹងដែរ ចេះតែឮថា សោ ភឹម ៗ។

**ស៖** លោកស្រីមាននៅចាំអ្វីដែរទេ អំពីការដែលលោកស្រីបានឮឈ្មោះរបស់គាត់នេះ?

**ឆ៖** ឮតំណាលក្នុងភូមិហ្នឹងថា ជំនាន់ សោ ភឹម ហ្នឹងវាក្រឡាប់ចាក់កាលហ្នឹង ចេះតែនាំគ្នាថាត្រឹម សោ ភឹម ហ្នឹងទៅ ប៉ុន្តែមិនដឹងទៅមុខទៀតយ៉ាងម៉េច អត់ដឹង។

**ស៖** លោកស្រីនៅចាំទេ អ្នកភូមិរបស់លោកស្រីនិយាយអ្វីខ្លះដែរអំពី សោ ភឹម?

**ឆ៖** អត់មាននិយាយអីទេ ប្រជាជនអត់បានដឹងទេ តែម៉ាឈុលហ្នឹងហើយទៅស្ងាត់ស្ងៀមទៅ។

**ស៖** លោកស្រីនៅចាំទេ តំបន់ណាមួយនៃភូមិភាគណាមួយ ដែល<>ភូមិលោកស្រីហ្នឹងស្ថិតនៅ<មុនឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩>?

**ផ៖** នៅតំបន់២៤។

**ស៖** ចុះលោកស្រីនៅចាំដែរ នៅតំបន់២៤ ចំណុះឲ្យភូមិភាគណាដែរ?

**ផ៖** ខ្ញុំអត់បានដឹងផង ដឹងតែតំបន់២៤។

[១០:០៨:១៨]

**ស៖** លោកស្រីធ្លាប់ដែលឮសូរបុគ្គលម្នាក់ឈ្មោះ ហេង សំរិន ដែរទេ?

**ផ៖** ឮតែឈ្មោះ មិនបានស្គាល់មុខ។

**ស៖** ចុះឮតែឈ្មោះហ្នឹង លោកស្រីដឹងអ្វីខ្លះដែរអំពីគាត់ អំពីហេង សំរិន នេះពីឆ្នាំ១៩៧៥ ទៅដល់ ៧៩ <ឬក៏ក្រោយមកដែរ ឬទេ>?

**ផ៖** ចាស មិនបានដឹងអ្វីទេ មិនបានដឹងទាំង គ្រាន់តែឮតែឈ្មោះគាត់ តែមិនបានដឹង។

**ស៖** តើលោកស្រីមានដឹងថា មានការប្រយុទ្ធគ្នារវាងកងទ័ព<នៃរបប/រដ្ឋាភិបាល>កម្ពុជាប្រជាធិបតេយ្យ និងកងទ័ពវៀតណាមដែរទេ? ឬក៏ម្យ៉ាងទៀតថា តើលោកស្រីដែលបានស្ដាប់ឮសូរ<> អាវុធផ្ទុះ ការបាញ់បោះដាក់គ្នា ឬក៏បាញ់ផ្លោងកាំភ្លើងធំ ឬក៏ការប្រយុទ្ធគ្នាដោយប្រើរថក្រោះអីដែរទេ រវាងកងទ័ពកម្ពុជាប្រជាធិបតេយ្យជាមួយកងទ័ពវៀតណាម?

**ផ៖** មិនបានឮផង មិនបានដឹងផង។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំហើយលោកស្រី។ បើខ្ញុំយល់មិនច្រឡំទេ លោកស្រីខ្លួនឯងផ្ទាល់មិនដែលធ្លាប់បានឃើញដោយផ្ទាល់ភ្នែកអំពីការសម្លាប់អ្នកណាម្នាក់ទេ។ លោកស្រីមិនដែលបានឃើញគេសម្លាប់អ្នកណាម្នាក់ផ្ទាល់ភ្នែកទេ។ តើត្រឹមត្រូវដែរទេ?

**ផ៖** ចាស ជាការត្រឹមត្រូវ ព្រោះមិនដែលឃើញមែន។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ អស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោង១០កន្លះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុង

បន្ទប់សវនាការនេះនៅវេលាម៉ោង១០កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១១ នាទី ដល់ម៉ោង ១០:៣១ នាទី)*

[១០:៣១:១៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះ ផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ <សូម>គោរពលោកប្រធាន លោក លោកស្រីចៅក្រម។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកស្រី សៅ សាក់ ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន។ ខ្ញុំនឹងសួរសំណួរខ្លីៗមួយចំនួនទៅកាន់លោកស្រី។ សំណួរទី១ គឺពាក់ព័ន្ធទៅនឹងហេតុការណ៍មួយដែលលោកស្រីបានលើកឡើងជាមួយនឹងសហព្រះរាជអាជ្ញារងជាតិ។ លោកស្រីឆ្លើយថា ត្រូវបានគេចាប់ខ្លួនអស់រយៈពេលប្រហែលជាជាង១០ថ្ងៃ ហើយនៅក្នុងពេលដែលលោកស្រីផ្តល់បទសម្ភាសន៍ជូនអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត លោកស្រីបាននិយាយថាគេចាប់ខ្លួនមនុស្សជាច្រើនក្នុងពេលដំណាលគ្នាជាមួយនឹងលោកស្រី។ ហើយលោកស្រីបាននិយាយអំពី យាយ<ចែ>។ លោកស្រីអាចបញ្ជាក់បានទេ អ្នកណាជា យាយ<ចែ> ហ្នឹង ហើយលោកស្រីស្គាល់គាត់តាមរបៀបណា?

ចំពោះអ្នកបកប្រែ ដើម្បីចៀសវាងនូវបញ្ហាបកប្រែឈ្មោះ គឺឈ្មោះហ្នឹងគឺ ចេ <សរសេរតាមភាសាបារាំង> គឺឯកសារ E3/7780។

**លោក គង់ សំអុន៖**

ឈ្មោះ ចែ សូមអរគុណ។

**លោកស្រី សៅ សាក់៖**

**ឆ៖** យាយចែ គេបានហៅទៅជាមួយខ្ញុំមែន។ នៅក្នុងវត្តអន្លង់ទ្រា។

[១០:៣៣:២៧]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ខ្ញុំចង់សួរលោកស្រីថា យាយចែ ហ្នឹងជាអ្នកណា? ហើយលោកស្រីស្គាល់តាមរបៀបណា?

**ឆ៖** យាយចែ ជាប្រជាជននៅភូមិអន្លង់ទ្រា នៅភូមិជាមួយគ្នា។

**ស៖** នៅក្នុងកំណត់ហេតុស្តាប់ចម្លើយលោកស្រី គឺ E3/7780, ERN ជាភាសាបារាំង 0025 0601, ជាភាសាអង់គ្លេសគឺ 00235512, និង ERN ជាភាសាខ្មែរ 00233296។ លោកស្រីបាននិយាយអំពីជន<ពន្ទុ>ដើមរបស់ យាយចែ នេះ។ តើលោកស្រីនៅចាំទេ?

**ឆ៖** គាត់ -- ខ្ញុំមិនបានដឹងប្រវត្តិគាត់ដែរ គាត់ថាគាត់ជនជាតិចាម។ តែនៅក្នុងភូមិខ្ញុំហ្នឹង នៅជាមួយគ្នាយូរហើយ មិនដឹងថាគាត់ជនជាតិចាមផង។ ដល់គាត់ថាជនជាតិចាម នឹកឃើញថាគាត់ឪពុកគាត់ចាម ហើយក៏គេឲ្យគាត់មកវិញមក។

**ស៖** អ៊ីចឹង ពេលនុ៎ង គឺគេដោះលែងគាត់ហ្នឹងក្នុងពេលជាមួយលោកស្រីដែរ មែនទេ?

**ឆ៖** ចាស គេដោះលែងនៅពេលនុ៎ង។

**ស៖** នៅទំព័រដដែល ជាភាសាបារាំង និងទំព័រដដែលជាភាសាអង់គ្លេស ក៏ប៉ុន្តែជាភាសាខ្មែរ គឺ ERN 00233297។ លោកស្រីបានលើកឡើងនូវឈ្មោះកម្មាភិបាលមូលដ្ឋានមួយចំនួន សូមអភ័យទោសផង បើខ្ញុំអានឈ្មោះទៅមិនត្រូវ។ ខ្ញុំសូមផ្តល់ ERN ដើម្បីឲ្យអ្នកបកប្រែតាមខ្ញុំទាន់។ គឺ ERN 0023 3297 គឺឈ្មោះហ្នឹង ឈ្មោះ ម៉ន, កុក, ឆឺយ និង នី ដែលជាកម្មាភិបាលមូលដ្ឋាន។ សំណួរទី១ គឺពាក់ព័ន្ធនឹងឈ្មោះ ម៉ន។ តើ ម៉ន នេះមានតួនាទីជាអ្វីដែរ?

[១០:៣៦:២៣]

**ឆ៖** ម៉ន គាត់ជាប្រធានភូមិនៅភូមិអន្លង់ទ្រា។

**ស៖** ពេលដែលគេចាប់ខ្លួនហ្នឹង ម៉នហ្នឹងនិយាយជាមួយលោកស្រីហ្នឹង ឬក៏យ៉ាងម៉េច ឬក៏មានអ្នកណាផ្សេង?

**ឆ៖** ម៉ន ហ្នឹងបានហៅខ្ញុំទៅនៅវត្ត។ គ្មានអ្នកផ្សេងទេ មានតែ ម៉ន ហ្នឹងម្នាក់។

**ស៖** អ៊ីចឹង គឺពេលហ្នឹង គឺម៉ន ហ្នឹងហើយដែលលោកស្រីបាននិយាយជាមួយហ្នឹង មែនទេ?

**ឆ៖** ចាស មនុស្សឈ្មោះ ម៉ន។

**ស៖** ចុះលោកស្រីស្គាល់មេរបស់ ម៉ន ហ្នឹងទេ?

**ឆ៖** មិនស្គាល់ទេ មេថ្នាក់លើ ស្គាល់ត្រឹមប្រធានឃុំ គឺឈ្មោះ ធើយ។

**ស៖** ចុះ ធើយ ហ្នឹង គាត់មានមុខតំណែងអីឲ្យប្រាកដដែរ?

[១០:៣៧:៥១]

**ឆ៖** គាត់គណៈឃុំព្រែកជ្រៃ។

**ស៖** លោកស្រីក៏បានរៀបរាប់ឈ្មោះ កុក ផងដែរ។ អ៊ីចឹង កុក នេះ មានមុខតំណែងអីដែរ?

**ឆ៖** ប្រធានភូមិដែរ ប្រធានភូមិទី១។ ទី១ ទី២ ជាមួយពូ ម៉ន ហ្នឹង ប្រធានភូមិហ្នឹង ភូមិអន្លង់ទ្រា។

**ស៖** ចុះឈ្មោះចុងក្រោយឈ្មោះ នី នេះ គាត់មានមុខតំណែងអីដែរ?

**ឆ៖** ឈ្មោះ នី ប្រធានឈ្លប។

**ស៖** លោកស្រីបាននិយាយជាច្រើនដងច្រើនសា <ហើយលោកស្រីក៏បាននិយាយពីម្សិលមិញដែរ>ថា លោកស្រីគ្រាន់តែជាអ្នកភូមិធម្មតា ហើយលោកស្រីគិតតែពីធ្វើការងាររបស់លោកស្រី។ ដូច្នេះខ្ញុំអាចនិយាយបានទេថា លោកស្រីមិនបានចូលរួមក្នុងការប្រជុំណាមួយជាមួយ ម៉ន, កុក, ធើយ និង នី នេះទេ?

**ឆ៖** មិនបានរួមប្រជុំកិច្ចការងារផ្សេងៗទេ ប្រជុំតែការងារបង្កបង្កើនផល។ ការងារដកស្ទូង។ ឲ្យយើងជំរុញការងារកសិកម្មហ្នឹង ជំរុញឲ្យបានជួនណា ១តោន -- ១ហិកតា ៣តោន ឡើង៦តោនឯណោះ។

**ស៖** អម្បាញ់មិញនេះ នៅពេលដែលលោកស្រីឆ្លើយទៅនឹងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោកស្រីបាននិយាយថា “ម៉ន ហ្នឹង ប្រហែលជាធ្វើស្ថិតិប្រជាជននៅក្នុងភូមិរបស់លោកស្រី<អំពីជាតិពន្ធុអ្នកទាំងនោះ>”។ ដូច្នេះ ខ្ញុំអាចនិយាយបានថា អ្វីដែលលោកស្រីបានឆ្លើយហ្នឹង គឺគ្រាន់តែជាការស្មានទេ <ដោយ>លោកស្រី<ផ្ទាល់មិនដែលឃើញរបាយការណ៍ទាំងនោះផង ហើយលោកស្រី>មិនដឹងប្រាកដថា<តើ ម៉ន បានបញ្ជូន>ស្ថិតិប្រជាជន<ទាំងអស់នោះឲ្យទៅមេរបស់គាត់

ដែលលោកស្រីមិនស្គាល់។ តើត្រឹមត្រូវទេ>?

**ឆ៖** ចាស ពិតប្រាកដហើយ។

[១០:៤០:១៥]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកស្រីសាក្សី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ខ្ញុំសូមជម្រាបសួរលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ ព្រឹកមិញនេះ លោកស្រីបាននិយាយអំពីការចាប់ជនជាតិវៀតណាមបញ្ជូនទៅស្រុកវិញ។ ខ្ញុំចង់សួរបន្ថែមថា លោកស្រីដឹងពីអ្នកណាៗដែលជាអ្នកនិយាយប្រាប់លោកស្រីថា ចាប់ជនជាតិវៀតណាមទៅស្រុកវិញនោះ? ស្គាល់ឈ្មោះគេទេ?

**លោកស្រី សៅ សាក់៖**

**ឆ៖** មិនមាន ដូចថា មិនមានប្រធានភូមិប្រធានអីណានិយាយប្រាប់ទេ មានតែប្រជាជនយើងស្មានក្នុងចិត្តហ្នឹងថា ហ៊ឺ! បើគេជូនទៅ គេឲ្យទៅប្រទេសវៀតណាម។ គ្រាន់តែដឹងតែប៉ុណ្ណឹងឯង គ្មាននរណានិយាយប្រាប់យើងទេ។

**ស៖** អ្នកស្រីដឹងហ្នឹង ដឹងពីអ្នកណា? អ្នកស្រីអាចចាំឈ្មោះបានទេ? ឬមួយក៏អ្នកស្រីភ្លេច អាចបញ្ជាក់បានទេ?

**ឆ៖** និយាយពីប្រជាជនតៗគ្នាហ្នឹងលោកគ្រូ? មានដូចថា ទៀវមបាយ រួម យាយៗទាំងអស់គ្នាហ្នឹង បងស្រីទាំងអស់គ្នាធ្វើការហ្នឹងចេះតែខ្សឹបខ្សៀវគ្នា ថា ហ៊ឺ! គេជូនប្រជាជនទៅវៀតណាមហើយយើងចេះតែភ័យហើយ។ ហ្នឹងបើតាមដឹងទៅមានតែយាយៗគ្នាឯងដែលទៅធ្វើការជាមួយគ្នាហ្នឹង គ្មានប្រុសៗ ឬកម្មាភិបាលណាអាចនិយាយប្រាប់យើងទេ មានតែ ដូចជា យាយយើត យាយអីហ្នឹង ដែលគាត់ចាស់ៗហ្នឹងនៅក្នុងក្រុមជាមួយគ្នាហ្នឹង ប្រធានក្រុម កូនក្រុមហ្នឹងទៅធ្វើការហ្នឹង ចេះតែពិភាក្សាគ្នាគិតក្រែងអ៊ីចឹង។ អាគេយកទៅ គេយកទៅវៀតណាមហើយ គេឲ្យទៅនៅស្រុកភូមិកំណើតគេវិញ។ ហ្នឹងបើតាមដឹងៗតែពីយាយៗគ្នាឯងហ្នឹង។ គ្មានដឹងពីកម្មាភិបាលណាប្រាប់យើងទេ។

**ស៖** បាទ សូមអរគុណ។ អ្នកស្រីដឹងថានៅពេលណាដែរ? ឆ្នាំណាដែរ? ចាំបានទេ?

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** អំឡុងពីឆ្នាំ៧៥ អំឡុងឆ្នាំ៧៥, ៧៨ ហ្នឹង ព្រោះធ្វើការសមូហភាព យើងធ្វើការសមូហភាពហ្នឹង មកហូបបាយរួមហ្នឹង តាំងពី៧៥ ដល់ ៧៨ ហ្នឹងយើងហូបបាយរួមហើយ បណ្ដើរៗហើយតាមសហករណ៍។

[១០:៤៣:១៨]

**ស៖** បាទ សូមអរគុណ។ មុននេះអំមិញ លោកស្រីឆ្លើយថា ឈ្មោះ នី ជាប្រធានឈ្លប។ លោកស្រីអាចបញ្ជាក់បានទេថា ឈ្មោះ នី ហ្នឹងឈ្លបអី? ជាឈ្លបភូមិ ឈ្លបឃុំ ឬមួយមានឋានៈអី អាចបញ្ជាក់ច្បាស់លាស់បានទេ?

**ឆ៖** ឈ្មោះ នី ហ្នឹងគាត់ឈ្លបភូមិ នៅភូមិខ្ញុំហ្នឹង។

**ស៖** បាទ សូមអរគុណលោកស្រី។

**លោក គង់ សំអុន៖**

លោកប្រធានខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ ហើយអង្គជំនុំជម្រះអរគុណលោកស្រី សៅ សាក់។ សវនាការស្ដាប់សក្ខីកម្មរបស់លោកស្រីក្នុងឋានៈជាសាក្សីបានដល់ទីបញ្ចប់ហើយ។ សក្ខីកម្មរបស់លោកស្រីនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្ដីនេះ។ ហើយវត្តមានរបស់លោកស្រីនៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ លោកស្រីអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកស្រីមានបំណងចង់ទៅបានហើយ។ សូមលោកស្រីមានសុខភាពល្អ ជួបតែសំណាងល្អ ហើយបានសេចក្ដីសុខសេចក្ដីចម្រើន។

មន្ត្រីរដ្ឋបាលតុលាការសម្រុះសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូនសាក្សី សៅ សាក់ វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ ហើយនិងសវនាការបន្តនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី 2-TCW-241។

ហើយបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សីបម្រុងឲ្យចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះ!

*(ដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-886 ចេញពីបន្ទប់សវនាការ)*

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

*(ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-241 ចូលក្នុងបន្ទប់សវនាការ)*

[១០:៤៦:២២]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួរស្តីលោកដើមបណ្តឹងរដ្ឋប្បវេណី តើលោកឈ្មោះអី?

**លោក ជឿង យ៉ាំង ចែត៖**

**ឆ៖** ខ្ញុំឈ្មោះ ជឿង យ៉ាំង ចែត។

**ស៖** លោក ជឿង យ៉ាំង ចែត តើលោកកើតនៅថ្ងៃ ខែ ឆ្នាំណា លោកចាំដែរទេ?

**ឆ៖** ខ្ញុំអត់ចាំទេ លោកប្រធាន។

**ស៖** ឆ្នាំនេះ លោកអាយុប៉ុន្មានហើយ?

**ឆ៖** បីដណ្តប់ បួនដណ្តប់ លោកប្រធាន។

**ស៖** ឆ្នាំនេះ ឥឡូវដល់ឆ្នាំនេះណ៎ះ! តើលោកមានអាយុប៉ុន្មាន? ឥឡូវហ្នឹងណ៎ា លោកមានអាយុប៉ុន្មាន?

**ឆ៖** អាយុ៦៥២ លោកប្រធាន។

**ស៖** អរគុណ លោក ជឿង យ៉ាំង ចែត។ តើលោកមានទីកន្លែងកំណើតនៅទីកន្លែងណាដែរ?

**ឆ៖** ទីកំណត់របស់ខ្ញុំ ភូមិឫស្សីដង្កូច ឃុំព្រៃគ្រី ស្រុកកំពង់លែង។

**ស៖** អរគុណ។ ចុះទីលំនៅសព្វថ្ងៃរបស់លោក តើលោករស់នៅទីកន្លែងណា?

**ឆ៖** ខ្ញុំនៅភូមិកណ្តាល ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង។

**ស៖** តើលោកប្រកបមុខរបរអីសព្វថ្ងៃនេះ?

[១០:៤៨:០០]

**ឆ៖** ខ្ញុំអ្នកកម្មករគេលោកប្រធាន។

**ស៖** បាទ អរគុណ។ ហើយលោក ជឿង យ៉ាំង ចែត សូមលោកបង្អង់បន្តិច។ បានន័យថា ស្តាប់សំណួរ ហើយលោកគិតថាតើសំណួរដែលសួរហ្នឹង គប្បីឆ្លើយតបយ៉ាងដូចម្តេច នោះជាឱកាសមួយដែលដើម្បីឱ្យមានសមត្ថភាពក្នុងការបកប្រែភាសាទៅជាភាសាផ្សេងៗដែលប្រើប្រាស់នៅអ.វ.ត.កនេះ ប្រើប្រាស់ភាសាបី ភាសាខ្មែរ ភាសាអង់គ្លេស ហើយនិងភាសាបារាំង អ៊ីចឹងហើយបានជាមានការ

យឺតបន្តិចដើម្បីទុកលទ្ធភាពឲ្យអ្នកបកប្រែភាសាហ្នឹងបកឲ្យអស់ខ្លឹមសារនៃសំណួរ-ចម្លើយណ៎ះ! តើឪពុកបង្កើតរបស់លោកឈ្មោះអី? ហើយម្ដាយបង្កើតរបស់លោកឈ្មោះអី លោក យាំង ចែត?

**ឆ៖** បាទ លោកប្រធាន ឪពុកខ្ញុំ ជឿង យាំងស្រ៊្វ។ ម៉ែខ្ញុំ មៀង ធីកង។

**ស៖** អរគុណ។ ចុះប្រពន្ធរបស់លោកឈ្មោះអី ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** សព្វថ្ងៃនេះប្រពន្ធខ្ញុំឈ្មោះ មៀង យ៉ាងណយ កូន១១នាក់ លោកប្រធាន។

**ស៖** លោកជឿង យ៉ាំង ចែត នៅក្នុង -- នៅចុងក្រោយនៃសវនាការផ្ដល់ស្ដាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងក្ដីនេះ លោកមានសិទ្ធិថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលកើតមានចំពោះលោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យចាប់ពី១៧ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ៧៩ ប្រសិនបើលោកមានបំណងធ្វើដូច្នេះ។ លោកជឿង យ៉ាំង ចែត តើលោកបានធ្លាប់បានផ្ដល់សក្ខីកម្ម ឬផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៃ អ.វ.ត.ក ដែរឬទេពេលកន្លងមកនេះ?

**ឆ៖** មានលោកប្រធាន មាន ប៉ុន្តែសុំនិយាយអ៊ីចេះ ខ្លះទៅវាចាំ ការណ៍សំខាន់ហ្នឹងចាំខ្លះការណ៍ដែលសំខាន់វាអត់ចាំខ្លះដែរ លោកប្រធាន។

[១០:៥០:១២]

**ស៖** យើងអត់ចង់សួរអ៊ីចឹងទេលោក ចង់ដឹងថាតើលោកធ្លាប់មកផ្ដល់សក្ខីកម្ម ឬក៏លោកបានផ្ដល់សក្ខីកម្មនៅទីកន្លែងណាមួយដល់អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ទៅសួរ ស្ដាប់យកសក្ខីកម្មរបស់លោកដែរឬទេរយៈពេលពីមុនៗកន្លងមកនេះ?

**ឆ៖** មានលោកប្រធាន។ ខាងមេធាវី ខាង សុគង់ មេខ្ញុំ សុគង់ ដល់មកចុងក្រោយ មកសួរសក្ខីកម្មខ្ញុំហ្នឹង ខាង លីម៉ា អ៊ីហ្នឹងលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ អ៊ីចឹងមិនមែនលោកផ្ដល់សក្ខីកម្មជាមួយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទេ បានន័យថាលោកហ្នឹងធ្វើការស្ដាប់ -- ផ្ដល់នូវសក្ខីកម្មមួយចំនួនដល់ទៅមេធាវីការពារក្ដីលោកប៉ុណ្ណោះ។ លោក ជឿង យ៉ាំង ចែត តើអាដែង -- ក្នុងការស្ដាប់សក្ខីកម្ម ជឿង យ៉ាំង ចែត អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង

អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សួរដេញដោលដើម្បីបណ្តឹងរដ្ឋប្បវេណីរូបនេះ មុនភាគីដទៃទៀតនៃរឿងក្តី។ ហើយសូមបញ្ជាក់ថា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងសហព្រះរាជអាជ្ញាមានរយៈពេលពីរវគ្គនៃថ្ងៃសវនាការក្នុងការសួរសាក្សីរូបនេះ។

សូមអញ្ជើញសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[១០:៥១:៥១]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន យើងខ្ញុំសូមអនុញ្ញាតប្រគល់វេទិកានេះជូនទៅមេធាវី លីម៉ា ង្វៀន លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណអង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញលោកស្រីមេធាវី!

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយកញ្ញា លីម៉ា ង្វៀន៖**

**ស៖** លោក ជឿង យ៉ាំង ចែត តើលោកមានជាតិពន្ធុ ឬក៏ជាតិដើមលោកជាវៀតណាមឬទេ?

**លោក ជឿង យ៉ាំង ចែត៖**

**ឆ៖** បាទ ខ្ញុំនៅវៀតណាម វៀតណាម នៅកាលសង្គមនៅហ្នឹង សម័យម៉ែឪខ្ញុំនៅសង្គមហ្នឹងទាំងអស់។

**ស៖** ឪពុកម្តាយរបស់លោកជាជនជាតិវៀតណាម តើអ៊ីចឹងឬទេ?

**ឆ៖** បាទ ត្រូវ។

**ស៖** លោកបានបញ្ជាក់ថា លោកកើតនៅឫស្សីដង្កួច នៅស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង។ តើលោកអាចប្រាប់អង្គតុលាការបានទេ ឪពុកម្តាយរបស់លោកមានស្រុកកំណើតនៅឯណា?

**ឆ៖** បាទ បាន។ ម៉ែឪខ្ញុំកើតលើឫស្សីដង្កួចហ្នឹងដែរ នៅឫស្សីដង្កួចហ្នឹង ឃុំព្រៃគ្រី ហ្នឹងដែរ ស្រុកកំពង់លែងដែរ។ ដល់បានកើតខ្ញុំមក ក៏ឫស្សីដង្កួច ស្រុកកំពង់លែង ដែរ។

[១០:៥៣:២៧]

**ស៖** តើ<លោកនិយាយភាសាអ្វី ពេលធំឡើងនៅ>ក្នុងផ្ទះកាលនោះ<>?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** កាលហ្នឹង ខ្ញុំនៅផ្ទះខ្ញុំ និយាយភាសាវៀតណាមដែរ។ និយាយខ្មែរ បើជួបខ្មែរ និយាយតាមខ្មែរដែរ។

**ស៖** តើលោកនិយាយភាសាអ្វីជាមួយឪពុកម្ដាយរបស់លោក?

**ឆ៖** និយាយភាសាវៀតណាម។

**ស៖** តើឪពុកម្ដាយរបស់លោក គាត់និយាយភាសាខ្មែរដែរឬទេ?

**ឆ៖** ចេះ គាត់ចេះដែរ និយាយពាក្យខ្មែរហ្នឹង បើនៅភូមិខ្មែរជិតគ្នាហ្នឹង និយាយពាក្យខ្មែរដែរ។

**ប្រធានអង្គជំនុំ៖**

មេធាវី នៅពេលដែលសួរចប់សូមបិទក្បាលមីក្រូហ្វូនរបស់មេធាវីផង កុំឱ្យវាសំឡេងខ្ទរគ្នា ទី១, ទី២ គឺសូមឱ្យបង្អង់បន្តិចនៅពេលដែលតាំងសំណួរ កុំញាប់ពេក ព្រោះរង់ចាំអ្នកបកប្រែភាសាឱ្យបកខ្លឹមសារនៃការឆ្លើយតបហ្នឹងឱ្យបានច្បាស់លាស់ឱ្យចប់សព្វគ្រប់។

[១០:៥៤:៥៥]

**កញ្ញា លីម៉ា ង្វៀន៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា លីម៉ា ង្វៀន៖**

**ស៖** តើឪពុកម្ដាយរបស់លោកកម្រិតចេះភាសាខ្មែររបស់គាត់ហ្នឹង កម្រិតម៉េចដែរ ចេះច្រើនឬតិចប៉ុនណា?

**លោក ជឿង យ៉ាំង ចែត៖**

**ឆ៖** ចេះ ៦០ភាគរយ។

**ស៖** តើក្រុមគ្រួសាររបស់លោក តើគោរពតាមប្រពៃណីទំនៀមទម្លាប់វៀតណាមដែរឬទេ?

**ឆ៖** បាទ គោរពតាមប្រពៃណីរបស់វៀតណាមដែរ។

**ស៖** តើសាសនារបស់ជនជាតិវៀតណាមជាអ្វី?

**ឆ៖** ជាថ្ងៃចូលឆ្នាំសែនក្បាលទឹក ហើយតែប៉ុណ្ណឹង។

**ស៖** ហើយវៀតណាមប្រើកាឡង់យេ ប្រើខុសពីខ្មែរ ខុសពីកាឡង់យេបារាំង ថាតើប្រតិទិនឬក៏កាឡង់យេ វៀតណាមហ្នឹងខុសគ្នាដូចម្ដេចដែរ?

**ឆ៖** បាទ បើបារាំងជាមួយវៀតណាម ខុសគ្នាមួយខែ។

**ស៖** តើប្រតិទិន ឬក៏កាឡង់យេ៉ហ្នឹងវាខុសគ្នាដូចម្ដេច ដែលលោកថាខុសមួយខែហ្នឹង<>?

**ឆ៖** ព្រោះបារាំងគេទៅមុនខាងវៀតណាមមួយខែ។

**ស៖** ដូច្នេះ កាលប្រតិទិនរបស់វៀតណាម គឺដូចគ្នាទៅនឹង<ប្រតិទិន>របស់ជនជាតិចិន។ តើអ៊ីចឹងឬទេ?

**ឆ៖** បាទ។

[១០:៥៧:៣៧]

**ស៖** លោកនិយាយថាប្រតិទិនហ្នឹងគឺថាមួយខែខុសគ្នា។ ជាឧទាហរណ៍ប្រសិនបើថ្ងៃនេះ ថ្ងៃទី ០៧ ខែធ្នូ តាមប្រតិទិនរបស់បស្ចិមប្រទេស តើថ្ងៃនេះ តាមប្រតិទិន តាមកាឡង់យេ៉វៀតណាម ចំនឹងថ្ងៃអី ខែអី?

**ឆ៖** បាទ វៀតណាមខែ១០ ថ្ងៃ២៦ របស់វៀតណាម។

**ស៖** អ៊ីចឹងប្រតិទិនវៀតណាមគឺថា កាលបរិច្ឆេទហ្នឹង មុនជាងកាលបរិច្ឆេទ<>របស់បស្ចិមប្រទេស អ៊ីចឹងដែរឬទេ?

**ឆ៖** ក្រោយៗជាងរបស់បារាំង ក្រោយជាងរបស់បារាំងមួយខែហ្នឹង ក្រោយប្រហែលពីរថ្ងៃដែរ ថ្ងៃខុសគ្នា ខែខុសគ្នាមួយថ្ងៃ មួយខែដែរ។

**ស៖** លោក ជឿង យ៉ាំងចែត តើលោកមានបងប្អូនប្រុសឬស្រីដែរឬទេ?

**ឆ៖** បាទ មានបងប្រុស បងស្រីដែរ។

**ស៖** តើត្រឹមត្រូវទេ ថានៅក្នុងឆ្នាំ១៩៧៥ លោកមានបងប្រុសពីរ<នាក់> ហើយមានបងស្រីពីរៗនាក់ ហើយលោកជាកូនពៅគេនៅក្នុងគ្រួសារនោះ?

**ឆ៖** ត្រឹមត្រូវ។ បងប្រុសពីរ បងស្រីពីរ ខ្ញុំមួយហ្នឹងពៅគេ។

**ស៖** នៅឆ្នាំ១៩៧៥ លោកប្រហែលជាអាយុ១៣ ឬ១៤ឆ្នាំ។ តើអ៊ីចឹងឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** តើលោកដឹងដែរឬទេនៅពេលដែលបងប្រុស ឬក៏បងស្រីរបស់លោកហ្នឹងកើតនៅឆ្នាំណា ខែណា? តើលោកនៅចាំដែរឬទេ?

**ឆ៖** កាលហ្នឹងអត់ចាំបាន ខ្ញុំអត់ទាន់ចាំបានទេ។

**ស៖** លោកបានប្រាប់តុលាការអំពី<ឈ្មោះ>ឪពុក ហើយនិង<ឈ្មោះ>ម្ដាយរបស់លោកពីដើម

ហើយ។ ខ្ញុំនឹងនិយាយពី<ឈ្មោះ>បង<បង្កើតលោកវិញម្តង ចាប់ផ្តើមចេញពីបងប្រុសគេបង្អស់>។ តើបងប្រុស<ដែលមានអាយុច្រើនជាងគេ>ហ្នឹង គាត់ឈ្មោះអ្វី?

**ឆ៖** បងទី១ ខ្ញុំហ្នឹង ជឿង យ៉ាំងខួយ, បងទី២ហ្នឹង ជឿង យ៉ាំងឡឺយ, បងទី៤ហ្នឹង ជឿង ធី យៀង, បងទី៥ហ្នឹង ជឿង ធីលិត បន្ទាប់ដល់ខ្ញុំ។

[១១:០១:១៦]

**ស៖** ក្រុមគ្រួសាររបស់លោក<មានជាតិពន្ធុ>ជាជនជាតិវៀតណាម។ តើសមាជិកក្រុមគ្រួសាររបស់លោកណាម្នាក់មានសញ្ជាតិជាវៀតណាមដែរឬទេ?

**ឆ៖** មានជីដូនជីតាហ្នឹងវៀតណាមដែរហ្នឹង តែមិនបានបងប្អូនខ្ញុំតែបានប្រាំនាក់ទេ។

**ស៖** តើសមាជិកក្រុមគ្រួសាររបស់លោកណាម្នាក់ គឺថាមានសញ្ជាតិជាជនជាតិវៀតណាម ជាសញ្ជាតិដូចថាកាន់អត្តសញ្ញាណប័ណ្ណ ឬក៏ឯកសារអីជាជនជាតិវៀតណាមដែរឬទេ?

**ឆ៖** អង្កាល់ហ្នឹងមិនទាន់គ្រប់អាយុបានបងខ្ញុំបានពីរនាក់ គ្រប់អាយុហ្នឹងចូលបាន អង្កាល់ហ្នឹង និយាយៗរឿងសំបុត្រហ្នឹង និយាយឡាំងតាយហ្នឹង សំបុត្រឡាំងតាយ ប្រើអាហ្នឹងអង្កាល់សង្គមនិយមហ្នឹង។

**ស៖** ខ្ញុំនឹងចូលទៅដល់បញ្ហាអំពីទីកន្លែងដែលលោករស់នៅ លោកកើតនៅក្នុងឬស្សីជង្គួច–ភូមិឬស្សីជង្គួច។ តើរយៈពេលប៉ុន្មានដែលក្រុមគ្រួសារលោករស់នៅក្នុងភូមិនេះ?

**ឆ៖** អង្កាល់ខ្ញុំនៅនឹងឆ្នាំ បើ៧៥ហ្នឹងបានខ្ញុំមកកំពង់ឆ្នាំង ភូមិកណ្តាលហ្នឹង មកពីខ្ញុំនៅឬស្សី-ជង្គួចហ្នឹងវាយូរឆ្នាំណាស់ហើយ។ ដល់សម័យខ្មែរក្រហមហ្នឹងធ្វើបាបបានរត់មកជិតកំពង់ឆ្នាំង នៅ។

[១១:០៣:២៤]

**ស៖** សូមលោកពន្យល់អំពីក្រុមគ្រួសាររបស់លោកដែលថា ខ្មែរក្រហមធ្វើបាបដូចម្តេចខ្លះ <> នៅក្នុងភូមិឬស្សីជង្គួចនេះ?

**ឆ៖** គេថា ដូចថាធ្វើបាបប្រជាជនហ្នឹងដូចថា ឈប់នៅហ្នឹង ថាបើនៅនឹងទៀតសម្លាប់ចោលទាំងអស់ហ្នឹងអត់មានឲ្យសល់មួយទេ។ បានអីចឹងគេបានប្រជាជនគេរត់មកកំពង់ឆ្នាំងទាំងអស់ ខ្ញុំក៏រត់តាមគេកំពង់ឆ្នាំងហ្នឹង។

**ស៖** តើលោកចាំអំពី<>ចំនួនប្រជាជននៅភូមិឬស្សីជង្គួចទេ ថាតើមានគ្រួសារវៀតណាមប៉ុន្មានគ្រួសារ? គ្រួសារខ្មែរមានប៉ុន្មានជាដើម?

**ឆ៖** បើគ្រួសារយៀកណាមនោះជាង៣០គ្រួសារទេ បើខ្មែរនោះច្រើនដែរនៅភូមិគេច្រើនដែរ។ ខ្ញុំចាំមិនបានរឿងខ្មែរ។

**ស៖** នៅពេលដែលគ្រួសាររបស់លោកចេញពីភូមិឫស្សីជង្គួចទៅ<ភូមិកណ្តាល> តើមានក្រុមគ្រួសារផ្សេងចាកចេញពីភូមិហ្នឹងជាមួយគ្នាដែរឬទេ?

[១១:០៥:០២]

**ឆ៖** មកទាំងអស់គ្នាកំពង់ឆ្នាំងហ្នឹង មកភូមិកណ្តាលនៅទាំងអស់គ្នាហ្នឹង ជុំវិញទាំងអស់ ទាំងចាម ទាំងខ្មែរ ទាំងវៀតណាម។

**ស៖** ខាងដើមលោកនិយាយថា គេប្រាប់ថា បើសិនជាលោក<បន្ត>នៅភូមិ<ហ្នឹង> គេនឹងសម្លាប់ចោលទាំងអស់។ សូមលោកពន្យល់ប្រាប់តុលាការ ថាតើអ្នកណាប្រាប់លោកពាក្យនេះ ហើយគេនិយាយទៅអ្នកណាខ្លះ<>?

**ឆ៖** កាលហ្នឹងមានណា មានត្រឹមតាពាងហ្នឹង។ តាហ្នឹងគាត់កាន់ក្តាប់ខាងស្រុកកំពង់លែង។

**ស៖** ឥឡូវនេះនៅក្នុងរបបខ្មែរក្រហម នៅក្នុងស្រុកំពង់លែងក៏គេហៅថាស្រុក១៨ដែរ តើអ៊ីចឹងដែរឬទេលោកដើមបណ្តឹងរដ្ឋប្បវេណី?

**ឆ៖** បាទ។

**ស៖** តើលោកនៅចាំអំពីកាលបរិច្ឆេទ ឬក៏ខែឆ្នាំដែលគ្រួសាររបស់លោកបានប្តូរទីតាំងពីភូមិឫស្សីជង្គួចទៅភូមិកណ្តាល? តើលោកនៅចាំថាខែណាទេ?

**ឆ៖** ខ្ញុំអត់ចាំខែទេ ប៉ុន្តែខ្ញុំចាំថា៧៥ហ្នឹង ខ្ញុំមកកំពង់ឆ្នាំង ខ្ញុំនៅហ្នឹងប្រហែលមួយខែជាងហ្នឹងបានខ្មែរក្រហមជម្លៀសខ្ញុំទៅដារ។

**ស៖** តើនៅក្នុងខែដែលលោកទៅដល់នោះ នៅភូមិកណ្តាលហ្នឹង គេឲ្យធ្វើអី?

**ឆ៖** ខ្ញុំក៏ទៅរកត្រីរកអីហ្នឹង ធ្វើកម្មករគេហ្នឹង។

**ស៖** លោកនិយាយថា គេបានជម្លៀសលោកទៅភូមិដារ <>សូមលោកប្រាប់តុលាការ ថាតើឪពុកម្តាយរបស់លោកជាអ្នកៗសម្រេច<>ចេញពីភូមិកណ្តាលទៅភូមិដារ ឬក៏គេបង្ខំឲ្យពួកគាត់ទៅទីនោះទេ?

**ឆ៖** ហ្នឹងគេបង្ខំបណ្តោយហ្នឹង គេថាគេស្រែកឡើងមួយម៉ាត់ថា “ជ័យយោ! សម្តេចឪ!” ផ្ទះណានៅដុតចោល លើគោកទៅតាមលើគោក ទឹកនៅនឹងទឹក។ គេអត់ឲ្យ ទឹកឡើងលើគោកមិនបានដែរ

វាគោកចូលទឹកក៏មិនបានដែរ។ អ៊ីចឹងទឹកនៅនឹងទឹក គេដេញទៅស្រុកកំពង់លែងហ្នឹងហើយ ទៅចូលកន្លែងដារហ្នឹង។

[១១:០៨:២០]

**ស៖** សូមលោក<>រៀបរាប់ថាតើនៅពេលដែលគេបង្ខំឲ្យចាកចេញទៅភូមិដារហ្នឹង តើមានហេតុការណ៍អីខ្លះដែលលោកបានចងចាំ?

**ឆ៖** គេឲ្យដឹកទៅដារហ្នឹង គេឲ្យថាគេធ្វើតាមក្រុម។ គេឲ្យថាក្រុមណាទៅធ្វើត្រីឲ្យគេ ធ្វើដំណើរឡើងលើគោក គេហៅទាំងឈ្មោះឡើងតែម្តង ព្រោះស៊ីញ៉េតាមគ្រួសារហ្នឹង គេហៅថាគ្រួសារណាឡើងលើគោក ឡើងទៅ គ្រួសារណាអត់ឡើងលើគោក អត់។

**ស៖** តើមានគ្រួសារប៉ុន្មានគ្រួសារដែលគេបង្ខំឲ្យចេញពីភូមិកណ្តាលទៅភូមិដារនៅពេលនោះ?

**ឆ៖** ខ្ញុំចងចាំមិនបាន ច្រើនណាស់ ប្រហែល១០០០គ្រួសារជាងអីណោះ ច្រើនណាស់។

**ស៖** តើនៅចាំដែរឬទេ ថាតើ<មានសមាសភាពជាតិពន្ធុ១.០០០>គ្រួសារ<ត្រូវបានគេជម្លៀសចេញ? តើលោកដឹងដែរទេ>ថា<ក្នុងចំណោមពួកគេ> តើមានក្រុមគ្រួសារខ្មែរប៉ុន្មានគ្រួសារ គ្រួសារវៀតណាមប៉ុន្មានគ្រួសារជាដើម?

**ឆ៖** ព្រោះទៅហ្នឹងវាច្រើនដែលគេដេញទេ រត់ទៅដឹងហើយ យើងរាប់ទៅប៉ុន្មានគ្រួសារ ដឹងប៉ុន្មានគ្រួសារ យើងចាំថាច្រើនប្រហែលជាង១០០០គ្រួសារអី ទាំងខ្មែរទាំងយួន។

**ស៖** តើលោកនៅចាំដែរឬទេ ថាតើមានគ្រួសារខ្មែរនិងគ្រួសារវៀតណាមហ្នឹង គ្រួសារវៀតណាមច្រើនជាងឬ <នៅកន្លែងហ្នឹង>?

**ឆ៖** ប្រហែលវៀតណាមច្រើនជាង។

**ស៖** ដូច្នេះ ថាតើភូមិដារ នៅឆ្ងាយប៉ុន្មានពីភូមិកណ្តាល?

**ឆ៖** ប្រហែល១៥គីឡូដីទេ ជិតចូល២០គីឡូអីហ្នឹង។

**ស៖** ហើយប្រជាជនដែលគេបញ្ជូនទៅភូមិដារហ្នឹង តើប្រជាជនវៀតណាមគេឲ្យរស់នៅលាយឡំជាមួយប្រជាជនខ្មែរ ឬក៏បំបែកជាពីរផ្នែក ឬក៏យ៉ាងណាដែរ?

[១១:១១:០២]

**ឆ៖** ខាងក្រុមរបស់ខ្ញុំ បែកជាក្រុមសុទ្ធជាវៀតណាម។ បើក្រុមគេខ្លះ មានខ្មែរខ្លះនិងមានវៀត-ណាមខ្លះ។ ក្រុមខ្ញុំហ្នឹង ក្រុមខាងតាពាងហ្នឹង សុទ្ធហ្នុង។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** តើអ្នកណាជាអ្នកទទួលខុសត្រូវជាប្រធានភូមិដារ?

**ឆ៖** ប្រធានភូមិដារហ្នឹង ខ្ញុំអត់ចូលចាំបានទេ។ ខ្ញុំអត់ដឹងបានទេ។ បើតាពាង ខ្ញុំដឹងហ្នុង មេគេទាំងអស់នៅហ្នឹងហ្នុង នៅស្រុកកំពង់លែងហ្នឹងហ្នុង។

**ស៖** លោកបញ្ជាក់ថា មានឈ្មោះ តាពាង តើគាត់ជាប្រធានភូមិ ឬក៏ជាប្រធានឃុំដារ?

**ឆ៖** គាត់ខាងប្រធានអាពត។

**ស៖** ឥឡូវនេះ ភូមិដារ តើស្ថិតនៅក្នុងស្រុក១៨ហ្នឹងដែរទេ?

**ឆ៖** ភូមិដារហ្នឹង ស្រុក១៨ដែរ។

[១១:១២:៣២]

**ស៖** សូមលោកប្រាប់តុលាការ ថាតើភូមិដារហ្នឹង ស្ថិតនៅទីតាំងកន្លែងណា? តើនៅនឹងភ្នំ ឬក៏នៅកន្លែងណា រៀបរាប់ពីទីកន្លែងភូមិដារ?

**ឆ៖** ភូមិដារ នៅភ្នំ។ នៅភ្នំហ្នឹង វាទៅខាងកើតវិញ ទៅភ្នំកង្កែប បានទៅច្រណូក។ បើយើងទៅ ចុះក្រោមមក ដារហ្នឹង ចូលក្រោម គេហៅស្រុកកំពង់លែង ឥឡូវ។ ចូលកំពង់លែង។

**ស៖** តើជីវភាពរស់នៅ ហើយនិងលក្ខណៈធ្វើការងារហ្នឹង វាធ្ងន់ ឬស្រាលយ៉ាងដូចម្ដេចនៅភ្នំកង្កែបនោះ?

**ឆ៖** បាទ ខ្ញុំនៅភ្នំកង្កែបហ្នឹង យកគ្រួសារខ្ញុំ ទាំងបង ទាំងស្រី បងស្រី បងប្រុសខ្ញុំទាំងអស់ ទាំងម៉ែឪខ្ញុំ ទៅចិតគល់ឈើ ខ្ញុំនៅផ្ទះយាមរោងហ្នឹង។ ចិតគល់ឈើរាល់ថ្ងៃ ព្រលឹមឡើងឲ្យបបរមួយចាន ថ្ងៃបបរមួយចាន ល្ងាចបបរមួយចាន លាយត្រកួនទៀត។

**ស៖** តើគេឲ្យធ្វើការអ្វីខ្លះ នៅភ្នំ នៅកន្លែងភ្នំនោះ?

**ឆ៖** ឲ្យខ្ញុំចិតគល់ឈើ ដាំដំឡូងមីហ្នឹង។

**ស៖** ឥឡូវនេះ តើក្រុមគ្រួសាររបស់លោកហ្នឹង រស់នៅភូមិដារ នៅភ្នំកង្កែបហ្នឹង អស់រយៈពេលប៉ុន្មាន មុននឹងគេយកពួកគាត់ទៅសម្លាប់ហ្នឹង?

**ឆ៖** មួយខែជាង។

**ស៖** នៅពេលដែលក្រុមគ្រួសាររបស់លោកនៅភ្នំនោះ តើគេតែងតែសង្ស័យ ឬក៏គិតថា ពេលណាមួយគេនឹងយកមនុស្សទាំងអស់នៅក្នុងគ្រួសារទៅសម្លាប់ តើធ្លាប់បានសង្ស័យ ឬគិតឃើញអ៊ីចឹងទេ?

ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**ឆ៖** អត់បានគិតអ៊ីចឹងទេ។ អត់បានគិតឃើញថាសម្លាប់មុនអ៊ីចឹង បើថាដឹងងាប់មុនអ៊ីចឹង ប្រហែលពួនទៅព្រៃ រត់ទៅខ្លាខាំងាប់ក៏ស្រួលចិត្តដែរ កុំវាយកពូថៅវ៉ៃលើក្បាល ដំបងហ្នឹងវ៉ៃលើក្បាល។

**សៈ** លោក ជឿង យ៉ាំងថែត ខ្ញុំចង់ឱ្យលោករៀបរាប់ឱ្យបានពិស្តារ ឱ្យលម្អិតអំពីហេតុការណ៍<ទាំងឡាយ>ដែលគេយកក្រុមគ្រួសាររបស់លោកទៅសម្លាប់ចាប់ផ្តើមពីដំបូង<។ សូមលោក>ប្រាប់តុលាការ<មកមើល៍ពី>កាលបរិច្ឆេទថ្ងៃខែឆ្នាំណាដែលគេប្រមូលសមាជិកក្រុមគ្រួសាររបស់លោក ដើម្បីយកទៅសម្លាប់ចោលនោះ? សូមលោកគិត ហើយនិងចំណាយពេលសមស្របតាមដែលលោកអាចរៀបរាប់លម្អិតបាន។

**ឆ៖** បាទ ម៉ែឪខ្ញុំហ្នឹងទៅជិត ឈហ្នឹងដើបមិនរួចទៀត ពុកខ្ញុំហ្នឹងគ្រុនឈឺគ្រុនផង ខ្ញុំក៏គ្រុនដែរ។ ពេលអ៊ីចឹងទៅ ព្រលឹមឡើងស្អែកហ្នឹងគាត់មកដល់ផ្ទះ មកប្រាំបីនាក់ កាំភ្លើងប្រាំបីដើម ពូថៅមួយដើម ពីងពង់មួយដើម សុំស្នើពុកខ្ញុំទៅមុន ស្នើចេញពីផុតផ្ទះ ចង ម៉ែខ្ញុំសន្លប់នៅនឹងផ្ទះហ្នឹង ហើយហៅម្នាក់មួយៗមកចងទាំងអស់ ចងខ្សែគោផង មិនចងខ្សែខ្មៅយើងទេ។ ដល់ពេលរួច ចងមនុស្សអ៊ីចឹងមួយៗទៅ ដល់ពេលយកចងមួយខ្សែតែម្តង ចងមួយខ្សែទាញទៅបណ្តោយ។

**សៈ** ដូច្នេះ នៅព្រឹកនោះ <តើ>សមាជិកក្រុមគ្រួសារទាំងអស់គ្នានៅផ្ទះជាមួយគ្នានៅពេលដែលមនុស្សប្រាំបីនាក់មកហៅឪពុករបស់លោកទៅ <>?

[១១:១៦:០៦]

**ឆ៖** បាទ នៅជុំទាំងអស់ហ្នឹង ម៉ោងប្រាំបីព្រឹកហ្នឹង។

**សៈ** សូមលោករៀបរាប់អំពីមនុស្សទាំងប្រាំបីនាក់ ថាតើពួកគេហ្នឹងមកពីណា? ហើយពួកគេស្លៀកពាក់អ្វីខ្លះ<>?

**ឆ៖** ក្រុមតាពាងមកតែម្តង ពាក់ខោអាវខ្មៅ យកក្រមាចងក។

**សៈ** តើពួកគេមានកាន់អាវុធអ្វីដែរទេពេលនោះ?

**ឆ៖** ពេលហ្នឹងកាំភ្លើងប្រាំបីដើម ប្រាំបីនាក់ហ្នឹង ប្រាំបីដើមកាំភ្លើង គ្រប់ដៃ ពូថៅមួយ ពីងពុងមួយ។

**សៈ** សូមលោករៀបរាប់ប្រាប់តុលាការ ថាតើពួកគេធ្វើដូចម្តេចចំពោះឪពុករបស់លោក<ក្រោយ>ពេលដែលគេ<ហៅគាត់>ចេញពីផ្ទះទៅ<>?

**ឆ៖** គេយកទៅដល់ជិតគោលដៅរណ្តៅគេសម្លាប់ចោលហ្នឹង គេចងនៅព្រៃប្រហែល១០០

ម៉ែត្រ ចងម៉ុហ្នឹងហ្នុង។ យកឪពុកខ្ញុំចេញមករណ្ដៅហ្នឹងវ៉ៃ ខ្ញុំអត់ឃើញវ៉ៃងាប់ទេ ប៉ុន្តែដល់ខ្ញុំទៅដល់រណ្ដៅ ឃើញម៉ែឪខ្ញុំនៅរណ្ដៅទាំងអស់។ ទាំងបង បងប្រុសបងស្រីខ្ញុំនៅរណ្ដៅទាំងអស់។

**ស៖** លោកបាននិយាយខាងដើមថា បុរសទាំងអស់នោះ<>បានចាប់ឪពុករបស់លោកចង ហើយក៏បាន<ចង>សមាជិក<គ្រួសាររបស់លោកដូចគ្នាដែរ។ តើលោកអាចពិពណ៌នាពី>របៀប<ដែលគេចងពួកគាត់នោះបានទេ?>

**ឆ៖** បាទ យកឪខ្ញុំចងស្លាបអ៊ីចឹង ចងអ៊ីចឹងហ្នុង ចងខ្សែគោចងអ៊ីចឹង ហើយបងខ្ញុំស្រីក៏ចងអ៊ីចឹង បងប្រុសក៏ចងអ៊ីចឹងទាំងអស់។ ហើយចងម្នាក់មួយខ្សែតែមួយទេ ដោះវិញចងទាំងអស់តែហ្នុង ទាំងអស់គ្នាហ្នឹងទាញមួយខ្សែហ្នឹងទៅតែហ្នុង ចូលព្រៃទៅ។

[១១:១៩:៤៦]

**ស៖** ដូច្នេះ តើពួកគេបានចង ចងម្នាក់ៗដាច់ពីគ្នា ឬក៏គេចងម្នាក់ៗហើយគេចងភ្ជាប់មួយខ្សែជាមួយៗគ្នា ឬក៏យ៉ាងម៉េច?

**ឆ៖** ចងៗម្នាក់ៗដាច់គ្នាមែន ប៉ុន្តែដល់គេយកទៅចងមួយខ្សែហ្នុង គេទាញទៅមួយខ្សែហ្នុង វាអត់ឲ្យអ្នកណារត់ចេញមួយទេ។

**ស៖** នៅថ្ងៃ<កើតហេតុនោះ> តើពួកគេធ្វើ<>ដូចគ្នា<ទៅ>នឹងក្រុមគ្រួសារ<>ផ្សេងទៀត?

**ឆ៖** អ្នកផ្សេងហ្នឹង ខ្ញុំបើថាអ្នកណាមានកម្លាំងទៅធ្វើតាមទៅមុខទៀតទៅ បើអ្នកណាអត់មានកម្លាំងគេយកវ៉ៃចោល ខ្ញុំក៏មិនដឹងដែរ កាលហ្នឹងខ្ញុំ ពីព្រោះខ្ញុំ គាត់វ៉ៃខ្ញុំបីខ្នងពូថៅលើក្បាលខ្ញុំ ឥឡូវនេះបាក់ឆ្អឹងមួយ បានខ្ញុំចងចាំមិនបានក្នុងខ្លួនខ្ញុំ ខ្ញុំឈឺចាប់ខ្ញុំណាស់។

**ស៖** ឥឡូវយើងចង់ត្រឡប់ទៅអ្វីដែលកើតឡើងនៅក្រៅ<ផ្ទះ>ក្រុមគ្រួសាររបស់លោក។ តើលោកបាន<ឃើញ>ពួកខ្មែរក្រហមបានយកសមាជិកក្រុមគ្រួសារណាផ្សេងទៀត ដែរទេ<នៅថ្ងៃហ្នឹង>?

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន <ខ្ញុំសូមជំទាស់ទៅនឹងការប្រើពាក្យ>"ខ្មែរក្រហម"<។> យើងត្រូវប្រើពាក្យឲ្យជាក់លាក់ <ហើយមេធាវីត្រូវជៀសវាងប្រើពាក្យ "ខ្មែរក្រហម" ជាពិសេស នៅពេលយើងនិយាយហេតុការណ៍>ក្នុងឆ្នាំ១៩៧៥<>។<ពេលហ្នឹង "ខ្មែរក្រហម" មិនទាន់ធ្វើអ្វីកើតទេ។ នេះជាសកម្មភាពរូបវន្ត ដែល>មេធាវី<សួរ ដូច្នេះ សាក្សីគួរពិពណ៌នាអំពីបុគ្គល ជាជាងសមាសភាពមួយដែលហៅថា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

"ខ្មែរក្រហម" នេះ>។

[១១:២២:០២]

**សួរដោយកញ្ញា លីម៉ា ង្វៀន៖**

**ស៖** លោក ជឿង យ៉ាំងចែត លោកនិយាយថាមានកម្មាភិបាលប្រាំបីរូប ដែលមកដល់ក្រុមគ្រួសាររបស់លោកព្រឹកហ្នឹង តើលោកបានឃើញអ្នកទាំងប្រាំបីនាក់នេះ <>ប្រព្រឹត្តទៅលើក្រុមគ្រួសារផ្សេងទៀត<ដូចពួកគេធ្វើលើ>គ្រួសាររបស់លោកដែរឬទេ?

**លោក ជឿង យ៉ាំង ចែត៖**

**ឆ៖** ថ្ងៃហ្នឹង ម៉ោងប្រាំបីហ្នឹង ចងនៅគ្រួសារហ្នឹងអែបផ្ទះខ្ញុំដែរហ្នឹង ប្ដីប្រពន្ធពីរនាក់ កូនពីរនាក់យកទៅហ្នឹង មួយខ្សែដែរ បួននាក់ហ្នឹង។

**ស៖** តើក្រុមគ្រួសារមួយនោះជា<គ្រួសារមានជាតិពន្ធុ>វៀតណាម<ឬ>?

**ឆ៖** បាទ ជនជាតិវៀតណាមដែរ។

**ស៖** តើ<គេចាប់ចង>ក្រុមគ្រួសារ<ហ្នឹង ក្នុងពេលតែមួយ ដូចដែលគេបានធ្វើនឹង>ក្រុមគ្រួសាររបស់លោកដែរឬទេ?

**ឆ៖** បាទ ដូចគ្នាហ្នឹង។

**ស៖** លោកបានជម្រាបតុលាការខាងដើមថា កម្មាភិបាលប្រាំបីនាក់នេះ <បន្ទាប់មក បានបណ្ដើរូបលោក>ចម្ងាយប្រហែលជា<មួយគីឡូ>ម៉ែត្រ<ទៅកាន់កន្លែងមួយផ្សេងទៀត។ តើលោកអាច>រៀបរាប់<ទីកន្លែងដែលគេបានបញ្ជូនលោកបានទេ?>

[១១:២៣:៤០]

**ឆ៖** ដូចថាយកទៅពីផ្ទះខ្ញុំទៅហ្នឹងចូលព្រៃហ្នឹងជាង១០០០ម៉ែត្រហើយ ជាង១គីឡូដីហើយ។ វាមកជិតរណ្ដៅហ្នឹងចងទាំងអស់ហ្នឹងអ៊ីចឹង នៅជិតរណ្ដៅហ្នឹងប្រហែល១០០ម៉ែត្រនៅទៅពីរណ្ដៅទៅហ្នឹង។ ហើយមកយកម្នាក់ម្ដងៗៗអ៊ីចឹង យកចេញមកវៃក្បាលម្នាក់ម្ដងៗអ៊ីចឹងទៅ។

**ស៖** នៅពេលដែលដើរចម្ងាយ១០០ម៉ែត្រនោះ តើកម្មាភិបាលនោះបាននិយាយទៅរកលោក<ឬក្រុមគ្រួសារលោក ឬគ្រួសារអ្នកផ្សេង>អ្វីខ្លះ<ដែរទេ>?

**ឆ៖** អត់ទេ មានតែ បើកម្មាភិបាលហ្នឹងបួននាក់នៅយាមនៅ ក្រុមមិនទាន់វៃក្បាលចោលនៅព្រៃហ្នឹងបួននាក់ នៅបួននាក់ហ្នឹងនាំទៅវៃម្នាក់ម្ដងៗអ៊ីចឹងទៅ នៅរណ្ដៅ។

**ស៖** សូមលោករៀបរាប់អំពីរណ្ដៅហ្នឹង តើរណ្ដៅហ្នឹងទំហំប៉ុនណា រាងវាយ៉ាងម៉េច ជូនតុលាការឲ្យបានជ្រាបផង?

**ឆ៖** បាទ មួយរណ្ដៅហ្នឹងពី -- វាទទឹងអ៊ីចឹង៣ម៉ែត្រ បណ្ដោយអ៊ីចឹង២,៥ម៉ែត្រ ហើយជម្រៅអ៊ីចឹង១,៥ម៉ែត្រ។

**ស៖** តើកម្មាភិបាលទាំងអស់នោះធ្វើដូចម្ដេចនៅពេលដែលទៅដល់រណ្ដៅនោះ?

**ឆ៖** នៅពេលរណ្ដៅហ្នឹងយកទៅ ដូចខ្ញុំជម្រាបអំមិញអ៊ីចឹងថា យកម្នាក់ម្ដងៗសម្លាប់ចោលហ្នឹង ម្នាក់ម្ដងវាយក្បាលរួចស្រាយខ្សែចេញ រុញចូលរណ្ដៅហ្នឹង ស្រាយខ្សែចេញរុញចូលរណ្ដៅហ្នឹងៗ ដល់ពេលខ្ញុំហ្នឹង គាត់យកមក ឲ្យខ្ញុំលុតជង្គង់ ខ្ញុំលុតជង្គង់រួច គាត់ចាប់ជើងខ្ញុំ គាត់ទាញទៅឲ្យដួលក្បាលចូលទៅនឹងដី ហើយយកដៃស្ទាបលើក្បាលខ្ញុំ យកពូថៅតូចហ្នឹង វាយមកលើក្បាលខ្ញុំបីខ្នងពូថៅ។

[១១:២៦:០៧]

**ស៖** តើនៅក្នុងសមាជិកក្រុមគ្រួសាររបស់លោក លោកជាមនុស្សចុងក្រោយដែលគេប្រាប់ថាឲ្យលុតជង្គង់នៅមាត់រណ្ដៅនោះ<?>

**ឆ៖** កាលខ្ញុំចុងក្រោយហ្នឹង វាយខ្ញុំចុងក្រោយហ្នឹង ទាំងប្រាំបីនាក់ទៅហ្នុង គេវាយរួចគេថាខ្ញុំងាប់ហើយ គេស្រាយខ្សែចេញមក គេរុញខ្ញុំចូលរណ្ដៅហ្នឹង គេទៅវិញទៅ។

**ស៖** នៅពេលដែលដល់ពេលលោកដែលគេបង្គាប់ឲ្យលោកលុតជង្គង់ហ្នឹង តើលោកមើលទៅក្នុងរណ្ដៅឃើញមានអ្វីខ្លះ?

**ឆ៖** ខាងប្អូននាក់ហ្នឹងខ្ញុំអត់ឃើញ ឃើញតែប្រហែលម៉ែឪខ្ញុំ បងប្អូនខ្ញុំសង្កត់ពីលើអ៊ីចឹងមិនដឹងបើថារណ្ដៅហ្នឹងពេញតែម្ដង ទាំងម៉ែ ទាំងបង ទាំងឪខ្ញុំទាំងអស់នៅរណ្ដៅហ្នឹង ខ្ញុំឃើញច្បាស់លាស់ពីព្រោះខ្ញុំចុងក្រោយគេ។

**ស៖** តើលោកបានឃើញសាកសពសមាជិកក្រុមគ្រួសារផ្សេងទៀតនៅក្នុងរណ្ដៅហ្នឹងទេ ក្រៅពីសាកសពសមាជិកក្រុមគ្រួសាររបស់លោកនៅថ្ងៃនោះ?

**ឆ៖** ខ្ញុំអត់ឃើញ ខ្ញុំខ្លាចតែម៉ែឪខ្ញុំកប់ពីលើ ខ្ញុំមិនឃើញទេ ហើយដល់ទៅដល់ហ្នឹង ខ្ញុំដូចថាងងឹតភ្នែក ខ្ញុំមើលអត់ឃើញអីទៀតទេ ថាមើលមិនឃើញហ្នុង ព្រោះងងឹងភ្នែកអស់។

[១១:២៨:១០]

**ស៖** <លោកបានរៀបរាប់>ពីខាងដើម<មកថា ដល់ពេលវេនលោក> គេ<>បង្ខំ<លោក>

ឲ្យអង្គុយលុតជង្គង់<នៅមាត់រណ្តៅ> ហើយ<កម្មាភិបាលម្នាក់ក្នុងចំណោមពួកគេ បាន>ទាញជើងលោក<ពីក្រោយ>។ <សូមលោកជួយពិពណ៌នាបន្តិចមើល៍?>

**ឆ៖** លើកទម្លាក់ អំមិញខ្ញុំនិយាយដែរ ខ្ញុំថា ឲ្យខ្ញុំលុតជង្គង់ ឲ្យខ្ញុំលុតជង្គង់ចុះទៅ។ ដល់ពេលខ្ញុំលុតជង្គង់រួចហើយ ចាប់ជើងខ្ញុំទាញទៅក្រោយ បានខ្ញុំដួលក្បាលខ្ញុំផ្ងាកទៅមុខ ទៅមុខអ៊ីចឹង បានយកដៃគេស្ទាបលើក្បាលខ្ញុំ បានយកពូថៅគេវាយលើក្បាលខ្ញុំ បីខ្នងពូថៅ រួចបានគេស្រាយខ្សែចេញ រួចរុញខ្ញុំចូលរណ្តៅ។

**សៈ** លោកបាននិយាយខាងដើមថា នៅពេលដែលគេទម្លាក់ចូលទៅក្នុងរណ្តៅ លោកក៏សន្លប់ ហើយក្រោយមក តើលោកដឹងខ្លួនវិញ គឺប្រហែលជាពេលណា ម៉ោងប៉ុន្មានតាមលោកចាំ?

**ឆ៖** ខ្ញុំចាំម៉ោងខ្ញុំ ប្រហែលម៉ោងបួនល្ងាច ហើយម៉ោងបួនល្ងាចហ្នឹងឡើងក៏មិនរួចដែរ កខ្ញុំហើមដូចហើមកក្របីបាត់ហើយ ដើរក៏មិនរួចដែរ ដើរក្បាលធ្ងន់ជាងគេទៅមុខទាំងអស់ បានខ្ញុំខំទៅដល់ចូលមកឃុំជើងគ្រោះហ្នឹង ដើរមកទាំងយប់ទាំងថ្ងៃ ដើរកាត់ព្រៃ ទាំងយប់ទាំងថ្ងៃ ដើរទៅមក យប់ហ្នឹងដើរមក ដល់ឃុំជើងគ្រោះ បានចូលផ្ទះតាលី។

[១១:២៩:៥៨]

**សៈ** ឥឡូវនេះ នៅពេលដែលមានហេតុការណ៍ទាំងអស់នេះ លោកមានអាយុប្រហែលតែ ១៣ ឬ ១៤ ឆ្នាំទេ។ សូមលោកជម្រាបតុលាការមើលថាតើៗលោកបានគិត ហើយលោកមានអារម្មណ៍ដូចម្តេចនៅពេលដែលលោកបានដឹងខ្លួនឡើងវិញនៅក្នុងរណ្តៅសាកសពរួមហ្នឹង តើក្នុងចិត្តរបស់លោកហ្នឹងដូចម្តេចពេលនោះ?

**ឆ៖** ពេលនុ៎ងខ្ញុំនិយាយត្រង់ ខ្ញុំអត់គិតអីទៀតទេ ពីងាប់ហើយវារស់វិញ អត់ទាន់គិតអីទៀតទេ។ បើងងឹតមុខហើយ ដើរទាំងយប់ទាំងថ្ងៃ ល្ងាចហ្នឹង ហើយដល់មួយយប់ហ្នឹងដល់ភូមិគេ អាចុងក្រោយ អាភូមិគេនៅនឹងទឹកហ្នឹង បានខាងវៀតណាមគេនៅនឹងទឹក មួយទូកតាលីហ្នឹង ខ្ញុំនៅហ្នឹង។ សុំស្នាក់នៅគេជួយខ្ញុំដែរ គេជួយធ្វើបុណ្យឲ្យខ្ញុំ គេយកៗអី យកថ្នាំបារាំងអីគេហ្នឹង គេព្យាបាលខ្ញុំ អត់មានថ្នាំ កាលហ្នឹងអត់មានថ្នាំគ្រាប់អីផឹក ស្លឹកឈើអ៊ីចឹង។

**សៈ** តើ<>តាលី ដែលជួយ<សង្គ្រោះ>លោកហ្នឹង <ជានរណាដែរ>?

**ឆ៖** ខាងក្រុម តាពាង ហ្នឹង ឲ្យតាលីហ្នឹងនៅនឹងទឹកហ្នឹងគាត់ធ្វើត្រី ប្រហុក ធ្វើត្រីងៀតអី ឲ្យក្រុមតាពាងហ្នឹង បានខ្ញុំទៅដល់ក្រុមហ្នឹង ខ្ញុំថាម៉ែឪខ្ញុំងាប់អស់ហើយ នៅសល់តែម្នាក់ខ្ញុំទេ ខ្ញុំឥឡូវរឬស

លើក្បាលខ្ញុំប៉ុណ្ណឹងទៀត។ ហើយគាត់ជួយខ្ញុំ គាត់យកទៅបេះស្លឹកឈើអីហ្នឹង គាត់ដាក់ឲ្យខ្ញុំ លើក្បាលខ្ញុំហ្នឹង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាក ចាប់ពីពេលនេះទៅរហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវ-នាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្ម ក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងមួយកន្លះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៣២ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:៣៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុនពេលផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ អង្គជំនុំជម្រះសាលាដំបូងធ្វើការផ្សព្វផ្សាយនូវសេចក្តីសម្រេចផ្ទាល់មាត់អំពីសាក្សីថ្មីពាក់ព័ន្ធនឹងការប្រព្រឹត្តទៅលើក្រុមគោលដៅជាក់លាក់ចំពោះជនជាតិវៀតណាមជូនភាគីពាក់ព័ន្ធបានជ្រាប។ ដើម្បីផ្តល់ការជូនដំណឹងទៅភាគីឲ្យបានទាន់ពេលវេលានៅពេលនេះ អង្គជំនុំជម្រះចេញសេចក្តីសម្រេចផ្ទាល់មាត់ពាក់ព័ន្ធនឹងផ្នែកមួយនៃឯកសារ E319/36 តាមសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសូមឲ្យកោះហៅសាក្សីបន្ថែមចំនួនបួនរូប និងសូមឲ្យទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរមួយចំនួនដែលមាននៅក្នុងឧបសម្ព័ន្ធ(ញ) ភ្ជាប់នឹងសំណើសុំខាងលើគឺឯកសារ E319/36.2។

[១៣:៣៤:៥៦]

ភាគីបានឆ្លើយតបទៅនឹងសំណើនេះដោយផ្ទាល់មាត់នៅក្នុងសវនាការកាលពីថ្ងៃ០១ ខែធ្នូ ឆ្នាំ២០១៥។ សេចក្តីសម្រេចផ្ទាល់មាត់នេះគឺពាក់ព័ន្ធតែទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលសូមឱ្យកោះហៅសាក្សីសម្រាប់ការប្រព្រឹត្តទៅលើជនជាតិវៀតណាមដែលការិយាល័យសហចៅក្រមស៊ើបអង្កេតបានស្តាប់ចម្លើយនៅក្នុងសំណុំរឿង០០៣ និងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សូមឱ្យទទួលយកកំណត់ហេតុចំនួនបី ក្នុងចំណោមកំណត់ហេតុនៃការស្តាប់ចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សីដែលទើបដែលត្រូវបានដាក់បង្ហាញនាពេលថ្មីៗនេះពីសំណុំរឿង០០៣ គឺឯកសារ E319/23.3.44, E319/23.3.46 និងឯកសារ E319/23.3.47 ដូចបានលើកឡើងនៅក្នុងកថាខណ្ឌ ១១ និង១២ នៃសំណើសុំរបស់សហព្រះរាជអាជ្ញាអន្តរជាតិ។

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីគាំទ្រចំពោះសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ។ មេធាវីការពារក្តី នួន ជា បានលើកឡើងថា ប្រសិនបើអង្គជំនុំជម្រះយល់ព្រមតាមសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សាក្សីដែលត្រូវបានស្នើទាំងនោះគួរតែត្រូវបានកោះហៅឱ្យមកផ្តល់សក្ខីកម្មតែនៅពេលដែលការស៊ើបអង្កេតនៅក្នុងសំណុំរឿង០០៣ ត្រូវបានបញ្ចប់។ ហើយត្រូវទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយលាយលក្ខណ៍អក្សររបស់សាក្សីទាំងអស់ដែលទើបតែត្រូវបានដាក់បង្ហាញនាពេលថ្មីៗនេះរួមទាំងឯកសារ E319/23.3.45 និង E319/23.3.48 ផងដែរ។

[១៣:៣៦:៥៤]

គ្មានភាគីណាមួយបដិសេធចំពោះការទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរចំនួនពីរបន្ថែមទៀតនោះទេ។ មេធាវីការពារក្តី ខៀវ សំផន បដិសេធទៅនឹងការកោះហៅសាក្សីដែលបានស្នើឡើងដោយលើកឡើងថា ដោយសារតែសហព្រះរាជអាជ្ញាបានស្គាល់សាក្សីរូបនេះក្នុងអំឡុងស៊ើបអង្កេតសំណុំរឿង០០២។ ហេតុដូច្នេះសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិមានភាពយឺតយ៉ាវ។

មេធាវីការពារក្តី ខៀវ សំផន ក៏បានលើកឡើងថា មិនត្រូវទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរណាមួយដែលសហព្រះរាជអាជ្ញាអន្តរជាតិបានស្នើឡើងធ្វើជាភស្តុតាងនៅមុនពេលបញ្ចប់ការស៊ើបអង្កេតសំណុំរឿង០០៣ឡើយ។

អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា បើទោះជាមជ្ឈមណ្ឌលឯកសារកម្ពុជាបានសម្ភាសជាមួយនឹងសាក្សីដែលបានស្នើសុំនោះក្នុងឆ្នាំ២០០៧ក៏ដោយ ក៏ការសម្ភាសនោះមានព័ត៌មានតិចតួចពាក់

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ព័ន្ធទៅនឹងការប្រព្រឹត្តទៅលើជនជាតិវៀតណាមដែរ ឯកសារ E3/9092។ កំណត់ហេតុនៃការស្ដាប់ចម្លើយជាលាយលក្ខណ៍អក្សរដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិទើបតែដាក់បង្ហាញនាពេលថ្មីៗនេះមានព័ត៌មានលម្អិតអំពីបញ្ហានេះ។

អង្គជំនុំជម្រះជឿជាក់ថាភស្តុតាងស្ដីពីការប្រព្រឹត្តទៅលើជនជាតិវៀតណាមនេះមិនមានអាទិភាពនៅមុនពេលការបើកជំនុំជម្រះក្ដីនេះទេ។ ហេតុដូច្នេះសំណើសុំនេះបានបំពេញនូវលក្ខខណ្ឌកំណត់ដោយវិធាន៨៧(៣) និង៨៧(៤) នៃវិធានផ្ទៃក្នុង។

អាស្រ័យហេតុនេះ អង្គជំនុំជម្រះយល់ព្រមតាមសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំកោះហៅសាក្សីដែលត្រូវបានស្នើរូបនេះ និងកំណត់រហស្សនាម 2-TCW-1000 ទៅឲ្យសាក្សីរូបនេះ។ អង្គជំនុំជម្រះក៏ទទួលយកកំណត់ហេតុនៃការស្ដាប់ចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សី 2-TCW-1000 នេះធ្វើជាឯកសារភស្តុតាងដូចដែលសហព្រះរាជអាជ្ញាអន្តរជាតិ និងមេធាវីការពារក្ដីបានស្នើឡើងគឺឯកសារE319/23.3.44, E319/23.3.45, E319/23.3.46, E319/23.3.47 និងE319/23.3.48។

[១៣:៣៩:៤៥]

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទទួលសិទ្ធិមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណី។

កុំអាល់ទាន់លោកស្រីមេធាវី! សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណើសូមការបំភ្លឺ<មួយ ទៅកាន់>មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី <ដោយខ្ញុំយោង>ទៅឯកសារ E3/5631 នៅទំព័រទី១ ជាបទសម្ភាសន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះជាមួយមេធាវីបច្ចុប្បន្ននេះឯង ដែលបានសម្ភាសដើមបណ្ដឹង។ នៅក្នុងអត្ថបទភាសាអង់គ្លេស ហើយទាក់ទងទៅនឹងសំណួរមួយចំនួន<មុន>ដែលមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីសួរទៅគាត់ទាក់ទងទៅនឹងប្រតិទិនវៀតណាម<ខុសគ្នាពី>ប្រតិទិនបស្ចិមប្រទេសនោះ<។ ក្នុងសំណៅភាសា> អង់គ្លេសគឺ 00678292, ខ្មែរ 0089753<(ស៊ីក) , ជាភាសាបារាំង 00898372 ។> ខ្ញុំសូមអានជាភាសាអង់គ្លេស៖ "នៅម៉ោងប្រាំបួន នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គឺថាថ្ងៃទី<១៧ ខែ>មីនា តាមប្រតិទិន<បស្ចិមលោក" បន្ទាប់មក> គាត់និយាយអំពីរឿងរ៉ាវ<អំពី>ការកាប់សម្លាប់បងប្អូនក្រុម

គ្រួសារគាត់។ អ៊ីចឹងមើលចំណុចនេះគឺថា<ទំនង>ប្រតិទិនបស្ចិមប្រទេស<មុន>មួយខែ<។ ហើយនៅទំព័របន្ទាប់ ដូចជានិយាយរឿងអីផ្សេងទៀត។ ប៉ុន្តែសំណួរគឺពាក់ព័ន្ធ ដោយសារនៅថ្ងៃទី១៧ ខែមីនា ឆ្នាំ ១៩៧៥ កាលបរិច្ឆេទនេះ ស្ថិតនៅ>ក្រៅវិសាលភាព<យុត្តាធិការ>នៃ<តុលាការ>នេះ<ហើយ>។ <ទាក់ទងនឹងសំណួរដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសួរផងដែរ ខ្ញុំគិតថា វាជាប្រយោជន៍ដល់ភាគីទាំងអស់ បើសិនវាជាកំហុស>ជាភាសាអង់គ្លេស នៅក្នុងឯកសារ <E3/5631>។

[១៣:៤២:១៥]

**កញ្ញា លីម៉ា ង្វៀន៖**

<លោក លោកស្រីចៅក្រម> នៅពេលខ្ញុំសួរពីខាងដើម ភាពខុសគ្នារវាងប្រតិទិនវៀតណាម ហើយនិងប្រតិទិនបស្ចិមប្រទេសនោះ <ដែលប្រតិទិនហ្នឹងដូចគ្នានឹងប្រតិទិនខ្មែរដែរ ហើយ>ដើមបណ្តឹងបានបញ្ជាក់<>បំភ្លឺ<លើ>ចំណុចដែលមេធាវី<ការពារក្តី>បានលើកអំមិញហ្នឹង<តើ គឺថា> ថ្ងៃនេះគឺទី០៧ ធ្នូ ប៉ុន្តែបើតាមប្រតិទិនវៀតណាមវិញ គឺ<២៦> ខែតុលា។ អ៊ីចឹងគឺថា យើងឃើញថា ប្រតិទិនវៀតណាមហ្នឹង <ដើរមុន>មួយខែ<ធៀបនឹង>ប្រតិទិនបស្ចិមប្រទេស ហើយយើង<បានស្នើថា ចម្លើយតបនេះបញ្ជាក់ឲ្យច្បាស់ពីភាពមិនស៊ីសង្វាក់គ្នានៅក្នុងព័ត៌មានបន្ថែមនោះ ផ្នែកទាំងពីរនៃចម្លើយហ្នឹង ឬថា>មានការភ័ន្តច្រឡំដែលកើតឡើងនៅក្នុងការពន្យល់ នៅក្នុងផ្នែកទី១ ទំព័រទី១ <ក្នុង> ព័ត៌មានបន្ថែមនេះ ហើយនៅទំព័រទី២ ដែល<សំដៅលើ>កាលបរិច្ឆេទ<>ខុសគ្នា។ ខ្ញុំសូមជម្រាបតុលាការថា សំណួរនោះគឺត្រូវបានបំភ្លឺរួចហើយ <តាមចម្លើយតបមុននេះបន្តិចរបស់>ដើមបណ្តឹងរដ្ឋប្បវេណី<>។

[១៣:៤៣:៣៣]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនច្បាស់ថាខ្ញុំយល់ត្រូវត្រូវទេ ប៉ុន្តែ<បញ្ហានោះគឺថា តើ>គាត់<កំពុងតែ>រៀបរាប់ពីហេតុការណ៍មុនយុត្តាធិការតុលាការនេះ<កំណត់> គឺថាមុនថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ <ឬក៏គាត់កំពុងតែរៀបរាប់អំពីព្រឹត្តិការណ៍នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥?។> ដូច្នេះ <ខ្ញុំគិតថា> តុលាការគប្បីតែកត់សម្គាល់អំពីថាការអះអាង<អំពីការ>កាប់សម្លាប់សមាជិកក្រុមគ្រួសាររបស់គាត់ហ្នឹង<កើតឡើងនៅមុនពេលយុត្តាធិការតុលាការ ឬយ៉ាងណា។ ខ្ញុំគិតថា នេះជាសំណួរតែមួយគត់ ដែលពាក់ព័ន្ធ>។

**ប្រធានអង្គជំនុំ៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បាទ ហើយមុននឹងផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី អំមិញនេះឃើញថាការបកប្រែជាភាសាខ្មែរ ឧទាហរណ៍ថ្ងៃនេះថ្ងៃ០៧ ខែធ្នូ ឆ្នាំ២០១៥ ហើយបើសិនជាមួយឆ្នាំក្រោយ ម៉េចក៏ទៅខែតុលាវិញ? ឬក៏បកប្រែខុស ឬក៏យ៉ាងម៉េច? វាទៅជាខែតុលា វាបញ្ច្រាស់វិញ។ បានន័យថាវាលឿនជាង ព្រោះហ្នឹងខែប្រតិទិនរបស់វៀតណាមហ្នឹង វាត្រូវលឿនជាងខាងបស្ចិមប្រទេសរហូតដល់ពីរខែឯណោះ វារំលងខែ១១ទៅទៀត។ បញ្ជាក់បញ្ជាចំណុចនេះឲ្យបានច្បាស់លាស់បន្តិចមើល៍ មុននឹងផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខអន្តរជាតិ។

**កញ្ញា លីម៉ា ង្វៀន៖**

ជម្រាបលោកប្រធាន តាមខ្ញុំយល់ខាងប្រតិទិនវៀតណាមហ្នឹងគឺប្រហាក់ប្រហែលទៅនឹងប្រតិទិនតាមចន្ទគតិ<ដែរ>។ អ៊ីចឹង <វាអាស្រ័យតាមព្រះចន្ទ ឬដំណើរព្រះចន្ទ នៅពេលដែលព្រះចន្ទពេញបូណ៌មី ឬដោយគន្លងខុសគ្នា>ទៅតាម<ដំណើរ>ចន្ទគតិ។ នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណី <លោក ជឿង យ៉ាំង ចែត>និយាយថា ថ្ងៃនេះគឺថ្ងៃទី២៦ តុលា តាមប្រតិទិនវៀតណាម គឺថា មានន័យថា មួយខែមុនប្រតិទិនបស្ចិមប្រទេស។

[១៣:៤៥:៥០]

**សួរដោយចៅក្រម ក្លូឌា ហ្វេនស៍៖**

**ស៖** ខ្ញុំសួរបន្ថែមទៅដើមបណ្តឹងរដ្ឋប្បវេណី។ ប្រសិនបើលោក ពេលដែលលោកឆ្លើយចម្លើយទាក់ទងទៅនឹងកាលបរិច្ឆេទថ្ងៃនេះ គឺសំណួរដែលទាក់ទងទៅនឹងកាលបរិច្ឆេទ ឆ្នាំ១៩៧៥-១៩៧៩ តើលោកឆ្លើយហ្នឹង គឺឆ្លើយប្រើកាលប្រតិទិនវៀតណាម ឬក៏ប្រតិទិនបស្ចិមប្រទេស? តើលោកស្តាប់សំណួរខ្ញុំយល់ទេ? លោកដើមបណ្តឹងរដ្ឋប្បវេណី?

**លោក ជឿង យ៉ាំង ចែត៖**

**ឆ៖** ខ្ញុំយល់ហើយ ប៉ុន្តែថាសុំយកជាគោលខាងវៀតណាមហ្នឹង បើនិយាយទៅ បើខាងខ្មែរថាខែចូលឆ្នាំខ្មែរ ចូលឆ្នាំខ្មែរប្រាំពីរថ្ងៃហ្នឹងដើម្បីជូនកម្លាំងពួកខ្ញុំហ្នឹងទៅជើងគ្រោះ-ដារហ្នឹងហើយ។ ខ្ញុំនៅដារ ខែបើថាខែរបស់វៀតណាមវិញ គឺខែ៤ របស់វៀតណាម។ យើងចូលខែ៣ ខ្មែរយើងចូលឆ្នាំចិន -- អ៊ំ! ចូលឆ្នាំខ្មែរ បានឡើងពីនោះមួយខែរួចបានគេសម្លាប់ម៉ែឪបងប្អូនខ្ញុំ។

**ស៖** ប៉ុន្តែទូទៅជាងហ្នឹងបន្តិច ហើយគេនឹងសួរសំណួរទៅលោក ជាកាលបរិច្ឆេទ<>។ តើនៅ

ពេល<គេសួរ>លោក<>អំពីកាលបរិច្ឆេទ<>ឆ្នាំ១៩៧៥ ដល់ ៧៩ <>តើលោកនឹងឆ្លើយសំណួរផ្អែកទៅលើប្រតិទិនវៀតណាម ឬក៏ប្រតិទិនបស្ចិមប្រទេស? បានន័យថាកាឡង់យ៉េបែបវៀតណាម ឬក៏បែបបរទេស ពេលដែលលោកឆ្លើយនោះណា? <ដូច្នេះ យើងអាចដឹងថា តើលោកឆ្លើយមួយណាតាមទស្សនៈរបស់លោក ដើម្បីឲ្យយើងអាចយល់បាន។>

**ឆ៖** បាទ ខ្ញុំនិយាយកាឡង់យ៉េរបស់វៀតណាមហ្នឹងហើយ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើភាគីទាំងអស់យល់ច្បាស់ហើយដែរ គឺថាប្រតិទិនវៀតណាមនិងបស្ចិមប្រទេស<? ខ្ញុំឮ មួយ ឬពីរខែ។>

**លោក វ៉ិចទ័រ កូប៉េ៖**

<សូមទោស ដែលខ្ញុំកាត់ លោកស្រីចៅក្រម ហ្វេនស៍។ សំណួរគឺថា> នេះគឺជាចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ដែលបានកត់ត្រាឡើងដោយមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី។ <ត្រង់នេះសរសេរថា> នៅថ្ងៃ១៧ ខែមេសា ១៩៧៥ គឺថា ថ្ងៃទី<១៧> មីនា ១៩៧៥។ ហើយអ៊ីចឹង <វាប្រាដកជាកំហុសក្នុងឯកសារនោះមែនហើយ។ ប្រសិនបើ កញ្ញា ង៉ៀន ព្រមទទួលស្គាល់កំហុសក្នុងសំណៅជាលាយលក្ខណ៍អក្សរក្នុងឯកសារនោះ វានឹងមិនមានបញ្ហាអ្វីទេ។>

[១៣:៤៩:០០]

**កញ្ញា លីម៉ា ង៉ៀន៖**

<លោក លោកស្រីចៅក្រម ដើម្បីឲ្យកាន់តែច្បាស់លាស់នោះ សូមយោងទៅលើ>ឯកសារ <E3/5631> គឺថាមាន<ឯកសារ>យោង<ពីរដែលមាន>កាលបរិច្ឆេទពីរខុសគ្នា។ បន្ទាប់<មក តាមឯកសារទាំងនោះ ឃើញមាន>ការ<>យោងទៅប្រតិទិនវៀតណាមនោះ<។ ខ្ញុំត្រូវ>បញ្ជាក់ឲ្យច្បាស់។<លោក លោកស្រីចៅក្រម> ខ្ញុំមិនមែនជាសាក្សីក្នុងករណីនេះទេ គឺ<ខ្ញុំមិនត្រូវផ្ដល់>ភស្តុតាង<អីដែរ ដោយភស្តុតាងត្រូវចេញពីលោក>ដើមបណ្ដឹងរដ្ឋប្បវេណី។ <ឥឡូវនេះ> នៅក្នុង<>ឯកសារយោង<ទីមួយ> ERN<ភាសាអង់គ្លេស> 00678292, បារាំង <00898372>, ខ្មែរ 00897513 ដែលមាននិយាយថា “នៅម៉ោងប្រាំបួន នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ (ថ្ងៃទី១៧ មីនា ឆ្នាំ១៩៧៥ តាមកាឡង់យ៉េ<បស្ចិមប្រទេស)” ដែលបញ្ជាក់ថា ប្រតិទិនបស្ចិមប្រទេសដើរមុនប្រតិទិនវៀតណាមមួយខែ>។ ប៉ុន្តែទោះជាយ៉ាងណាក្ដី នៅទំព័រ<បន្ទាប់>ទៀតនៅក្នុងអង់គ្លេស <00678293, ខ្មែរ

00897515, បារាំង 00-->

**អ្នកបកប្រែ៖**

លោកប្រធាន សូមអនុញ្ញាតឲ្យគាត់ហៅ ERN ម្ដងទៀត។ អ្នកបកប្រែតាមអត់ទាន់ បាទ។

**ប្រធានអង្គជំនុំ៖**

មេធាវីនិយាយម្ដងទៀត។ ហើយនិយាយញាប់ អ្នកបកប្រែបកមិនទាន់ទេ។ ហើយមិនដឹងជាគោលបំណងនៃការនិយាយនេះយ៉ាងម៉េចទេ ព្រោះដើម្បីប្រយោជន៍ស្ដាប់ច្បាស់លាស់នៅក្នុងដំណើរការសក្ដិកម្ម មិនមែននិយាយតែម្នាក់ឯងទេ។ យើងដូចនិយាយរំឭកពីព្រឹកម្ដងហើយ លើបញ្ហានិយាយញាប់នេះ ហើយទុកឃ្លា ពេលវេលាសម្រាប់អ្នកបកប្រែផង។

**កញ្ញា លីម៉ា ង្វៀន៖**

នៅទំព័រទី២ ជាភាសាអង់គ្លេស ឯកសារ ខ្ញុំជាអាន ERN បារាំង <00898373 សរសេរថា៖> "នៅខែមិថុនា ឆ្នាំ១៩៧៨ <(ស៊ីក)" បន្ទាប់មក មានបើកវង់ក្រចកសរសេរថា> "(ខែកក្កដា ឆ្នាំ១៩៧៥ អនុលោមតាមប្រតិទិនបស្ចិមប្រទេស)។" ដូច្នេះ នៅក្នុងកំណត់ត្រា <យើងឃើញ>ហើយ<ថា>វា<មិន>ស្របគ្នា<លើ>កាលបរិច្ឆេទវៀតណាម <និង>កាលបរិច្ឆេទ<>ប្រតិទិនបស្ចិមប្រទេស<នោះទេ។ វាខុស>គ្នា<> គឺថាទំព័រទី១ គឺថាប្រតិទិនបស្ចិមប្រទេស <>មុនកាលបរិច្ឆេទប្រតិទិនវៀតណាម<តែនៅ>ទំព័រទី២ <>ដាក់ថាប្រតិទិន<បស្ចិម ដើរក្រោយប្រតិទិនវៀតណាមទៅវិញ។ ត្រង់នេះបណ្ដាលឲ្យមានភាពច្របូកច្របល់គ្នា។ លោក លោកស្រីចៅក្រម ខ្ញុំសូមលើកឡើងថា លោកដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់នេះ បានឆ្លើយនឹងសំណួរនេះរួចហើយ ជាពិសេស នៅពេលគេសួរគាត់ថា "តើកាលបរិច្ឆេទថ្ងៃនេះជាថ្ងៃអ្វី ធៀបទៅនឹង>កាលបរិច្ឆេទ<ប្រតិទិន>វៀតណាម<?" ហើយគាត់បានបញ្ជាក់ហើយថា កាលបរិច្ឆេទវៀតណាម ដើរមុន>កាលបរិច្ឆេទនៅក្នុងប្រតិទិនបស្ចិមប្រទេស។

[១៣:៥២:១២]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៥៤:00]

**ប្រធានអង្គជំនុំ៖**

បាទ មានបញ្ហាអី? បាទ អញ្ជើញតទៅទៀត! ចាំស្ដាប់ទៀតមើល តើវាមានបញ្ហាអី លើបញ្ហាកាលបរិច្ឆេទនេះ?

**ស្ទួរដោយកញ្ញា លីម៉ា ង្វៀន៖**

អរគុណលោកប្រធាន។

**ស្ទួរដោយកញ្ញា លីម៉ា ង្វៀន៖**

**ស៖** លោក ជឿង យ៉ាំង ចែត ឥឡូវមុនពេលសម្រាក លោកបានរៀបរាប់ប្រាប់តុលាការពីការកាប់សម្លាប់ដ៏ឃោរឃៅ ដ៏រន្ធត់លើសមាជិកក្រុមគ្រួសាររបស់លោក <ក្នុងហ្នឹងមានតែលោកម្នាក់ទេដែលរួចជីវិត>។ ហើយលោកនិយាយថា លោកអាច<>គេចខ្លួនចេញពីរណ្ដៅ<សពរួម> ហើយទៅរស់នៅផ្ទះ តាលី ដែលជួយលោក។ តើលោកនៅផ្ទះ តាលី ហ្នឹងយូរប៉ុន្មាន? គឺនៅស្នាក់នៅហ្នឹងប៉ុន្មានរយៈពេលប៉ុនណា?

**លោក ជឿង យ៉ាំង ចែត៖**

**ឆ៖** បាទ ខ្ញុំស្នាក់នៅផ្ទះ តាលី ហ្នឹងមួយខែ បានខ្ញុំ គេមកហ្នឹងគេតំណាងគេឲ្យគាត់ហ្នឹងដែលថា ខាងនៅនឹងទឹកហ្នឹងបានចេញដំណើរទៅប្រទេសយួនវិញ។ បានអ៊ីចឹងគាត់ថា កុំអាលអ្នែងលាក់ខ្លួននៅត្រង់ណាសិនទៅ អ្នែងចាំអញធ្វើសំបុត្រចំណាំឲ្យអ្នែង ចាំចូលមកអញឲ្យអ្នែងដោយសារទៅមួយកំណាត់ផ្លូវ។ បានខ្ញុំចូល លាក់ខ្លួននៅឃុំនឹងគេដែរ បានពីរអាទិត្យ បានគេ បានតាលី ហ្នឹងគាត់បានចេញដំណើរទៅ។ មួយខែក្រោយហ្នឹងបានចេញដំណើរទៅស្រុកយួន។

**ស៖** នៅពេល តាលី ចាកចេញទៅវៀតណាម តើលោកបានទៅជាមួយគាត់ទេ?

**ឆ៖** បាទ ខ្ញុំនៅ កាលហ្នឹងគាត់ឲ្យដំណឹងខ្ញុំដឹងហ្នឹង ខ្ញុំចេញពីព្រៃមក។ ខ្ញុំចូលនៅឃ្លុបទូកគាត់នៅឃ្លុបទូកគាត់ ពីព្រោះគ្រួសារគាត់ហ្នឹងបានតែប្រាំបីនាក់ទេ គេឲ្យចេញដំណើរទៅហ្នឹងគឺគេទៅមើលតាមគ្រួសារហ្នឹង ប្រាំបីនាក់ អត់បានឈ្មោះណាចូលទូកបានទៀតទេ។ អ៊ីចឹងចូលទៅឃ្លុបទូកហ្នឹងផុតពីកន្លែងគេឆែកឆេរគ្រួសារតាលីហ្នឹង រួចបានខ្ញុំបានឡើងលើអង្គុយបានលើទូកវិញ។

**ស៖** នេះតើនេះគឺគេធ្វើឡើងតាមនយោបាយរបស់ខ្មែរក្រហម ឬក៏នយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ ឬបក្សកុម្មុយនីស្តកម្ពុជាក្នុងការបញ្ជូនទៅវៀតណាមវិញ ឬក៏ធ្វើយ៉ាងម៉េចឲ្យអស់ជនជាតិវៀតណាមពីកម្ពុជា? តើលោកបានដឹងពីរឿងនេះទេ?

**ឆ៖** បាទ រឿងហ្នឹងខ្ញុំអត់ដឹងទេ ទើបដឹងដំណឹងរបស់ខាង តាលី ហ្នឹង ក្រុមតាលីហ្នឹងគាត់ជូនទៅហ្នឹង ខាងអង្គការគេដូរអំបិល ដូរអង្ករអីជាមួយខាងវៀតណាមហ្នឹង តែប៉ុណ្ណឹង ខ្ញុំដឹងតែប៉ុណ្ណឹង ខ្ញុំដោយសារគាត់ទៅហ្នឹង ជួយលាក់ខ្លួនតែប៉ុណ្ណឹង។

**ស៖** តើទូកហ្នឹងជាទូករបស់ តាលី ឬ<>?

**ឆ៖** ទូកហ្នឹងទូករបស់ តាលី។ ខ្ញុំដើរទៅដល់មាត់ទន្លេបួនមុខហ្នឹង ខ្ញុំបានឡើងសាឡង់។

[១៣:៥៨:០០]

**ស៖** ឥឡូវនេះ ត្រឡប់មកព័ត៌មានលម្អិតអំពីទូករបស់ តាលី <លោកប្រាប់>ថាសមាជិកក្រុមគ្រួសារគាត់មានគ្នាប្រាំបីនាក់ ហើយ<>លោក<ក៏ថា លោកទៅដែរ តែនៅកន្លែងផ្សេង គឺលោកទៅ>លាក់ខ្លួននៅឃ្លុបរបស់ទូក។ តើមានហេតុផលអីដែលលោកត្រូវលាក់ខ្លួនក្នុងឃ្លុបអ៊ីចឹង?

**ឆ៖** ពីព្រោះគេឲ្យមួយក្រុមរបស់តាលីហ្នឹងមួយគ្រួសារ តែមួយក្រុមគាត់ហ្នឹងបានទៅប្រទេសវៀតណាមហ្នឹង។ បានអ៊ីចឹង គ្រួសារគាត់តែប្រាំបីនាក់ទេ វាលើសម្នាក់ទៀត គេត្រូវវាយចោលដែរ វាយទាំងអស់ ក៏គាត់ចោលដែរ មិនវាយតែម្នាក់យើងទេ។ បានអ៊ីចឹង យើង -- គាត់លាក់ខ្ញុំនៅឃ្លុបទូក។ អ៊ីចឹង ដើម្បីដល់កន្លែងគាត់ កន្លែងគេឆែកឆេហ្នឹង គេឲ្យយើងឡើងជួយចែវជួយអុំនឹងគេទៅស្រុកយួន។

[១៣:៥៩:០៧]

**ស៖** សូមលោករៀបរាប់អំពីដំណើរទូកនៅពេលដែល តាលី គាត់ចេញទូក<ពីកន្លែងដែលគាត់នៅ ទៅកាន់>ទន្លេបួនមុខហ្នឹង។ តើទូកឆ្លងតាមណាខ្លះ?<>សូមលោកជួយរៀបរាប់ជូនតុលាការជ្រាប។

**ឆ៖** បាទ ពីព្រោះខ្ញុំមកពី ចេញមកទៅ ប៉ុន្តែខ្ញុំទៅតាមទន្លេ មកចូលមកមុខវាំងហ្នឹងបានហៅទន្លេបួនមុខ។ ខ្ញុំចេញមកតាមហ្នឹងមក ទន្លេបួនមុខហ្នឹង ខ្ញុំឡើងកប៉ាល់គេហ្នឹង កប៉ាល់គេមកយកដូរអំបិល ដូរអង្ករហ្នឹង។ គេយកឡើងកប៉ាល់ហ្នឹងគេចូលមកអ្នកលឿង ហើយតាលី គាត់ក៏ចែវទូកទៅ ឬក៏គាត់អុំទៅទេ ខ្ញុំឡើងជាមួយគេ ប៉ុន្តែគេឡើងសាឡង់ហ្នឹង គេឡើងច្រើនមនុស្សហើយ គេឡើងប្រហែលហាហុកសិបនាក់អី ហើយខ្ញុំឡើងទៀត គេចេញដំណើរទៅបណ្តោយ។ ចេញទៅអ្នកលឿងហ្នឹង គាត់និយាយជាមួយខាងវៀតណាមហ្នឹង គេនិយាយយ៉ាងម៉េចខ្ញុំមិនដឹងទេ គេដូរអំបិល ដូរអង្ករហ្នឹង។

**ស៖** ដើម្បីបំភ្លឺឲ្យច្បាស់ តើទន្លេបួនមុខជាកន្លែង ជាកន្លែងដែលមុខបួនដែលជាកន្លែងនៅមុខវាំង រាជវាំងនៅភ្នំពេញហ្នឹង កន្លែងហ្នឹងអីដែលលោកនិយាយថាទន្លេបួនមុខនោះ?

**ឆ៖** បាទ ជាមុខវាំងហ្នឹងឯង។

**ស៖** តើក្នុងពេលដំណើរជិះទូកជាមួយ តាលី ហ្នឹង គឺលោកធ្វើដំណើរប៉ុន្មានថ្ងៃពីកន្លែងចេញដំណើរមករហូតបានមកដល់ទន្លេបួនមុខ នៅដែលលោកនិយាយអំមិញហ្នឹង?

**ឆ៖** ខ្ញុំចេញពីនោះមកទាំងថ្ងៃទាំងយប់ ថែវ អុំហ្នឹងទាំងថ្ងៃទាំងយប់ បីថ្ងៃបីយប់បានដល់ទន្លេប្អូនមុខ។

**ស៖** ឥឡូវនេះ តើនៅពេលដែលលោកមកដល់ទន្លេប្អូនមុខ តើគេធ្វើយ៉ាងម៉េច តើគេបំបែកលោកចេញពី តាលី នៅកន្លែងហ្នឹង ឬក៏យ៉ាងម៉េច?

[១៤:០១:២៩]

**ឆ៖** អ៊ីចឹងដើម្បីមកដល់ទន្លេប្អូនមុខនោះ មានសាឡង់គេដាក់មនុស្សទៅអ្នកលឿង គាត់ថាបើអ្នែងជិះទូកអញទៀត អញងាប់ទាំងគ្រួសារអញហើយ ខ្លាចគេឆែកកន្លែងណាទៀត ទៅអ្នែងឡើងសាឡង់ហ្នឹងសិនទៅ គាត់អុំទៅៗ គាត់អុំគាត់ថែវទៅ គាត់ដាក់ឱ្យខ្ញុំឡើងសាឡង់ហ្នឹងទៅ នៅជាមួយគេជាមួយឯងហ្នឹងទៅ។

**ស៖** ពីដើម -- ខាងដើមលោកនិយាយថា គឺថាមាននៅក្នុងសាឡង់ហ្នឹង មាន៦០នាក់ជាង តើៗអ្នកនៅលើសាឡង់ហ្នឹង គឺជនជាតិវៀតណាម ឬក៏<មាន>ជនជាតិខ្មែរ<ដែរ>?

**ឆ៖** បាទ នៅសាឡង់ហ្នឹងសុទ្ធតែវៀតណាមហ្នឹង អត់មានខ្មែរ ខ្មែរទៅដែរក៏មិនបាន ចេញទៅមិនបានដែរ ហើយខាងចិនហ្នឹងចូលទូកចម្លងនោះក៏មិនបានដែរ។

**ស៖** តើសាឡង់ហ្នឹងជារបស់អ្នកណា?

**ឆ៖** សាឡង់ហ្នឹងខាង កាលហ្នឹងខ្មែរក្រហមហើយ ប៉ុន្តែថាយើងមិនដឹងសាឡង់ខាងណាទេ អត់មែនៗសាឡង់វៀតណាមទេ។ ប៊ិនថាខាងខ្មែរកំណត់ទៅ ការពារសាឡង់ហ្នឹងទៅបានចូលអ្នកលឿងហ្នឹងបានទំនាក់ទំនងជាមួយវៀតណាម។

**ស៖** តើខ្មែរក្រហមអាចកំណត់អត្តសញ្ញាណដូចម្ដេចថាអ្នកណាត្រូវៗបញ្ជូនឱ្យទៅសាឡង់ដូចម្ដេច? <ដើម្បីសន្សំពេល ខ្ញុំធ្វើ>សំណួរឡើងវិញ -- តើកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ឬ<កម្ពុជាប្រជាធិប្បតេយ្យ ធ្វើយ៉ាងម៉េច ដើម្បី>កំណត់អត្តសញ្ញាណ<ថានរណាខ្លះត្រូវ>ឱ្យឡើងជិះទូក<>?

**លោក វ៉ិចទ័រ កូប៉េ៖**

<លោកប្រធាន ដើម្បីឱ្យត្រូវតាមប្រវត្តិសាស្ត្រ កាលនោះ មិនទាន់មាន>កម្ពុជាប្រជាធិបតេយ្យ<នៅឡើយទេ ហើយ>មិនទាន់បានបង្កើតទេ រហូតទាល់តែ<ដើមឆ្នាំ១៩៧៦។ បក្សកុម្មុយនីស្តកម្ពុជាមិនបានប្រកាសនៅឡើយទេ> រហូត<ដល់>ខែកញ្ញា ឆ្នាំ៧៧<។ ដូច្នេះ ពាក្យខ្មែរក្រហម ជារឿងផ្សេងហើយបក្សកុម្មុយនីស្តកម្ពុជាមិនដែលប្រើឈ្មោះហ្នឹងផង។ ពេលហ្នឹង យើងនៅក្នុងអំឡុង> សម័យរណ

សិរ្សបរួមជាតិ<នៅឡើយទេ>។ បាទ <បើសិនណាមេធាវីចង់សួរឱ្យត្រូវប្រវត្តិសាស្ត្រ គាត់ត្រូវសួរថាតើសមាជិក>របស់រណសិរ្សបរួមជាតិ<និយាយអ្វីខ្លះទៅកាន់សាក្សី?>

[១៤:០៣:៥៨]

**កញ្ញា លីម៉ា ង្វៀន៖**

<លោក លោកស្រីចៅក្រម>ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះ គាត់និយាយថាខ្មែរក្រហមបានបង្គាប់ឱ្យប្រជាជនឡើងទៅលើសាឡង់ដើម្បី<ដោះដូរគ្នា។ គាត់ថា ខ្មែរក្រហមជាអ្នកបង្គាប់ឱ្យមនុស្សឡើងជិះសាឡង់។> ដូច្នេះ ខ្ញុំសូមជម្រាបតុលាការថា យើងនឹងប្រើពាក្យតាមដើមបណ្តឹងរដ្ឋប្បវេណី គាត់បញ្ជាក់ថាតើគាត់ហៅអ្នកហ្នឹងថាជានរណា យើងនឹងប្រើជាសម្តីរបស់<ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ>។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:០៥:០៣]

**ប្រធានអង្គជំនុំ៖**

បាទ ហើយលោកស្រីមេធាវីអាចប្រើបាន ហើយពាក្យខ្មែរក្រហមនេះ យើងប្រើទូទៅតាំងពីដើមទី ទាំងសវនាការ ទាំងសាធារណជន គឺនិយាយ គេច្បាស់លាស់បញ្ហានេះ ហើយបរិបទយ៉ាងណានោះគឺស្រេចតែអង្គជំនុំជម្រះនឹងយកទៅពិនិត្យ ពិចារណាវាយតម្លៃជាក្រោយ ព្រោះយើងបានកំណត់ហើយបញ្ហា គឺមិនអាចកំណត់ព្រំដែនឱ្យបានច្បាស់លាស់រវាងរបៀបរបបដាច់ដោយឡែកគ្នា អំពីកាលៈទេសៈពេលវេលាអំពីបញ្ហាខ្មែរក្រហមនោះទេ។ ឧទាហរណ៍ដូចជាសាលាក្តីនេះ ក៏បច្ចុប្បន្ននេះ មហាជនប្រជាជនជាច្រើន គេស្គាល់ថាតុលាការខ្មែរក្រហម ឬក៏តុលាការកាត់ទោសខ្មែរក្រហមដែរ។ អាចសួរបានណ៎ះ!

**កញ្ញា លីម៉ា ង្វៀន៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា លីម៉ា ង្វៀន៖**

**ស៖** លោក ជឿង យ៉ាំង ចែត ខ្ញុំសួរលោកថាតើខ្មែរក្រហមកំណត់អត្តសញ្ញាណ<ប្រជាជនយ៉ាងដូចម្តេច ដើម្បីឱ្យពួកគេ> ឡើងទៅជិះសាឡង់<ធំ>ហ្នឹង<>?

**លោក ជឿង យ៉ាំង ចែត៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ពីព្រោះអាហ្នឹងថា ប្រជាជនបានឡើងជិះសាឡង់ហ្នឹងថា អត់បានទូកទេ ដឹកទូកឡើងលើគោកអស់ហើយ ដុតចោលអស់ អ្នកហ្នឹងបានលោតទៅទេ វត់តាមព្រៃអី តាមភក់អីមក ដោយសារគេមួយដំណាក់ៗទេ បានឡើងសាឡង់ហ្នឹង។ បើអ្នកមានទូក គេចែវ គេអុំទៅដល់អ្នកលឿងដែរ ដូរអង្ករ ដូរអំបិល ដូចគ្នាហ្នឹងដែរ។

[១៤:០៦:៤១]

**ស៖** លោកបានផ្ដល់ភស្តុតាងខាងដើមថា មានតែ<ជនជាតិ>វៀតណាមទេដែលគេឲ្យឡើងជិះសាឡង់ហ្នឹងហើយគេមិនឲ្យខ្មែរណាឡើងជិះទេ។ <លោកប្រាប់ថា> ខ្មែរក្រហមណែនាំ<ថានរណាខ្លះត្រូវ>ឡើងសាឡង់នោះ<។ ដូច្នេះ ខ្ញុំចង់សួរថា> តើគេជ្រើសរើសរបៀបម៉េច ដើម្បីឲ្យដឹងថាអ្នកណាជាខ្មែរ អ្នកណាជាវៀតណាមដែលត្រូវឡើងទូក អ្នកណាដែលមិនត្រូវឡើងទូក គេជ្រើសរើសម៉េចពេលនោះ?

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប!

អញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំថាជាសំណួរច្រំដែល ដើមបណ្ដឹងរដ្ឋប្បវេណីគាត់បានឆ្លើយបញ្ជាក់ហើយថា អ្នកណាឡើងទៅយ៉ាងម៉េចបាន គឺស្រេចតែគេ ជាពិសេសអ្នកដែលមានទូក គឺអាចចែវទូកហ្នឹងទៅដល់កន្លែងសាឡង់នោះទៅ ឡើងទៅបានហើយ ហើយបើមិនអ៊ីចឹងទេ ចែវទៅដល់អ្នកលឿងអាចត្រូវបានគេដោះដូរយ៉ាងម៉េចទៅតាមភាពជាក់ស្ដែងនៅពេលនោះ។ ដូច្នេះ វាអត់មានភាពច្បាស់លាស់ដែលដើមបណ្ដឹងរដ្ឋប្បវេណីនេះអាចបញ្ជាក់លើសពីនេះទៀតទេ។ បាទ សូមអរគុណ។

**កញ្ញា លីម៉ា ង្វៀន៖**

លោក លោកស្រីចៅក្រម ខ្ញុំគិតថាមេធាវី ខៀវ សំផន <យល់>ខុស<លើសំណួរ និង>ភស្តុតាង<ដែលបានផ្ដល់កន្លងមក។> លោក ជឿង យ៉ាំង ចែត ខ្ញុំសួរទៅគាត់ ហើយគាត់ប្រាប់តុលាការថាមានតែជនជាតិវៀតណាមទេដែលគេឲ្យជិះសាឡង់ ហើយសំណួរសួរថាតើខ្មែរក្រហមកំណត់អត្តសញ្ញាណ<ជនជាតិ>វៀតណាម<ហ្នឹងដោយរបៀបម៉េច ដើម្បីឲ្យ>ឡើង<ជិះសាឡង់>ហ្នឹង<> នេះជាសំណួររបស់ខ្ញុំទៅគាត់។ <ហើយគាត់ មិនទាន់បានឆ្លើយសំណួរនេះផង។>

[១៤:០៨:២៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបដិសេធនូវសេចក្ដីជំទាស់របស់មេធាវី គង់ សំអុន។ បាទ សំណួរនេះគឺជាមិនមែនជាប្រភេទសំណួរច្រំដែល ហើយអង្គជំនុំជម្រះត្រូវការស្ដាប់ចម្លើយតបរបស់ដើមបណ្ដឹងរដ្ឋប្បវេណីចំពោះសំណួរចុងក្រោយដ៏ល្អរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

ដើមបណ្ដឹងរដ្ឋប្បវេណីបើចាំនូវសំណួរ សូមឆ្លើយតបទៅនឹងសំណួររបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី។

**លោក ជឿង យ៉ាំង ចៃត៖**

**ឆ៖** បាទ ខ្ញុំបាននៅត្រង់ហ្នឹង គេរើស រើសថាអ្នកណាវៀតណាម ពីណាចិន ពីណាខ្មែរ។ អ៊ីចឹងដើម្បីយើងនិយាយហ្នឹង ពាក្យវៀតណាមហ្នឹង -- ឥឡូវ ខ្ញុំនិយាយខ្មែរអ៊ីចឹង វារឹង ពាក្យវាមិនច្បាស់លាស់។ វារឹងអ៊ីចឹង ដើម្បីគេដឹង ហើយគេមុខ ខ្មែរគេក៏ដឹង បើនិយាយខ្មែរ និយាយយួន ក៏ប៉ៃឡាំគេមិនឲ្យទៅទេ។

[១៤:០៩:៣២]

**សួរដោយកញ្ញា លីម៉ា ង្វៀន៖**

**ស៖** តើប្រជាជនខ្មែរដែលចង់ទៅជិះសាឡង់ហ្នឹងដែរ តើ<មានអ្វីកើតឡើងចំពោះពួកគេ>?

**ឆ៖** គេក៏ -- ការពិបាកដូចខ្ញុំដែរ ការពិបាកដូចខ្ញុំ បានគេពួនទៅ គេរត់ទៅ ចូលស្រុក ចូលអីប៉ុន្តែដល់សាឡង់ហ្នឹងគេមិនឲ្យទៅទេ ហើយដោយសារតាមទូក ទាំងយួនហ្នឹង យួនក៏មិនឲ្យទៅដែរ ងាប់ៗទាំងអស់គ្នាទាំងអស់ហ្នឹង កាលហ្នឹង។ កាលហ្នឹង សម័យហ្នឹងថា រស់អាណាមួយហ្នឹងអរណាស់ហើយ។

**ស៖** ឥឡូវនេះនៅពេលដែលៗលោកមានអាយុតែ១៣ ឬក៏១៤ឆ្នាំធ្វើដំណើរតែម្នាក់ឯង។ តើលោកស្គាល់អ្នកណាម្នាក់ដែលនៅលើសាឡង់ លើកាណូតនោះទេ?

**ឆ៖** ខ្ញុំអត់ស្គាល់គេទេ ចូលបន្លំជាមួយគេតែម្ដង ធ្វើកូនចៅគេហ្នង។

**ស៖** តើមានកម្មាភិបាលខ្មែរក្រហមនៅលើសាឡង់ហ្នឹងទេ?

**ឆ៖** កាលហ្នឹង ខ្ញុំអត់ចាំបានថាអ្នកណាមេ អ្នកណាកូនអីទេ តែឃើញតែពាក់អាវដូចជា ខ្មៅហ្នឹង ហើយក្រមាចងកហ្នឹងទេ ប៉ុន្តែអត់មានកាំភ្លើងគ្រាប់អីទេ ដៃទទេ។

**ស៖** ពីខាងដើមលោកបានបញ្ជាក់ប្រាប់តុលាការថា ទូកខ្មែរក្រហមធំមួយហ្នឹង គឺ<>បត់ទៅអ្នកលឿងនៅក្នុងខេត្តព្រៃវែង។ តើអ៊ីចឹងទេ?

**ឆ៖** បាទ។

**ស៖** តើទូកហ្នឹងចេញដំណើរទម្រាំទៅដល់អ្នកលឿង<ក្នុងខេត្ត>ព្រៃវែងហ្នឹង គឺប្រើពេលប៉ុន្មានដែរ? រយៈពេលប៉ុន្មាន?

**ឆ៖** មួយយប់ មួយថ្ងៃដល់។ ដល់ទាំងព្រឹក ព្រលឹមឡើងដល់អ្នកលឿងបណ្ដោយ។

**ស៖** នៅពេលដែលលោកទៅដល់អ្នកលឿង តើ<មានអ្វីកើតឡើងចំពោះ>ប្រជាជនវៀតណាមដែលនៅលើ<>សាឡង់<?>

**ឆ៖** ដើម្បីគេមកនិយាយជាមួយខាងវៀតណាមហ្នឹង គេនិយាយយ៉ាងម៉េចគេ ខ្ញុំមិនដឹងទេ ប៉ុន្តែថាឲ្យវៀតណាមហ្នឹងឡើងលើគោកហ្នឹង គេរាប់មនុស្ស រាប់ម្ដងនៅសាឡាងហ្នឹងប៉ុន្មាននាក់ អ៊ីចឹងគេយកសាឡង់ហ្នឹង គេមក សាឡង់វៀតណាមហ្នឹង គេយកអំបិលយកអង្កររួច គេឲ្យ បានចេញដំណើរទៅបានវៀតណាមហ្នឹងឲ្យសាឡង់ប្រជាជនហ្នឹងចូលទូកសាឡង់របស់វៀតណាម។

[១៤:១២:៤៤]

**ស៖** ដូច្នេះលោកនិយាយថា មានសាឡាងវៀតណាមមក<ដល់អ្នកលឿងហ្នឹងដែរ>។ តើលោក<អាច>រៀបរាប់<ថាមានអ្វីខ្លះ មាននរណាខ្លះនៅលើ>សាឡាង<>នោះ <>?

**ឆ៖** ខ្ញុំឃើញអង្ករអំបិលទេ អត់ឃើញអីទេ ឃើញតែអង្ករជាមួយអំបិលហ្នឹង។

**ស៖** តើមានអាជ្ញាធរជនជាតិវៀតណាមនៅលើសាឡាង ឬក៏ទូករបស់វៀតណាមហ្នឹងទេ ក្រៅពីអង្ករនិងអំបិល?

**ឆ៖** អត់មានទេ។

**ស៖** លោកបានបញ្ជាក់ប្រាប់តុលាការថា នៅពេលដែលទៅដល់គេបានរាប់ចំនួនមនុស្សនៅលើសាឡង់របស់ខាងខ្មែរក្រហម តើអ្នកណាអ្នករាប់ប្រជាជនទាំងអស់នោះបាទ?

**ឆ៖** បាទ ខាងហ្នឹងវៀតណាមឡើងរាប់ជាមួយខ្មែរយើងហ្នឹង ខ្មែរឈរម្ខាង វៀតណាមឈរម្ខាង រាប់រួចអ៊ីចឹង យើងអង្គុយលើគោកហ្នឹងចាំគេៗអង្ករអំបិលរួច គេចេញដំណើរទៅបានសាឡង់ហ្នឹងចូលខាង បានវៀតណាមបានចូលសាឡង់វៀតណាមទៅប្រទេសវិញ។

**ស៖** តើលោកបានឃើញការដោះដូរ ការៗដូរជនជាតិវៀតណាម ហើយនិងអំបិល និងអង្ករ

តើលោកបានឃើញដោយផ្ទាល់ភ្នែកដោយខ្លួនឯងទេ ពេលនោះ?

**ឆ៖** បាទ ខ្ញុំទៅក្នុងហ្នឹងខ្ញុំស្គាល់ មិនឃើញម៉េច ខ្ញុំទៅសាឡង់ហ្នឹងទៅហើយ ខ្ញុំលើគោក ខ្ញុំឃើញគេលើកអំបិល លើកអង្ករមកសាឡង់ខាងខ្មែរយើងហ្នឹងឯង។ ហើយខ្ញុំទៅសាឡង់អង្ករអំបិលហ្នឹង ទៅស្រុកប្រទេសយួនហ្នឹងហើយ។

**ស៖** តាមពិតលោកជាមនុស្សម្នាក់ក្នុងចំណោមជនជាតិវៀតណាមដែលគេយកទៅដូរអង្ករ និងអំបិល។

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[១៤:១៥:១១]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់ចំពោះការប្រើពាក្យថា "ជួញ" ឬក៏ "ដោះដូរ"នេះ។ អ្វីដែលសាក្សីនិយាយនេះ គឺថាជនជាតិវៀតណាមនៅលើ<ទូកហ្នឹង ហើយ>អង្ករ <និងសម្ភារៈផ្សេងទៀតបានដឹកមកវិញ។ នេះមានន័យថា គ្មានការដោះដូរគ្នាទេ។ រឿងហ្នឹងគឺកើតឡើងគ្រប់ពេល គឺថាឡានដឹកអីវ៉ាន់មួយឆ្ពោះកាន់គោលដៅ "ក" ហើយទម្លាក់អីវ៉ាន់នោះចុះ បន្ទាប់មកដឹកអីវ៉ាន់ផ្សេងវិលទៅវិញ។ អ៊ីចឹង វាមិនមានន័យថា ដោះដូរអីទេ។ នោះជាសេចក្ដីសន្និដ្ឋានរបស់មេធាវីហើយ។ ដូច្នេះ ខ្ញុំយល់ថា ពាក្យ "ជួញ" ឬ "ដោះដូរ" ជាពាក្យប្រើនៅក្នុងបរិបទនយោបាយធំមួយ មិនមែនជាការពិពណ៌នាត្រឹមត្រូវឡើយ។>

**កញ្ញា លីម៉ា ង្វៀន៖**

<លោក លោកស្រីចៅក្រម> នៅក្នុងភស្ដុតាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី គាត់ប្រើពាក្យថា "<ដំណើរការ>ដោះដូរ" <>ច្រើនដង– <យ៉ាងហោចណាស់ គាត់បាននិយាយ>បីដង<រួចមកហើយ គឺថា ពេលគាត់ស្ថិតនៅលើសាឡង់នោះ> គឺគេយកទៅ<សម្រាប់ដំណើរការ>ដោះដូរ<។> ចំពោះភស្ដុតាង លោក លោកស្រីចៅក្រម ខ្ញុំមិនទាន់ដាក់ជាសេចក្ដីសន្និដ្ឋានទេ <ពីព្រោះ> ឥឡូវនេះយើងកំពុងតែស្ដាប់ភស្ដុតាងចេញពីដើមបណ្ដឹងរដ្ឋប្បវេណី <ហើយ>ភស្ដុតាងនោះ <បង្ហាញ>ថាគេយកប្រជាជនវៀតណាមដាក់លើ<>លើសាឡង់ <គេទុកជីវិតឲ្យពួកវៀតណាមហ្នឹង គឺដើម្បីសម្រាប់តែដំណើរការដោះដូរហ្នឹងឯង។ គេអាចហៅដំណើរនេះថា ជំនួញ ឬក៏ការដូរគ្នា ឬក៏ការប្ដូរទំនិញគ្នា អីយ៉ាងម៉េចក៏បាន តែ>ជាជនជាតិវៀតណាម<ទាំងនោះ គឺគេ>យក<មកសម្រាប់តែ>ប្ដូរយកអំបិល <និងអង្ករ។

នេះជាភស្តុតាងដែលលាតត្រដាងនៅថ្ងៃនេះ។>

[១៤:១៧:០១]

**លោក វិចទ័រ កូប៉េ៖**

ខ្ញុំសូមឆ្លើយតបលោកប្រធាន។ នៅក្នុង<សវនាការ>ការបង្ហាញឯកសារ<គន្លឹះ>នោះ <ខ្ញុំគិតថា វា>ទាក់ទងទៅនឹង<មន្ទីរក្រាំងតាចាន់ -- យើងបានបញ្ចាំង>ខ្សែវីដេអូ<មួយអំពី>គណៈប្រតិភូ<ជាន់ខ្ពស់មកពីប្រទេសវៀតណាម មកកាន់ទីក្រុងភ្នំពេញ ដើម្បីចូលជួបជាមួយ> នួន ជា, ប៉ុល ពត, ហើយនិងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា<ជាន់ខ្ពស់ផ្សេងៗទៀត។ តាមពិត ប្រធានបក្ស ឈ្មោះ ឡេ ឌួន បានមកកាន់ទីក្រុងភ្នំពេញ។ កញ្ញាមេធាវីក៏បានមើលខ្សែភាពយន្តដែរ។ មេធាវីប្រហែលជាចាំថា ពួកគេត្រូវបានដើរជូនមើលជុំវិញព្រះវិហារព្រះកែវមរកត។> ទំនាក់ទំនងជាមួយវៀតណាម <និង> រដ្ឋាភិបាលបណ្តោះអាសន្ន<នាពេលនោះ គឺមានភាពស្និទ្ធស្នាលគ្នាណាស់។ ដូច្នេះ ការផ្តល់យោបល់ថា ជីវិតជនជាតិវៀតណាមទាំងនោះត្រូវបានសង្គ្រោះដោយសារតែគេត្រូវការស្រូវអង្ករប៉ុណ្ណឹង គឺជាសេចក្តីសន្និដ្ឋានបំផ្លើស ធ្វើឡើងដោយមេធាវីម្នាក់នេះ ហើយក៏គ្មានមូលដ្ឋាននយោបាយអ្វីសោះ នៅខែសីហា> ឆ្នាំ១៩៧៥នោះ<។ ខ្ញុំគិតថា យើងត្រូវកម្រិតចំពោះអ្វីដែល>សាក្សីបានឃើញនោះ<។ គាត់អាចយល់ថា វាជាការប្តូរ ឬក៏ជំនួញ ប៉ុន្តែវាមិនមែនបែបហ្នឹងទេ។>

**កញ្ញា លីម៉ា ង្វៀន៖**

លោកចៅក្រម មេធាវីការពារក្តី--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ តាមអង្គហេតុដែលដើមបណ្តឹងរដ្ឋប្បវេណីបានលើកមកនេះ វាហាក់ដូចវានឹងព្រឹត្តិការណ៍មួយថ្មីៗបន្ទាប់ពីជ័យជម្នះ១៧ មេសា ១៩៧៥ ហើយបញ្ហានៅពេលនោះវាពុំមានការដឹកនាំចាត់ចែងដែលមានលក្ខណៈគ្រប់គ្រាន់នៅឡើយទេ។ ហើយជាក់ស្តែងអ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីបានឃើញ គឺឃើញការផ្លាស់ប្តូរដែលឃើញផ្លាស់ប្តូរ គឺផ្លាស់ប្តូរកប៉ាល់ គាត់ជិះនៅលើសាឡាងមួយ ហើយគាត់ឡើងទៅលើសាឡាងមួយទៀត ដែលអាចថាសាឡាងមួយជាសាឡាងរបស់ខាងកម្ពុជា ហើយសាឡាងមួយទៀតជាសាឡាងខាងវៀតណាម។ ហើយអ្វីដែលគាត់ឃើញទៀតនោះ

គឺការលើកយកអីវ៉ាន់ ដែលមានថាជាអំបិល ឬអង្ករ ពីសាឡាងរបស់វៀតណាមមកខាងកម្ពុជា។ ដូច្នេះ ការដែលគ្រាន់តែឃើញប៉ុណ្ណេះមិនអាចថាវាជាជំនួញដែលត្រូវដោះដូរយកអំបិល អង្ករ ហើយយកមនុស្ស នោះដោះដូរមកវិញនោះទេ។ វាអាចជាការដោះដូរអីផ្សេងទៀត ពីព្រោះតាមសាក្សីដែលបានផ្តល់សក្ខី-កម្មកន្លងមក ក៏បានបញ្ជាក់ហើយអំពីការចាត់ចែងរបៀបដោះដូរជាលក្ខណៈផ្ទាល់ខ្លួនក្តី ជាលក្ខណៈក្នុងក្រុមមូលដ្ឋានមួយៗក្តី ដែលមានការដូរថ្នាំពេទ្យ ដូរអីជាដើម រវាងខាងព្រំដែនវៀតណាមនោះ។ បាទ សូមអរគុណ។

[១៤:១៩:៥២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយគប្បីបញ្ចប់បញ្ហានេះទៅ ហើយដើមបណ្តឹងរដ្ឋប្បវេណីគប្បីសួរបញ្ជាក់ភាគីកូនក្តីរបស់លោកស្រីមើល៍ ថាតើវាមានអីដែលជាមូលដ្ឋានកត់សម្គាល់ថាសកម្មភាពនោះ គឺជាការដោះដូរ? អាហ្នឹងគឺច្បាស់លាស់ហើយ ទី១។ បញ្ហាទី២ ដូចបញ្ហាដទៃទៀត ប្រសិនបើភាគីមេធាវីការពារក្តី មានបំណងចង់បញ្ជាក់បញ្ហានេះ គប្បីចាំដល់វេនខ្លួនដែលអង្គជំនុំជម្រះនឹងផ្តល់ពេលវេលាសម្រាប់សួរដេញដោល។ អ៊ីចឹងហើយបានយើងប្រើពាក្យ "សួរដេញដោល" ដើម្បីបញ្ជាក់រំលេចឱ្យបានច្បាស់លាស់ដូចអ្វីដែលមេធាវីទាំងអស់ហ្នឹងបានធ្វើកន្លងមក។ អ្វីដែលមិនច្បាស់ អ្វីដែលវាមិនត្រឹមត្រូវ គឺខ្លួនតែងតែសួរបញ្ជាក់ចុងក្រោយដើម្បីផ្ចាញ់ ក៏ផ្ចាញ់សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីជាដើម។ នេះជានីតិវិធីដែលសួរដេញដោលតាមផ្លូវតុលាការ។

**កញ្ញា លីម៉ា ង្វៀន៖**

ចាសលោកប្រធាន នេះមិនមែនជាដំណាក់កាលនៃសេចក្តីសន្និដ្ឋានបញ្ចប់ការសួរដេញដោលទេ។

**សួរដោយកញ្ញា លីម៉ា ង្វៀន៖**

**ស៖** ខ្ញុំសូម<បន្តដើម្បី>ឱ្យដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់ថា ហេតុអ្វីបានគាត់កំណត់ថា វាជាការដោះដូរ។ លោក ជឿង យ៉ាំង ចែត ភ័ស្តុតាងរបស់លោកដែលលោកបង្ហាញមុននេះ <លោក>ថាគឺជាការដោះដូររវាងខ្មែរក្រហម និងអាជ្ញាធរវៀតណាម។ តើវាមានអ្វីដែលនាំឱ្យលោកសន្និដ្ឋានថាវាជាការដោះដូរ ឬក៏វាជាជំនួញក្នុងការដោះដូរទៅវិញនោះ?

**លោក ជឿង យ៉ាំង ចែត៖**

**ឆ៖** ពីព្រោះខ្ញុំឮថាវៀតណាមគេឡើង គេនិយាយមុខខ្ញុំអ៊ីចឹងដែរ គេថា "ខ្ញុំរស់នឹងអង្ករអំបិល

ហ្នឹងហើយ ខ្ញុំដូរអស់លោកឯងទៅស្រុកយួនហ្នឹងហើយ"។

**ស៖** នៅពេលដែលលោកនៅលើសាឡង់នោះ លោក តើលោកបានឃើញអង្ករប៉ុន្មានបាវ អំបិលប៉ុន្មានបាវដែលត្រូវយកមកដោះដូរហ្នឹង?

**ឆ៖** បាទ ខ្ញុំអត់ -- ឃើញអង្ករអំបិលច្រើនមែន ប៉ុន្តែខ្ញុំអត់រាប់បេបានទេ ព្រោះខ្ញុំឡើងលើគោកហើយ គេឱ្យខ្ញុំឡើងលើគោកសិនហើយ។

[១៤:២២:៣៥]

**ស៖** តើមានអ្វីកើតឡើងបន្ទាប់មកទៀតនៅពេលដែលលោកចេញពី ឡើងចេញពីសាឡង់ ទៅនៅលើគោកនុ៎ង?

**ឆ៖** ខ្ញុំឡើងពីសាឡង់លើគោកហ្នឹង គេរាប់ហើយ គេរាប់មនុស្ស មួយសាឡង់ហ្នឹង យកពីខ្មែរយកដាក់អ្នកលឿងនោះប៉ុន្មាននាក់ ប៉ុន្មានរយនាក់អ៊ីចឹង គេបានយកអង្ករមកដូរ។

**ស៖** ដូច្នេះលោកបានឆ្លើយថា ក្រោយពីគេរាប់ចំនួនប្រជាជនវៀតណាម<ចុះពី>ទូកខ្មែរក្រហម គេក៏ពិនិត្យម្តងទៀត ហើយក៏គេរាប់ចំនួនបាវអង្ករ បាវអំបិលដែរនៅលើទូកវៀតណាមនោះ លោកកំពុងនិយាយថាអ៊ីចឹងមែនទេ?

**ឆ៖** អារឿងរាប់បេរាប់អី ខ្ញុំមិនដឹងទេ ប៉ុន្តែឃើញសាឡង់ហ្នឹងដាក់អង្ករ ដាក់អំបិលមែនទែនតែម្តង ប៉ុន្តែគេ សាឡង់ខាងខ្មែរក្រហមហ្នឹង កៀកមកសាឡង់របស់វៀតណាមហ្នឹងគេយកបណ្តោយ បានសាឡង់របស់វៀតណាមហ្នឹង ទំនេរអង្ករអំបិលហ្នឹង បានប្រជាជនវៀតណាមហ្នឹងបានចូលទូកចម្លងហ្នឹងទៅស្រុកយួនវិញ។

**ស៖** នៅពេលដែលលោកឡើងជិះសាឡង់វៀតណាម តើមានអ្នកណាម្នាក់ដែលជិះនៅលើសាឡង់របស់ខ្មែរក្រហម ឡើងទៅជិះសាឡង់វៀតណាមហ្នឹងដែរទេ ជាមួយហ្នឹងលោកហ្នឹង?

**ឆ៖** អត់មានខ្មែរទៅជិះជាមួយទេ សុទ្ធតែវៀតណាមតែម្តង។

**ស៖** បន្ទាប់មកសាឡង់ហ្នឹងចេញដំណើរទៅណាទៅ?

**ឆ៖** ចេញមកវៀតណាម ហៅច្រូវដុក ចូលច្រូវដុកហ្នឹង។

**ស៖** តើមានអ្វីកើតឡើងទៀត<ចំពោះលោក> និងប្រជាជនវៀតណាមទាំងនោះហ្នឹង <កាលណាសាឡង់នោះ>ទៅដល់ប្រទេសវៀតណាម?

**ឆ៖** បាទ ខ្ញុំទៅដល់ហ្នឹង អង្គការខាងវៀតណាមហ្នឹងគេឱ្យយើងស្នាក់នៅសាលារៀនហ្នឹង។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សាលារៀនរបស់វៀតណាមហ្នឹង គេឲ្យចូលនៅទាំងអស់ហ្នឹង គេឲ្យអង្ករ គេបើកអង្ករឲ្យស៊ី។ គេបើកឆ្នាំង បើកចានឲ្យទាំងអស់ ទាំងកៅស៊ូ ទាំងមុង ទាំងកន្ទេល។

[១៤:២៥:៤០]

**ស៖** ពេលដែលលោកនិយាយថា "អង្គការវៀតណាម" តើលោកកំពុងនិយាយសំដៅទៅដល់អាជ្ញាធរវៀតណាម ឬក៏រដ្ឋាភិបាលវៀតណាម?

**ឆ៖** សាឡង់អង្ករហ្នឹង គេយកទៅហ្នឹង។ ខាងសាឡង់ហ្នឹង ខាងអង្គការ ហើយខាងស្អីរបស់វៀតណាមទេ ប៉ុន្តែខ្ញុំដឹងគេយកមក។ គេនិយាយជាមួយខ្ញុំវៀតណាម។ គេដាក់ឲ្យខ្ញុំឡើងទៅសាលារៀនហ្នឹង។ គេឲ្យស្នាក់នៅត្រង់ហ្នឹង គេបើកអង្ករ បើកមុងកន្ទេលឲ្យ ចានឆ្នាំងអីៗហ្នឹង។

**ស៖** តើលោកស្នាក់នៅក្នុងប្រទេសវៀតណាមអស់រយៈពេលប៉ុន្មានដែរ?

**ឆ៖** ខ្ញុំស្នាក់នៅៗប្រទេសវៀតណាម ដល់ឆ្នាំចិត -- ៨២ ដែលបានឡើងប្រទេសខ្មែរ។

**ស៖** ហេតុអ្វីបានជាលោកសម្រេចវិលត្រឡប់មកនៅប្រទេសកម្ពុជាវិញ?

**ឆ៖** ពីព្រោះខ្ញុំនៅនោះហ្នឹង អត់មានដីអីធ្វើចម្ការស្អីគេទេ។ ខ្ញុំជាអ្នករកត្រី។ នៅហ្នឹងក៏អត់មានត្រី ខ្ញុំបានឡើងប្រទេសខ្ញុំ -- ប្រទេសខ្មែរហ្នឹង ដើម្បីម៉ែឪខ្ញុំស្លាប់យ៉ាងណាស្លាប់ ប៉ុន្តែខ្ញុំក៏អត់ចូលប្រទេសខ្មែរខ្ញុំ។

[១៤:២៧:១២]

**ស៖** តើលោកវិលត្រឡប់មកប្រទេសកម្ពុជាវិញ មកតែម្នាក់ឯងទេ? ឬក៏លោកវិលត្រឡប់មកវិញជាមួយនឹងអ្នកដទៃ?

**ឆ៖** ខ្ញុំមកជិះជាមួយគេដែរ។ ខ្ញុំអត់មាន កាលហ្នឹងខ្ញុំអត់មានអង្ករ អត់មានអីផង អត់មានលុយមានកាក់អីមក។ ខ្ញុំជិះតាមទូកគេមក ចែវឡើងទាំងអស់គ្នាហ្នឹង ជួយចែវ ជួយអុំគេឡើង។

**ស៖** នៅពេលលោកមកប្រទេសកម្ពុជា តើលោកមានឯកសារអីដែលត្រូវបង្ហាញជូនដល់អាជ្ញាធរកម្ពុជាទេ ដែលមានសល់ឯកសារអីពីមុនៗដើម្បីបង្ហាញអាជ្ញាធរកម្ពុជាទេពេលមកដល់?

**ឆ៖** ឯកសារខ្ញុំមាន ប៉ុន្តែដល់ខ្ញុំទៅផ្ទះ កាលខ្ញុំឡើង៨២ហ្នឹង ខ្ញុំមានឯកសាររបស់ខ្ញុំនៅខេត្តកំពង់ឆ្នាំង។ ខ្ញុំដាក់នៅផ្ទះអស់ហើយ អត់បានយកមក។

**ស៖** នៅពេលលោកនិយាយថាលោកទុកនៅផ្ទះ មានន័យថាលោកទុកមុនពេលលោកចាកចេញពីប្រទេសកម្ពុជាទៅហ្នឹង ឬក៏យ៉ាងម៉េច?

**ឆ៖** ពីចាកចេញពីប្រទេសកម្ពុជា ខ្ញុំអត់មានសំបុត្រស្នាមអីទៀតទេ ដុតផ្ទះខ្ញុំអស់រលីង អស់ហើយ។ ខោអាវមានតែមួយកំប្លេទៅទេ អត់មានអីទៀតទេ។ លែងមានអីសំបុត្រស្អីទៀត។

**សៈ** ឥឡូវលោក ជឿង យ៉ាំង ចែត ពីខាងដើមលោកបង្ហាញថា ដោយសារតែលោករងរបួសនៅផ្នែកខាងក្រោយនៃក្បាលរបស់លោក ដោយសារតែខ្មែរក្រហមវាយងខ្នងពូថៅហ្នឹងនោះ ដែលកម្មាភិបាលខ្មែរក្រហមវាយនឹងខ្នងពូថៅ លោកៗថាបាត់បង់ការចងចាំខ្លះ តើលោកភ្លេចភ្លាំងហ្នឹង លោកភ្លេចភ្លាំងអ្វីខ្លះដែរ? ពេលខ្លះហ្នឹងលោកធ្លាប់ភ្លេចភ្លាំង ភ្លេចភ្លាំងអី?

**ឆ៖** ខ្ញុំឥឡូវចង់ចាំមិនបាន។ អារឿងភ្លេចភ្លាំងហ្នឹង ត្រឹមកាលណាវាពិបាកខ្លួនខ្ញុំភ្លេចហើយ។ កាលណាដូចថា ខ្ញុំឈឺ ខ្ញុំអត់ចំណាំបាននៅប្រទេសខ្មែរអ៊ីចឹងបាន។ បើថា កាលណាខ្ញុំឈឺចាប់ ខ្ញុំដាក់នៅក្នុងចិត្តហើយ ខ្ញុំត្រូវនិយាយចេញទាំងអស់ប៉ុណ្ណឹង។

[១៤:៣០:០០]

**សៈ** តើលោកដែលភ្លេចនូវអ្វីដែលកើតឡើងចំពោះគ្រួសាររបស់លោកទេ? ហើយបើអ៊ីចឹង ថាតើលោក<ដែរមានភ្លេចភ្លាំងថាម៉េចលោកបាន>រស់រានមានជីវិតពី<ការកាប់សម្លាប់នៅ>ឆ្នាំ១៩៧៥ <>ដែរ<ទេ>?

**ឆ៖** ខ្ញុំទៅនៅប្រទេសខ្មែរ ខ្ញុំគ្រាន់តែស៊ីត្រកួនទេ ហើយខ្ញុំស៊ីបាយគេ ស៊ីបបរជាមួយនឹងគេហ្នឹង គេឲ្យម្នាក់បន្តិចៗស៊ីរស់ហ្នឹង ដើម្បីទៅដល់ស្រុកវៀតណាមហ្នឹង។ វៀតណាមគេចិញ្ចឹមខ្ញុំឡើងប៉ុន្មានខែ គេលែងចិញ្ចឹមហើយ គេបើកអង្ករលែងប៉ុន្មានថ្ងៃហ្នឹង -- បានប៉ុន្មានខែហ្នឹងលែងៗចិញ្ចឹមទៀតហើយ។ ខ្ញុំទៅស៊ីឈ្នួលគេ ខ្ញុំរស់សព្វថ្ងៃហ្នឹង។ ដល់៧០ -- ដល់៨២ ហ្នឹង ខ្ញុំបានឡើងស៊ីកម្មករគេ សព្វថ្ងៃក៏ស៊ីកម្មករគេដែរ ធ្វើកម្មករគេ មានរបស់ឯណាធ្វើ។

**សៈ** លោក ជឿង យ៉ាំង ចែត តើអ្វីៗទាំងអស់ដែលលោកជម្រាបជូនតុលាការ តើនេះគឺជាចងចាំរបស់លោកដែលលោកជម្រាបជូនទៅតុលាការចំពោះការសម្លាប់ក្រុមគ្រួសាររបស់លោកហ្នឹង <ក៏ដូចជារបៀបដែលលោកនៅរស់រានមានជីវិតពីការកាប់សម្លាប់, មែនទេ>?

**ឆ៖** ចងចាំខ្ញុំ ថ្ងៃហ្នឹងផ្ទាល់ភ្នែកខ្ញុំហ្នង ថ្ងៃហ្នឹងម៉ែឪខ្ញុំងាប់ បងប្អូនខ្ញុំសម្លាប់ងាប់ទៅ ផ្ទាល់ភ្នែកខ្ញុំនៅៗខ្ញុំនៅនឹងងាប់ហ្នឹងនៅមុខហ្នឹងដែរ ប៉ុន្តែសំណាងលោកតា លោកយាយ ឬអីជួយខ្ញុំទេ វាយខ្ញុំបីខ្នងពូថៅនៅបាក់ឆ្អឹងមួយនៅហ្នឹង មើលនៅៗបាក់ត្រឹមហ្នឹង ប៉ុន្តែដល់ខែត្រជាក់ ខ្ញុំឡើងវេទនាខ្ញុំណាស់វេទនាណាស់។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** តើអ្វីៗដែលកើតឡើងចំពោះឪពុកម្ដាយលោកនេះ លោកអាចនឹងភ្លេចទេមើលទៅ?

**ឆ៖** បាទ ខ្ញុំភ្លេចមិនបានទេ ខ្ញុំភ្លេចមិនបាន។ បើឧទាហរណ៍មួយ ខ្ញុំចង់សួរអ៊ីចេះ ដូចជាគាត់គេសម្លាប់ម៉ែឪគាត់ សម្លាប់ប្រពន្ធកូនចៅគាត់ គាត់នៅអ៊ីចឹងគាត់នៅធ្វើទុក្ខយ៉ាងម៉េច គាត់វេទនាយ៉ាងម៉េច ដូចជាខ្ញុំអ៊ីចឹងទេ?

[១៤:៣២:៥៦]

**កញ្ញា លីម៉ា ង្វៀន៖**

លោក ជឿង យ៉ាំង ចែត លោកមានពេលវេលាក្នុងការលើកឡើងពីចំណុចនេះនៅពេលដែលប្រធានអង្គជំនុំជម្រះអនុញ្ញាតឲ្យលោកថ្លែងរបៀបនេះ។

ខ្ញុំអស់សំណួរហើយលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រមទាំងអស់ ភាគីទាំងអស់។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំឈ្មោះ អេនឌ្រូ ប៊ិយ <ខ្ញុំមកពីការិយាល័យសហព្រះរាជអាជ្ញា ហើយ>ខ្ញុំមានសំណួរតិចទេ <បន្តពីកញ្ញាមេធាវី> ។<>ដំបូងខ្ញុំសួរចង់សួរថា តើខ្មែរក្រហមបានទៅដល់ភូមិរបស់លោកដំបូងបំផុតហ្នឹងនៅពេលណា?

[១៤:៣៤:០៣]

**លោក ជឿង យ៉ាំង ចែត៖**

**ឆ៖** បើមុនដំបូងជម្លៀសខ្ញុំឡើងលើដារហ្នឹង បើថាទៅខែវៀតណាម ខ្ញុំចាំហ្នងៗ បើខែ៥ៗរបស់វៀតណាម មកហ្នឹង ក្រុមតាពាងហ្នឹងហ្នង។ តាពាងហ្នឹងមេខ្មែរក្រហមហ្នឹង។

**ស៖** <តាមខ្ញុំស្ដាប់លោកនោះ> លោកនិយាយថាគឺខែទី៥ នៃកាឡេនឌីវៀតណាម –កាឡង់យ៉េវៀតណាម– នៅពេល<ឃើញ>ខ្មែរក្រហមចូលទៅដល់ភូមិរបស់លោកដំបូង។ ក្នុងឆ្នាំណាដែរលោក?

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ឆ្នាំ១០៧៥*(ស៊ីក)* ហ្នឹង។

**ស៖** សូមអរគុណ។ សំណួរបន្ទាប់គឺថា ដំបូង -- សូមកែតម្រូវខ្ញុំផង ក្រែងលោខ្ញុំស្ដាប់មិនទាន់-- ប៉ុន្តែខ្ញុំយល់ថា លោកបាននិយាយថា មានគ្រួសារវៀតណាមចំនួន៣០គ្រួសារនៅក្នុងភូមិកំណើតរបស់លោក ហើយមានសមាជិកគ្រួសារខ្មែរនោះច្រើនលើសលប់។ អ៊ីចឹងមែនទេ?

**ឆ៖** បាទមាន ប៉ុន្តែថ្ងៃហ្នឹង បើខ្ញុំនិយាយទៅតាមខែ ខ្ញុំក៏អត់នឹកឃើញដែរ ប៉ុន្តែខ្ញុំមកជម្លៀស -- ខ្លួនខ្ញុំអត់មានអ្នកណាជម្លៀសទេ រត់មកទាំងអស់គ្នាហ្នឹង នៅវាស្ងាត់ពេកនៅព្រៃនោះ នៅឃុំឫស្សីដង្កួចនោះវាស្ងាត់ណាស់ បានរត់មកកំពង់ឆ្នាំង ភូមិកណ្ដាលហ្នឹង ជាង៣០គ្រួសារ មកប្រហែលនៅមួយខែទេ ចូលឆ្នាំខ្មែរ ប្រាំពីរថ្ងៃក្រោយចូលឆ្នាំខ្មែររួច ប្រាំពីរថ្ងៃក្រោយទេ គេនៅលើគោក គេ "ជយយោ សម្ដេចឪ! ផ្ទះអ្នកណានៅដុតចោល"។ អ៊ីចឹងលើគោកនៅលើគោក នៅហ្នឹងទឹកទៅតាមទឹក អត់ឲ្យអ្នកនៅនឹងទឹកហ្នឹងឡើងលើគោកទាន់គេផង។ អ្នកនៅគោករត់មកទូកក៏មិនទាន់ផង។

[១៤:៣៦:១៨]

**ស៖** លោកនិយាយថា អ្នកដែលឡើងមកភូមិកណ្ដាលហ្នឹងមានតែក្រុមគ្រួសារវៀតណាម លោកនិយាយថា មានតែគ្រួសារវៀតណាម ៣០គ្រួសារទេ? <ហើយគ្រួសារខ្មែរមិនបានចាកចេញពីភូមិកំណើតលោកទេ នាពេលនោះ, អ៊ីចឹងមែនទេ?>

**ឆ៖** ខ្ញុំនៅភូមិឫស្សីដង្កួចហ្នឹងជាង៣០គ្រួសារ មកភូមិកណ្ដាល កំពង់ឆ្នាំងយើងហ្នឹង ប៉ុន្តែវៀតណាមនៅកំពង់ឆ្នាំងហ្នឹងក៏ច្រើនដែរ ទាំងចាមនៅកំពង់ឆ្នាំងក៏ច្រើនដែរ ខ្មែរយើងនៅហ្នឹងក៏ច្រើនដែរ នៅទឹក នៅលើគោកទាំងអស់គ្នាហ្នឹង ជុំគ្នានៅកន្លែងភូមិកណ្ដាលហ្នឹង។

**ស៖** ខ្ញុំសួរអំពីក្រុមគ្រួសារខ្មែរបន្ថែមពីលើក្រុមគ្រួសារវៀតណាម<៣០គ្រួសារនោះ> ដែលរស់ភូមិរបស់លោក។ តើគ្រួសារខ្មែរហ្នឹងចាកចេញពីភូមិនោះដែរ ឬក៏អត់ទេនៅពេលដែលក្រុមគ្រួសារវៀតណាមចាកចេញមក ឬក៏ក្រុមគ្រួសារខ្មែរហ្នឹងបន្តរស់នៅភូមិហ្នឹង នៅពេលដែលក្រុមគ្រួសារវៀតណាមចាកចេញពីភូមិនោះ?

**ឆ៖** បាទ វៀតណាមនេះ ៣០គ្រួសារហ្នឹងចាកចេញពីភូមិឫស្សីដង្កួចហ្នឹងទេ បើខ្មែរគេអត់ចាកចេញទេ គេនៅផ្ទះហ្នឹង គេនៅហ្នឹងហើយ គេអត់មានចេញទេ។

**ស៖** ខ្ញុំព្យួរថា លោកទើបតែនិយាយថា ស្ទើរគេដែលថាផ្ទះដែលមិនមានអ្នកណានៅហ្នឹងត្រូវដុតចោលហ្នឹង លោកចង់សំដៅថាផ្ទះរបស់ក្រុមគ្រួសារវៀតណាមដែលចាកចេញមកហ្នឹង ក្រោយចាក

ចេញហើយ គេដុតផ្ទះដែលនៅទំនេរហ្នឹងចោលអ៊ីចឹងអី?

**ឆ៖** បាទ វាអ៊ីចេះ! ដូចថាផ្ទះលើគោកហ្នឹង ហើយផ្ទះនៅនឹងទឹកហ្នឹង គេថានៅទឹក ជយយោសម្ដេចឪ! ផ្ទះអ្នកណានៅដុតចោល។ អ្នកលើគោក គេរុញឡើងលើគោក អ្នកនៅលើទឹក គេរុញនៅនឹងទឹក។ គេជូនទៅដារ ទៅភូមិដារណា ទៅភូមិហ្នឹងទៅ ភូមិណាទៅតាមភូមិហ្នឹងទៅ គេបញ្ជាឲ្យទៅហើយ ប៉ុន្ដែថាផ្ទះ គេទៅអស់ហើយ នៅផ្ទះហ្នឹងគេជយយោហើយ អត់មានអ្នកណានៅហ្នឹង គេដុតចោលហើយ អត់មានទុកទេ ដុតចោល កម្ទេចចោលហ្នុង។

[១៤:៣៨:៥៣]

**ស៖** តើអ្នកភូមិស្រុករបស់លោក ដឹងថាអ្នកណារស់នៅភូមិហ្នឹងជាជនជាតិវៀតណាម មិនមែនជាជនជាតិវៀតណាមដែរឬទេ? <បើដូច្នេះ តើ>គេដឹងដោយរបៀបណា?

**ឆ៖** ការដេញ ជយយោសម្ដេចឪហ្នឹង ដេញទាំងអស់ ទាំងខ្មែរ ទាំងចាម ទាំងចិន ទាំងយួនហ្នឹង ដេញទាំងអស់ អត់មាននៅសល់អ្នកណាមួយនៅខេត្តកំពង់ឆ្នាំងហ្នឹងទេ។ អ្នកណានៅលើគោកទៅបញ្ជូនហោះលើគោកទៅ អ្នកណានៅទឹក ទៅដើរទៅច្រណូកអីទៅ អ្នកណានៅជើងគ្រោះៗទៅ ដេញតាមភូមិ ដេញឲ្យទៅឆ្ងាយខេត្តកំពង់ឆ្នាំងហ្នឹង បានគេដុតផ្ទះហ្នឹងចោល អត់មានពីណានៅខេត្តកំពង់ឆ្នាំងហ្នឹងទាំងអស់។

**ស៖** ខ្ញុំសូមទោសសំណួររបស់ខ្ញុំវាមិនច្បាស់។ ខ្ញុំចង់ស្វែងយល់ថា តើលោកបានដឹងថាអ្នកភូមិរបស់លោកនេះ <>គិត<>តាំងពីមុនខ្មែរក្រហមចូលមកដល់ ក៏ដូចជាពេលដែលខ្មែរក្រហមចូលមកដល់ ទាំងមុន ទាំងក្រោយ។ តើគេដឹងថាអ្នកណាជាវៀតណាម? អ្នកណាជាខ្មែរទេ? ហើយបើគេដឹងៗដោយរបៀបណា?

**ឆ៖** ដឹងរបៀបថា យើងកាលមុនជាឪជាម៉ែយើងហ្នឹង វាដូចជាបងយើងហ្នឹង វាចូលដូចថាកាលសម័យហ្នឹងគេប្រើ "ឡាំងតាយ"ហ្នឹង – ឡាំងតាយហ្នឹង ដូចកត់សម្គាល់ខ្លួនយើងហ្នឹង បានគេប្រើយកតាមពាក្យហ្នឹង គេយកហ្នឹង។ ដូចសៀវភៅគ្រួសារសព្វថ្ងៃឥឡូវអ៊ីចឹង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះទៅ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់

ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក ហើយនិងឲ្យអញ្ជើញគាត់ មកកាន់កន្លែងផ្តល់សក្ខីកម្ម ក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤១ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:២៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញារងអន្តរជាតិមានឱកាសការតាំងសំណួរដេញដោយចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី មុនយើងសម្រាក ខ្ញុំបានសួរលោកអំពីភូមិឫស្សីដង្គួចរបស់លោក។ ហើយខ្ញុំ<សូមទោសផង ខ្ញុំដូចជា>មិនទាន់យល់ច្បាស់ពីចម្លើយចុងក្រោយ<របស់លោកទេ។ ខ្ញុំចង់សួរលោក> ថាតើគេដឹងថាអ្នកណាជាជនជាតិវៀតណាម អ្នកណាជាជនជាតិខ្មែរយ៉ាងដូចម្តេច<ក្នុងចំណោមអ្នករស់នៅក្នុងភូមិលោក>?

**លោក ជឿង យ៉ាំង ចែត៖**

**ឆ៖** ដូចខ្ញុំនិយាយអំមិញដែរថា ពីព្រោះហ្នឹង កាលហ្នឹងប្រើក្រដាសឡាំងតាយហ្នឹង ដល់គេដឹងថាដូចថាក្រដាសហ្នឹង ហើយយើងក្រដាសគ្រួសារ បញ្ជីគ្រួសាររបស់យើងហ្នឹង គេដឹង គេដឹងណា វៀត-ណាមក៏ដឹង ដឹងខ្លះខ្មែរ។

**ស៖** ដើម្បីឲ្យប្រាកដ<ច្បាស់>ថាខ្ញុំយល់ចម្លើយរបស់លោក គឺថាមានសៀវភៅ<គ្រួសារ>នៅក្នុងភូមិរបស់លោកដែលបញ្ជាក់ថាតើបុគ្គលណា ឬក្រុមគ្រួសារណាជាជនជាតិវៀតណាម អ្នកណាជា

ជនជាតិខ្មែរ។ តើ<អ៊ីចឹងត្រឹមត្រូវទេ>?

**ឆ៖** បាទមាន កាលហ្នឹងមានដល់ កាលហ្នឹងគេដុតផ្ទះដុតអីអស់ហើយ អត់មានទេ ឥឡូវខ្ញុំអត់មានទេ។ ខ្លួនហ្នឹងមានតែខ្លួនទទេ និងខោអាវមួយកំប្លេហ្នឹង មានអីយកតាមតាមខ្លួនទេ។

**ស៖** លោកបានបញ្ជាក់ថាពាក្យ <ខ្ញុំស្តាប់ឮ>លោកប្រើពាក្យ "ឡាំងតាយ" ដែលលោករៀបរាប់ថា ជាសៀវភៅកត់ត្រា ឬក៏ជាសៀវភៅកត់ត្រាគ្រួសារដែលបញ្ជាក់ថាបុគ្គលណាម្នាក់ ឬគ្រួសារណាម្នាក់ជាជនជាតិខ្មែរ ឬជនជាតិវៀតណាម។ តើអ៊ីចឹងឬទេ លោកដើមបណ្តឹងរដ្ឋប្បវេណី?

**ឆ៖** ពីព្រោះខ្ញុំនិយាយថាហើយ ថាកាលហ្នឹងវាអ៊ីចេះ ដូចជាឡាំងតាយហ្នឹង គេដឹងវៀតណាម គេធ្វើឡាំងតាយហើយ។ បើខ្មែរគេអត់ធ្វើឡាំងតាយអីទេ។ បានអ៊ីចឹងបានថាគេដឹងវៀតណាម គេដឹងខ្មែរ។

[១៥:០៤:៣៧]

**ស៖** នៅពេលដែលខ្មែរក្រហមចូលមកដល់ភូមិរបស់លោក តើពួកគេអាច<ចូល>មើលអាសៀវភៅ ឡាំងតាយហ្នឹងទេ ជាសៀវភៅគ្រួសាររបស់ក្រុមគ្រួសារអ្នកភូមិបានទេ?

**ឆ៖** បាន ដូចខ្ញុំជម្រាបមុនអ៊ីចឹង។ ដូចតែថាខ្ញុំនៅភូមិហ្នឹង ដល់ខ្ញុំទៅជម្លៀសឡើងលើហ្នឹងគេបានដឹងថាយើងនៅភូមិឫស្សីជ្រុំដូចហ្នឹងហើយ ក៏បានជម្លៀសឡើងលើគោក។ ក៏គេអត់ បើអត់រស់នៅភូមិហ្នឹង គេជម្លៀសនៅនឹងទឹកហ្នឹង ធ្វើត្រីឲ្យពួកខ្មែរក្រហមហ្នឹងទៅ។

**ស៖** តើខ្មែរក្រហមបានបញ្ជាក់ប្រាប់ប្រជាជនដូចជាលោកនៅក្នុងភូមិដែរឬទេថា <គេដឹងថា> អ្នកណាជាជនជាតិវៀតណាម? អ្នកណាជាខ្មែរ? តើគេបាននិយាយអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ គេមាននិយាយអ៊ីចឹងដែរ។ គេនិយាយថា ខ្មែរក៏ធ្វើពលកម្មក៏ដូចវៀតណាម-យួន។ អង្កាល់ហ្នឹងគេហៅយួនហើយ គ្មានយៀកណាមទេ។ យួនហ្នឹងដែរ ដូចគ្នា ប៉ុន្តែគេបញ្ជីគ្រួសារវាខុសគ្នា កាលណាយៀកណាមគឺគេនិយាយប្រើឡាំងតាយ កាលណាខ្មែរគេប្រើផ្សេង។ អ៊ីចឹងដើម្បីវាខុសគ្នាត្រឹមហ្នឹង។

[១៥:០៦:១៣]

**ស៖** តើខ្មែរក្រហមនោះ គេបានមើលឯកសារឡាំងតាយដែរឬទេ? ឬក៏គេសុំមើលសៀវភៅ ឬក៏ឯកសារឡាំងតាយ<របស់គ្រួសារ>ហ្នឹង<>?

**ឆ៖** មើលទាំងអស់ខាងយៀកណាម មើលទាំងអស់ ឡាំងតាយហ្នឹងមើលទាំងអស់។

**ស៖** នៅពេលដែលក្រុមគ្រួសារលោក និងក្រុមគ្រួសារវៀតណាមផ្សេងទៀត ដែលគេប្រាប់ឲ្យចាកចេញ តើលោកដឹងដែរឬទេ តើខ្មែរក្រហមគេបានប្រើបញ្ជីឈ្មោះជនជាតិវៀតណាម ឬក៏ក្រុមគ្រួសារវៀតណាមដែរទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ <ជាថ្មីម្តងទៀត> ខ្ញុំសូមជំទាស់ដែលថាសហព្រះរាជអាជ្ញាប្រើពាក្យ "ខ្មែរ<ក្រហម"។ វាជារឿងមួយដែលប្រហែល>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី<ប្រើពាក្យហ្នឹង> ប៉ុន្តែ ពាក្យថាខ្មែរក្រហមនោះ គឺមិនស័ក្តិសម មិនមានៗកត្តាខាងអង្គហេតុក្នុងការរៀបរាប់នូវកាលៈទេសៈបែបនេះទេ យើងត្រូវតែរៀបរាប់ឲ្យជាក់លាក់។ ខ្ញុំ<ទើបតែ>យោងទៅរកការប្រជុំថ្នាក់ខ្ពស់មួយនៅក្នុងខែកក្កដា ឬសីហា ឆ្នាំ១៩៧៥ រវាង ប៉ុល ពត, នួន ជា និង វៀតណាម<។ ច្បាស់ណាស់ មានហេតុការណ៍ជាច្រើនបានកើតឡើងនៅថ្នាក់កំពូល>។ ដូច្នេះ <បើ>យើងនិយាយ<>ខ្មែរក្រហម <ទូទៅនៅខែមីនា> ខែមេសា ឧសភា មិថុនា <ឆ្នាំ១៩៧៥> គឺប្រើពាក្យនេះមិនត្រឹមត្រូវទេ<។ អ៊ីចឹងទេ> សហព្រះរាជអាជ្ញា<គួរគប្បីសួរឲ្យច្បាស់> មិនអាចសួរថាខ្មែរក្រហមធ្វើបែបនេះ ធ្វើបែបនោះ <តែសួរបែបនេះវិញ តើអ្នកនោះជានរណាគេ, ទោះបីជាកម្មាភិបាល ឬអ្នកមូលដ្ឋានក្តី។>

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

ខ្ញុំសូមឆ្លើយលោកប្រធាន។ មេធាវីការពារក្តី នួន ជា លើកឡើងការជំទាស់<តែមួយនេះជាច្រើនដងមក>ហើយ<។> ហើយការជំទាស់<មួយនេះ>ត្រូវបានបដិសេធម្តងហើយម្តងទៀត។ ហើយពាក្យនេះ<គឺជាពាក្យតែមួយដែលលោក>ដើមបណ្តឹងរដ្ឋប្បវេណី<យល់។ បើសិនណា>មេធាវី<ការពារក្តីចង់សួរបញ្ជាក់ក្រោយទៀតនោះ គាត់អាចធ្វើបាន។ ចំពោះខ្ញុំៗពេញចិត្តហើយ ដែលលោក>ដើមបណ្តឹងរដ្ឋប្បវេណី<យល់ពាក្យដែលខ្ញុំកំពុងប្រើប្រាស់។> ដូច្នេះ ខ្ញុំសូមអនុញ្ញាតបន្តលោកប្រធាន។

[១៥:០៩:០៤]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្តីជំទាស់របស់មេធាវីការពារលោក វ៉ិចទ័រ កូប៉េ ក្នុងការប្រើប្រាស់ពាក្យនេះ។ ពាក្យនេះគឺប្រើជាការកត់សម្គាល់ទូទៅ ហើយយើងប្រើប្រាស់ច្រើនបរិបទនៃអង្គហេតុរួចមកហើយតាំងពីប្រវត្តិសាស្ត្របក្សកុម្មុនីយស្តកម្ពុជាហូរហែរហូតមក។ ហើយនេះគេចង្អុលបង្ហាញអំពីសញ្ញាណនៃក្រុម មួយក្រុមដែលមាននិន្នាការកុម្មុយនីស្ត ហើយចំពោះការវាយតម្លៃដំណាក់កាលណាមួយ ហើយនោះគឺជារឿងរបស់អង្គជំនុំជម្រះដែលនឹងពិនិត្យវាយតម្លៃទៅតាមស្ថានភាពជាក់ស្តែងកាលៈទេសៈជាក់ស្តែងមានការពាក់ព័ន្ធ។ លោកអាចតសំណួររបស់លោកបាន។

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំបានសួរលោកនៅពេលដែលគ្រួសារលោក ហើយនិងគ្រួសារវៀតណាមផ្សេងទៀត ដែលគេបង្ខំឲ្យទៅនៅភូមិផ្សេងទៀត។ តើលោកបានដឹងទេថាខ្មែរក្រហមនោះគេបានប្រើបញ្ជីដើម្បី<>កំណត់ថាអ្នកណាត្រូវចេញពីភូមិដែរឬទេ?

**លោក ជឿង យ៉ាំង ចែត៖**

**ឆ៖** កាលនោះខ្ញុំដូចប្រាប់ទៅថា យើងមកពីឫស្សីដង្កួចមកនោះ ជាង៣០គ្រួសារ គេមិនជម្លៀសមកទេ គេមកខ្លួនឯង យើងនៅកំពង់ឆ្នាំងហ្នឹងប្រហែលចូលឆ្នាំខ្មែរ ប្រាំពីរថ្ងៃចុងក្រោយហ្នឹង បានគេដាក់មួយម៉ាត់ "ជយយោសម្តេចឪ ផ្ទះណានៅដុតចោល" អ៊ីចឹងគេជម្លៀសខាងលើគោក ទៅលើគោកទៅខាងទឹកទៅតាមទឹកទៅ បានជម្លៀសមកចូលជើងគ្រោះ-ដារហ្នឹង។ បាន អ៊ីចឹងបានគេថាចូលដារហ្នឹងបានគេយកសំបុត្រឡាំងតាយហ្នឹងគេមើល ដូចថា យើងនៅភូមិឫស្សីដង្កួចហ្នឹងគេយកទៅឡើងលើភ្នំ។ អ្នកណានៅភូមិផ្សេង គេដាក់នៅទឹក។ អ្នកណាត្រូវការឡើងភ្នំ គេឲ្យជម្លៀសទៅភ្នំហើយ។

[១៥:១១:៤៩]

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី មុនថ្ងៃដែលលោករៀបរាប់អំពីការចាប់សមាជិកក្រុមគ្រួសាររបស់លោក ហើយគេចាប់គ្រួសារ<មួយ ជាអ្នកជិតខាងលោក>យកអ្នកទាំងនោះទៅសម្លាប់។ តើលោកដឹងថាមានគេចាប់ក្រុមគ្រួសារវៀតណាមផ្សេងទៀតទេ នៅក្នុងភូមិដែលលោករស់នៅ ដែលថានៅលើភ្នំនោះ <ដែរ ឬទេ>?

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំជំទាស់<ទៅនឹងការតាំង>សំណួរនេះ លោកប្រធាន <សំណួរ>ទំនងជាផ្ដល់នូវហេតុការណ៍ដើម្បីឲ្យដើមបណ្ដឹងរដ្ឋប្បវេណី<ពិពណ៌នា>ថាវាកើតអ៊ីចឹងមែន ថាមានការចាប់ខ្លួន ដោយហេតុថាគ្រួសារហ្នឹងជាគ្រួសារវៀតណាម។ <ករណីចាប់ខ្លួននេះគឺច្បាស់ណាស់ដោយសារតែពួកគេជាជនជាតិវៀតណាម។ ប៉ុន្ដែ សំណួរសួរដោយមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីនោះ ទំនងដូចជាសន្និដ្ឋានថាព្រឹត្តិការណ៍កើតឡើង ការសម្លាប់រង្គាលកើតឡើង គឺដោយសារតែពួកគេជាជនជាតិវៀតណាម> ប៉ុន្ដែដើមបណ្ដឹងរដ្ឋប្បវេណីខ្លួនឯងបញ្ជាក់ខ្លួនឯងនៅក្នុងពាក្យសុំ<តាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី បង្ហាញថា គាត់មិនដឹងអំពី>មូលហេតុ<អ្វីដែលគេមកចាប់ក្រុមគ្រួសាររបស់គាត់ទេ នៅពេលដំបូងនោះ>។

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

ខ្ញុំសូមឆ្លើយតបទៅនឹងមេធាវីការពារក្ដី។ ហើយខ្ញុំសួរសំណួរដោយមានលក្ខណៈអព្យាក្រឹត្យដោយមិនបញ្ជាក់ថា គេចាប់នោះសុទ្ធតែវៀតណាមទេ ប៉ុន្ដែ<មេធាវីការពារក្ដីលោក នួន ជា ទៅវិញទេជាអ្នកបកស្រាយមកលើខ្លឹមសារនៃសំណួររបស់ខ្ញុំ។ ខ្ញុំគ្រាន់តែសួរលោកដើមបណ្ដឹងរដ្ឋប្បវេណីថា តើគាត់បានដឹងទេ ថាបុគ្គលណា ឬគ្រួសារមួយណាត្រូវចាប់ខ្លួន ដែលជាវៀតណាមប៉ុណ្ណោះ។> សំណួរ<ខ្ញុំ>មានលក្ខណៈ ជាអព្យាក្រឹត <ហើយខ្ញុំគិតថា ដើមបណ្ដឹងរដ្ឋប្បវេណីអាចឆ្លើយសំណួរនេះបាន>។ ប្រសិនបើមេធាវីការពារក្ដី នួន ជា គាត់ចង់សួរសំណួរ<ទាក់ទងទៅនឹងការចាប់ខ្លួនដទៃទៀតនោះ ពិតណាស់ គាត់អាចធ្វើតាមខ្លួនចង់>។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធសេចក្ដីជំទាស់របស់លោកមេធាវី វ៉ិចទ័រ កូប៉េ នូវបញ្ហាដែល នៃការតាំងសំណួរចុងក្រោយរបស់សហព្រះរាជអាជ្ញារងអន្តរជាតិ ចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះអម្បាញ់មិញនេះ។ បញ្ហាទី២ យើងសូមរំឭកភាគីពាក់ព័ន្ធថា មិនគប្បីបង្រៀនភាគីម្ដងទៀត ឲ្យទើបតែរៀនមកតាំងសំណួរនៅក្នុងសវនាការនេះទេ ព្រោះភាគីពាក់ព័ន្ធនេះទំនងជាមានបទពិសោធន៍ និងចេះដឹងអំពីរបៀបនៃការតាំងសំណួរដេញដោលនៅក្នុងតុលាការនេះយូរហើយ ទើបដាក់ពាក្យសុំមកធ្វើការនៅទីនេះ។

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សូមអរគុណលោកប្រធាន។

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំបានសួរលោកថា មុនពេលថ្ងៃដែលខ្លួនលោក ហើយនិង <គ្រួសារវៀតណាមផ្សេងត្រូវបានចាប់ខ្លួន និងនាំយកទៅសម្លាប់> តើលោកដឹងមានការចាប់ខ្លួនមនុស្សផ្សេងទៀតទេ នៅ<ពេលដែលលោកនៅ>ភ្នំនោះដែល<មានគ្រួសារ>ជនជាតិវៀតណាម<នោះដែរឬទេ>?

**លោក ជឿង យ៉ុង ចែត៖**

**ឆ៖** ខ្ញុំដឹងតែគ្រួសារខ្ញុំ ជាមួយគ្រួសារតែមួយហ្នឹងបួននាក់ហ្នឹងទេ ប៉ុន្តែថា ខ្ញុំចុងក្រោយមកសម្លាប់អីទៀតខ្ញុំអត់ដឹងទេ។ ប៉ុន្តែថា ខ្ញុំកាលហ្នឹងវាយចូលរណ្តៅរួច សំពងកខ្ញុំហើយ ខ្ញុំទៅពួននៅព្រៃ ពួននៅផ្ទះទូកទន្លេហ្នឹងហើយ។ ខ្ញុំអត់ហ៊ានចេញមុខទៅក្រៅទៀត មិនដឹងអីរឿងរ៉ាវទៅមុខទៀត។ ខ្ញុំដឹងតែប៉ុណ្ណឹងទេ។

**ស៖** នៅក្នុងរណ្តៅដែលលោកបានឃើញសាកសពសមាជិកក្រុមគ្រួសារដែលគេសម្លាប់ហ្នឹង តើមានរណ្តៅផ្សេងទៀតដែលនៅជិតៗហ្នឹងទេ? លោកបានឃើញទេ?

**ឆ៖** ខ្ញុំអត់បានឃើញទេ ឃើញរណ្តៅពីរហ្នឹងទេ។ ខ្ញុំឃើញតែពីរនុ៎ង ប៉ុន្តែរណ្តៅឪម៉ែខ្ញុំ ទាំងបងទាំងអី ទាំងគេស្លាប់ហ្នឹងរណ្តៅតែមួយ នៅរណ្តៅទទេមួយទៀត។

[១៥:១៦:៣៣]

**ស៖** សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរពីរបីទៀតទេ ចង់សួរលោក។ យ៉ាងហោចណាពាក់ព័ន្ធទៅនឹងនៅពេលដែលលោកធ្វើដំណើរទៅវៀតណាមដោយជិះតាមសាឡាងនោះកាលនោះ នៅពេលដែលលោកចេញដំណើរដំបូងតាមទូករបស់តាលី នោះហើយលោកបានធ្វើដំណើរតម្រង់មកភ្នំពេញកាលហ្នឹង តើលោកបានឃើញទូកផ្សេងៗធ្វើដំណើរមកជិតលោកទេ? បើក្នុងករណីមាន ថាតើលោកឃើញ<ប្រហែល> ប៉ុន្មានដែលមកជិតៗជាមួយលោកដែរហ្នឹង? អាចចាំបានទេ?

**ឆ៖** ចាំបាន។ កាលហ្នឹងកាលណាអ្នកណាជិះសាឡង់ទៅ ដូចថាដើរទៅមុន ពួននៅព្រៃ មិនដឹងទេ គេនៅសាឡង់មុនហើយ។ ប៉ុន្តែទៅតាមផ្លូវទឹកហ្នឹង ខ្ញុំឃើញប្រហែលចូល៦០, ៧០អី ទូកចេញដំណើរទៅភ្នំពេញ។

**ស៖** តើលោកបានមានឱកាសសង្កេតមើល ឬក៏មើលឃើញមនុស្សដែលជិះនៅលើទូកផ្សេងៗ

ទូកនោះទេ ដែលថាទូកដែលគេធ្វើដំណើរជិតៗលោក? <>

**ឆ៖** បាទ ខ្ញុំឃើញគេចែវអែបគ្នានុ៎ង ចែវកាលហ្នឹង អត់ចែវឆ្ងាយគ្នាទេ ចែវអែបគ្នា ដូចជាមួយហ្វូងហ្នុង មានងាប់ ងាប់អស់មួយហ្វូងទៅ។ ចែវៗអែបគ្នាហ្នឹង អត់មានចែវឆ្ងាយណាទៅមុន ណាទៅក្រោយទេ ចែវមួយហ្វូងទៅហ្នុង។

**ស៖** តើលោកអាចស្គាល់អំពីជាតិ<ពន្ធុ>ជនជាតិដែលជិះនៅលើទូកទាំងអស់ហ្នឹងទេ? <>

**ឆ៖** ជនជាតិវៀតណាមហ្នុង អត់មានជនជាតិណាទៅទៀតទេ។ មានជនជាតិវៀតហ្នុង ប៉ុនថាទូកណាខ្ញុំមិនដឹង។ តែទូកខាងខ្ញុំពីរបីទូកហ្នឹង ចែវអែបៗគ្នាហ្នឹង អត់មានជនជាតិណាមួយទេ។

**ស៖** នៅពេលដែលលោកឡើងជិះទៅសាឡាងដែលលោកបានរៀបរាប់ បាទ ជិះសាឡូង់នៅទន្លេចតុមុខនៅមុខវាំង<នៅភ្នំពេញ> នោះ តើមានសាឡូង់តែមួយហ្នឹងទេដែលប្រជាជនឡើងជិះរួមគ្នា? ឬក៏ថាមានសាឡាងផ្សេងទៀតដែល<ប្រជាជនជិះ> ធ្វើដំណើរឆ្ពោះទៅខាងវៀតណាមនោះ?

[១៥:១៩:៣១]

**ឆ៖** កាលខ្ញុំឃើញៗតែមួយទេ ប៉ុន្តែលើសាឡូង់ហ្នឹងគេនៅ មនុស្សនៅហ្នឹងប្រហែល៥០-៦០នាក់ហើយបានខ្ញុំឡើងទៅហ្នឹង។ ខ្ញុំឡើងហ្នឹង តាលី ហ្នឹង គាត់និយាយមួយម៉ាត់មួយខ្ញុំ។ គាត់ថា "កុំអ្នែងនៅជិះទូកអញ ខ្លាចកន្លែងណាគេស្រែកទៀត គេសម្លាប់អញចោលហើយ អ្នែងឡើងសាឡូង់ហ្នឹងទៅ"។ បានខ្ញុំឡើង ខ្ញុំបែកជាមួយគាត់ទៅ។ តែប៉ុណ្ណឹងទេ ខ្ញុំឃើញសាឡូង់តែមួយហ្នឹង។

**ស៖** តើនៅពេលដែលលោកឡើងជិះសាឡូង់ហ្នឹងថាចេញពីទន្លេចតុមុខមុខវាំងទៅ តើលោកនៅលើសាឡូង់ហ្នឹងយូរប៉ុនណាមុនពេលដែលសាឡូង់ហ្នឹងចេញដំណើរទៅខាងវៀតណាម រយៈពេលយូរទេមុននឹងទៅ?

**ឆ៖** បាទមុននឹងទៅហ្នឹងប្រហែលខ្ញុំឡើងទៅប្រហែលម៉ោងប្រាំបីព្រឹកបានដល់សាឡូង់ហ្នឹង ខ្ញុំឡើងទៅសាឡូង់ទៅបណ្តោយ។ ម៉ោងប្រាំបីព្រឹក ដល់ម៉ោងបួនភ្លឺដល់អ្នកលឿង។

**លោក ចូសេហ្វ អេនទ្រូ ប៊ិយលី៖**

សូមអរគុណច្រើនលោកដើមបណ្តឹងរដ្ឋប្បវេណី។

លោកប្រធាន ខ្ញុំអរគុណ ហើយខ្ញុំបញ្ចប់ការតាំងសំណួររបស់ខ្ញុំ បាទ។

**ប្រធានអង្គជំនុំ៖**

ទំនងជាចៅក្រមមានសំណួរ។ សូមអញ្ជើញលោកស្រីចៅក្រម ហ្វេនស៍។

**សួរដោយចៅក្រម ក្លូឌា ហ្វេនស៍៖**

**ស៖** ខ្ញុំមានសំណួរខ្លីពីរលោកដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីឲ្យលោកបំភ្លឺបន្ថែម។ លោកបានបញ្ជាក់ថាអំពីសៀវភៅកត់ត្រាគ្រួសារ ហើយលោកបាននិយាយថា គេកត់ត្រាពី<ជាតិពន្ធុ>នៅក្នុងសៀវភៅហ្នឹង។ តើអ្នកណាជាអ្នករក្សាទុកនូវសៀវភៅកត់ត្រាគ្រួសារហ្នឹង<? តើ>ប្រធានភូមិគេអ្នកទុក ឬក៏<មាន>គេ<ផ្សេងអ្នកទុក។>

[១៥:២២:០២]

**លោក ជឿង យ៉ាំង ចែត៖**

**ឆ៖** បញ្ជីគ្រួសារហ្នឹង ដូចជា"ឡាំងតាយ"ហ្នឹង ម៉ែខ្ញុំទុកទេ។ កាលណាដូចថា យើងទៅណាយើងជម្រាបគេហ្នឹង គេដូចថាៗទៅភូមិណាជម្រាបគេ យកក្រដាសហ្នឹងទៅជម្រាបគេ ដល់គេចង់សួរយើង ដល់ផ្ទះយើងៗយកអាសំបុត្រហ្នឹងទៅ ចេញឲ្យគេមើល បើអត់មានគេផាកអី គេៗនេះហើយ។ ខ្ញុំដឹងតែប៉ុណ្ណឹងទេ។

**ស៖** អ៊ីចឹងសៀវភៅកត់ត្រាគ្រួសារហ្នឹងគឺគ្រួសារមួយៗជាអ្នកទុក។ អ្នកណាជាចេញសៀវភៅហ្នឹងឲ្យ អ្នកណាជាអ្នកសរសេរសៀវភៅហ្នឹងកត់ត្រាសម្រាប់គ្រួសារមួយៗ?

**ឆ៖** កាលហ្នឹង ខ្ញុំនៅចងចាំអត់បានទេ កាលហ្នឹងម៉ែខ្ញុំជាមួយឪខ្ញុំទៅធ្វើទេ ខ្ញុំអត់ទាន់គ្រប់អាយុធ្វើផង ប៉ុន្តែចងចាំ ខ្ញុំដឹងតែ"ឡាំងតាយ"ជាមួយបញ្ជីគ្រួសាររបស់ម៉ែឪខ្ញុំហ្នឹងទេ មិនដឹងអ្នកណាធ្វើ។

**ស៖** <>ប៉ុន្តែដើម្បីឲ្យច្បាស់ មិនមែនថាសមាជិកគ្រួសារឬជាអ្នកសរសេរខ្លួនឯងទេ គឺអាជ្ញាធរគេអ្នកចេញសៀវភៅហ្នឹងឲ្យ អ៊ីចឹងមែនឬទេ លោកដើមបណ្ដឹង?

**ឆ៖** បាទ។

**ស៖** ក្នុងករណីដែលដឹង តើលោកបានដឹងទេ ថាតើមានៗការិយាល័យ<កណ្ដាលសម្រាប់ចុះបញ្ជី ឈ្មោះ និងជាតិពន្ធុ។ល។ នៅតាមថ្នាក់ភូមិ បន្ថែមលើក្រដាសស្នាមដែលគេចេញឲ្យគ្រួសារនីមួយៗ ដែលគេហៅថា សៀវភៅគ្រួសារ?> លោកដឹងទេ?

**ឆ៖** បាទ ខ្ញុំអត់ដឹងទេ កាលនោះខ្ញុំអត់ដឹងទេ។

**ស៖** សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីចៅក្រម។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវី

ការពារក្ដីដើម្បីមានឱកាសសួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ ហើយដំបូងនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្ដីលោក នួន ជា។ បាទ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

[១៥:២៤:៣៤]

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី តើលោកអាចអាន ឬក៏ចេះសរសេរភាសាអង់គ្លេសបានទេ?

**លោក ជឿង យ៉ាំង ចែត៖**

**ឆ៖** កាលហ្នឹងខ្ញុំនៅតូចណាស់បាន អត់បានទៅរៀនទេ។ អក្សរវៀតណាមក៏អត់បានរៀនចេះផង អក្សរខ្មែរក៏មិនបានរៀនផង។ គ្រាន់តែរៀនបានអត់ទាន់បានមួយខែផង ជម្លៀសដូរទៅហើយ បានរៀនអីចេះ។ ដល់សម័យនេះ ខ្ញុំក្រដល់មែនទែនក្រហើយ ផ្ទះមិនទាំងមាននៅផង។ ហើយមានអីទៅរៀនចេះអក្សរហ្នឹងគេ រកអង្ករស៊ីមិនបានផង។

**ស៖** ប្រហែលជាខ្ញុំសួរទៅលោកមិនច្បាស់លោកដើមបណ្ដឹងរដ្ឋប្បវេណី។ តើលោកចេះនិយាយចេះអាន ចេះសរសេរភាសាអង់គ្លេសទេ នៅក្នុងខែធ្នូ ឆ្នាំ២០១០?

**ឆ៖** ខ្ញុំអត់ចេះអក្សរទេ អត់ចេះកត់ទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំចង់បង្ហាញទៅដើមបណ្ដឹងរដ្ឋប្បវេណីនូវឯកសារភាសាអង់គ្លេស E3/5631 <មានចំណងជើងថា> "ព័ត៌មានបន្ថែមរបស់ ជឿង យ៉ាំង ចែត <> ថ្ងៃទី២១ ខែ១២ ឆ្នាំ២០១០ <ដោយមេធាវី លីម៉ា ង្វៀន, ឡាចឡង់ ស្កូលី និងគង់ លៀងដូ"។ ឯកសារនេះមិនមែនជាឯកសារសំណៅជាភាសាខ្មែរទេ តែជាសំណៅភាសាអង់គ្លេស។>

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំយល់ដើមបណ្ដឹងរដ្ឋប្បវេណី លោកមិនអាចចេះអាន ចេះសរសេរ ប៉ុន្តែនៅខាងក្រោម

ទំព័រនេះ ឯកសារនេះ លោកអាចឃើញស្នាមផ្តិតមេដៃ ហើយនៅខាងក្រោមហ្នឹងគេដាក់ឈ្មោះលោកថា ជឿង យ៉ាំង ចែត គឺថានៅថ្ងៃទី<២១> ខែធ្នូ ឆ្នាំ២០១០ តើលោកនៅចាំទេថា លោកបានផ្តិតមេដៃលើឯកសារភាសាអង់គ្លេស ជាឯកសារព័ត៌មានបន្ថែម<ចុះ> ថ្ងៃទី២១ ខែ១២ ឆ្នាំ២០១០?

**លោក ជឿង យ៉ាំង ចែត៖**

**ឆ៖** ដូច ខ្ញុំនិយាយអំមិញ ខ្ញុំរៀបរាប់ហើយ។ ខ្ញុំចេះតែឆ្នាំរបស់វៀតណាមទេ ខ្ញុំក៏និយាយអ៊ីចឹងដែរ។ បើខ្មែរក៏ខ្ញុំមិនចេះហៅយ៉ាងម៉េចដែរ ហើយខាងបារាំង ខ្ញុំនិយាយរឿងខាងយៀកណាមទេ។

**ប្រធានអង្គជំនុំ៖**

លោកដើមបណ្តឹងរដ្ឋប្បវេណីស្តាប់សំណួរឲ្យបាន សឹមឆ្លើយតប។ សំណួរហ្នឹង គឺលោកបានឃើញក្រដាសនុ៎ងហើយ ហើយមេធាវីសួរថាតើលោកចាំទេ ថាលោកបានផ្តិតមេដៃ ស្នាមដៃលើឯកសារដែលលោកកំពុងកាន់នុ៎ងដែរឬទេ? លោកចងចាំដែរឬទេកាលពីឆ្នាំ២០១០?

[១៥:២៨:១៣]

**លោក ជឿង យ៉ាំង ចែត៖**

**ឆ៖** ចងចាំ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើលោកចាំថាលោកបានផ្តិតមេដៃលើឯកសារនោះទេ ពីព្រោះលោកបានយល់ស្របលើខ្លឹមសារនៃឯកសារនោះ។ <និយាយម៉្យាងទៀត តើគេមានអានឯកសារហ្នឹងឲ្យលោក>ស្តាប់ជាភាសាខ្មែរ ឬជាភាសាវៀតណាម ស្តាប់លោកយល់ហើយ បានផ្តិតមេដៃទេពេលនោះ?

**ឆ៖** បាទ អានខ្មែរឲ្យខ្ញុំស្តាប់ទេ។

**ស៖** នៅពេលដែលគេអានចប់ឲ្យលោកស្តាប់ជាភាសាខ្មែរ បកប្រែពីភាសាអង់គ្លេសលើឯកសារនេះ តើ<លោកឆ្លើយប្រាប់គេថា “បាទ, ខ្ញុំយល់ស្រប” ហើយបន្ទាប់មក ដោយសារតែលោកយល់ស្របទើបលោក> ព្រមផ្តិតមេដៃលើឯកសារហ្នឹង។ តើបានធ្វើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ខ្ញុំព្រមហើយ។

[១៥:២៩:៤៣]

**ស៖** <ឥឡូវនេះ អ្វីដែលលោកមិនអាចដឹង ដោយសារតែលោកមិនចេះអាន ឬ>មិនយល់ភាសាអង់គ្លេសនោះ គឺថានៅទំព័រភាសាអង់គ្លេស ទំព័រទី១ មានសរសេរពីរដង គេកត់ត្រាពីរដង<អំពី>ហេតុ

ការណ៍ដែលបានកើតឡើងចំពោះលោកហ្នឹងគឺថានៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ហើយតាមកាឡង់យ៉េវៀតណាមហ្នឹង ថ្ងៃទី១៧ មីនា ឆ្នាំ១៩៧៥ <បើតាមប្រតិទិនបស្ចិមប្រទេស ហើយថា ហេតុការណ៍ដែលកើតឡើងចំពោះគ្រួសារលោកគឺនៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៥ តាមប្រតិទិនបស្ចិមប្រទេស។ ឯកសារនេះសរសេរថា> គេបង្ខំឲ្យលោក ឲ្យលោកចេញពីភូមិទៅភូមិដារ នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៥ ជាកាឡង់យ៉េបស្ចិមប្រទេស ហើយ<ព្រឹត្តិការណ៍ទាក់ទងនឹង>ក្រុមគ្រួសាររបស់លោក គឺកើតឡើងនៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៥ <នៅម៉ោង៩> ទៅតាមកាឡង់យ៉េបស្ចិមប្រទេសនោះដែរ។ តើលោក<ចាំនូវ>អ្វីដែលខ្ញុំអានតាមខ្លឹមសារនេះទេ?

**ឆ៖** បាទ ស្តាប់បាន ប៉ុន្តែខ្ញុំនិយាយថា ពេលកាឡង់យ៉េនេះ ខ្ញុំនិយាយថាកាលនេះ ម៉ែឪខ្ញុំហ្នឹងឡើង ដល់ពេលចេញពីកំពង់ឆ្នាំងហ្នឹង ឡើងទៅ -- ឡើងដារហ្នឹង វាចូលខែ៤ របស់វៀតណាមហ្នឹងផុតចូលឆ្នាំខ្មែរប្រាំពីរថ្ងៃ ចូលខែ៤ ខ្ញុំនិយាយហ្នឹងនិយាយតាមការពាក្យរបស់ខ្ញុំ ខ្ញុំដឹង។ ដល់ឡើងដល់ហ្នឹង នៅប្រហែលជាមួយខែជាងទេ បានម៉ែឪខ្ញុំយកទៅសម្លាប់ចោល។ ហ្នឹងខ្ញុំអត់ចេះខែ ចាំថ្ងៃអីទៀតទេ។

[១៥:៣១:៤៦]

**សៈ** អ៊ីចឹងជាចម្លើយ ជាសក្ខីកម្មរបស់លោក អ្វីដែលសរសេរលើឯកសារ E3/5631 <ចំពោះហេតុការណ៍ពីរ>ហ្នឹងមិនត្រឹមត្រូវទេ ពីព្រោះថាគេមិនបានបញ្ជូនលោកចេញពីភូមិនៅថ្ងៃទី១៧ ខែ៣ ឆ្នាំ១៩៧៥ ហើយក្រុមគ្រួសាររបស់លោកក៏មិនត្រូវបានគេសម្លាប់នៅថ្ងៃទី១៧ ខែ៣ ឆ្នាំ៧៥នោះទេ គឺឯកសារនេះកត់មិនត្រឹមត្រូវតាមអ្វីដែលលោកចាំទេ។ មានន័យអ៊ីចឹងឬទេ?

**ឆ៖** ឯកសារមុនខ្ញុំមិនដឹងទេ ប៉ុន្តែថាឆ្នាំ ខ្ញុំដឹងថាចាំថ្ងៃឆ្នាំ ដូចថាខ្ញុំកាលហ្នឹង ខ្ញុំវង្វេង ខ្ញុំថាវង្វេងកាលណាខ្ញុំចាំកន្លែងណា ខ្ញុំប្រាប់កន្លែងហ្នឹង បើខែថ្ងៃហ្នឹង ខ្ញុំចងចាំមិនបានទេ ខ្ញុំឡើងវង្វេងអស់ហើយព្រោះខ្ញុំដឹងឆ្នាំហ្នឹង ខែ តែមួយខែពីរខែ ខ្ញុំដឹង បើថានិយាយតែថ្ងៃអីហ្នឹង ខ្ញុំអត់ដឹងទេ។

**សៈ** អ៊ីចឹងខ្ញុំសួរសម្រួលឡើងវិញ លោកដើមបណ្តឹងរដ្ឋប្បវេណី។ ឯកសារនេះ បាទ ដែលយើងអាចយល់ថាមេធាវីរបស់លោកជាអ្នករៀបចំ ហើយលោកជាអ្នកផ្តិតមេដៃ ហើយលោកបានធ្វើសក្ខីកម្ម<>ថា ក្រុមគ្រួសាររបស់លោកត្រូវគេសម្លាប់នៅថ្ងៃទី១៧ ខែ មីនា<> ឆ្នាំ១៩៧៥ តើព័ត៌មានហ្នឹងពិត ឬមិនពិត?

**ឆ៖** ទេ ព័ត៌មានហ្នឹង អត់ ខ្ញុំអត់ដឹងពិត ឬមិនពិត។ ត្រង់ថាព័ត៌មានហ្នឹង ខ្ញុំមកតែ គេសួរខ្ញុំថា

ម៉ែឪខ្ញុំងាប់ខែណា ឆ្នាំណា ខ្ញុំប្រាប់ខែហ្នឹង ឆ្នាំហ្នឹង។ បើថាខ្ញុំនិយាយថ្ងៃ និយាយខែ តែខែរបស់ខ្ញុំទេ បើថាខែខ្មែរ ខែចិន ខ្ញុំពន្យល់បាន ខ្ញុំមិនចងចាំបានទេ ព្រោះខ្ញុំវាមានសរសៃខ្លះ។

[១៥:៣៤:០៥]

**ស៖** ខ្ញុំយល់លោកដើមបណ្តឹងរដ្ឋប្បវេណី ពីព្រោះថារឿងហ្នឹងវាកើតយូរណាស់មកហើយ ប៉ុន្តែនៅក្នុងកាលៈទេសៈធម្មតា គឺ<>មួយខែមុន ឬមួយខែក្រោយ<វាមិនខុសគ្នាប៉ុន្មានទេ។ ប៉ុន្តែឥឡូវនេះតាមមូលហេតុ>បច្ចេកទេស ហើយខ្ញុំមិនចង់រំខាន<លោកច្រើនពេក>ទេ ប៉ុន្តែខ្ញុំចង់ដឹងឲ្យច្បាស់ថាតើហេតុការណ៍ហ្នឹងវាកើតឡើងនៅ<ពេល>ណា<ឲ្យពិតប្រាកដ>។ អ៊ីចឹង <ឥឡូវនេះ> លោក<និយាយថា លោក>មិន<ដឹងកាលបរិច្ឆេទ>ដែលមានការអះអាងថាក្រុមគ្រួសាររបស់លោកត្រូវបានគេសម្លាប់ហ្នឹង<?>

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ សហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជំទាស់ទៅនឹងទម្រង់នៃសំណួរចុងក្រោយរបស់មេធាវីការពារក្តី។ ត្រឹមត្រូវដែលថាដើមបណ្តឹងរដ្ឋប្បវេណី គាត់បានបញ្ជាក់ថាគាត់ច្រឡំ អំពីកាលបរិច្ឆេទទាក់ទងទៅនឹងការដាក់ឈ្មោះខែ ប៉ុន្តែគាត់<នៅតែរក្សាថា> កាលបរិច្ឆេទ<ទាំងបញ្ជូន និងសម្លាប់ គឺនៅពេលចូលឆ្នាំខ្មែរ។ ដូច្នេះ បើសិនណាមេធាវីការពារក្តីចង់សួរគាត់ឲ្យបញ្ជាក់កាលបរិច្ឆេទហ្នឹងថា យ៉ាងម៉េចនោះ ខ្ញុំនឹងមិនជំទាស់ទេ។ ប៉ុន្តែ>ខ្ញុំជំទាស់ទៅនឹងការរៀបនូវពាក្យពេចន៍ ហើយនិងទម្រង់នៃសំណួរ <ដែលមេធាវីទើបតែបានរៀបចំ> ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំព្យាយាមរកវិធីសួរលោកប្រធាន ដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណីគាត់យល់ពីកាលបរិច្ឆេទហ្នឹងថាប្រាកដយ៉ាងដូចម្តេច។ <ខ្ញុំសូមទទួលស្គាល់អំពីអ្វីដែលលោកដើមបណ្តឹងរដ្ឋប្បវេណីបានជម្រាបនៅចំពោះមុខយើងរាល់គ្នា។> ប៉ុន្តែខ្ញុំមកតទល់នឹងគាត់អំពីឯកសារដែលគាត់ផ្តិតមេដៃចំពោះមុខមេធាវីរបស់គាត់ ហើយដែលបញ្ជាក់ពីរដងថា<ហេតុការណ៍ហ្នឹងកើតឡើង> នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៥។ បន្ទាប់មក ក្រោយមកគឺថាដើមបណ្តឹងរដ្ឋប្បវេណី<រូបនេះនិយាយថាខ្លួន>ច្រឡំអំពីកាលបរិច្ឆេទ ដោយគាត់បញ្ជាក់ថា <នៅពេល>ចូលឆ្នាំខ្មែរ <ឬចូលខែទីប្រាំ ក៏មិនបានផ្លាស់ប្តូរអង្គហេតុ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដែរ> គឺថា ថ្ងៃទី១៧ ខែមីនា <មាននៅក្នុងឯកសារនោះដដែល ជាភស្តុតាង ហើយយើងទាំងអស់គ្នាយល់ច្បាស់ណាស់ថា វាអាចប្រើប្រាស់ជាភស្តុតាងដោះបន្ទុក ឬដាក់បន្ទុក។>

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

<លោកប្រធាន ខ្ញុំសូមមានយោបល់មួយ។> ខ្ញុំគិតថាសំណួរនេះត្រូវបានឆ្លើយរួចមកហើយលោកប្រធាន។ មុនពេលឈប់សម្រាកហ្នឹង គាត់<ខ្លួនឯងហ្នឹង បាន និយាយថា<>ឯកសារ E3/5631 <ខុស។ ខ្ញុំគិតថា ភាគីទាំងឡាយក៏យល់ស្របផងដែរ។ លើសពីនេះ> ដើមបណ្តឹងរដ្ឋប្បវេណីក៏គាត់បានពន្យល់អំពីចំណុចតម្រុយរបស់គាត់ផ្ទាល់ ដើម្បីពន្យល់ថានៅពេលណា ដែលគ្រួសាររបស់គាត់ត្រូវបានសម្លាប់ គឺ<ក្រោយចូលឆ្នាំខ្មែរមួយខែ> ។ ដូច្នេះ ខ្ញុំគិតថាគាត់ត្រឡប់មកសួរសំណួរដែលបានសម្រេចរួចមកហើយមុនពេលឈប់សម្រាកនោះ។ ដូច្នេះ សូមមេធាវីការពារក្តីបន្តទៅទៀត ពីព្រោះថាសំណួរដែលលោកសួរនេះគឺថាជាសំណួរច្រំដែល។

[១៥:៣៧:៥៥]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន មិនមែនជាសំណួរច្រំដែលទេ ជាវិធីដែលខ្ញុំសួរ។ <ខ្ញុំចង់ដឹងថា> ឯកសារនេះជាឯកសារត្រឹមត្រូវ <ឬយ៉ាងណា> ដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាអ្នកចងក្រង <ឬក៏អ្វីដែលលោកដើមបណ្តឹង>និយាយក្នុងតុលាការហ្នឹង ត្រឹមត្រូវ <ឬយ៉ាងណា។ វាមិនអាចត្រូវទាំងពីរនោះទេ។>

**ប្រធានអង្គជំនុំ៖**

មិនអនុញ្ញាតឲ្យការជំទាស់ហើយ ម្តងហើយម្តងទៀតទេ។ ហើយមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិ អម្បាញ់មិញនេះយើងអនុគ្រោះ ពីព្រោះខាងសហព្រះរាជអាជ្ញារងអន្តរជាតិបានធ្វើការជំទាស់តវ៉ាហើយ លោកស្រីនៅស្ងៀម។ ដល់ពេលភាគីខាងណោះគេបញ្ជាក់លើ ជំទាស់លើសេចក្តីជំទាស់ លោកស្រីបែរជាងើបម្តងទៀត។ ឥឡូវនេះ លោកស្រីចាប់ផ្តើមងើបម្តងទៀត វប្បធម៌នៃការអនុវត្ត យើងមិនអនុញ្ញាតឲ្យភាគីធ្វើដូច្នេះទេ តាំងពីដើមទីមក។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៤០:០៦]

**ប្រធានអង្គជំនុំ៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បាទ អង្គជំនុំជម្រះផ្តល់ភារកិច្ចជូនទៅលោកស្រីចៅក្រម ហ្វេនស៍ ដើម្បីសម្រេចលើបញ្ហានេះឲ្យបានច្បាស់លាស់និងជ្រះស្រឡះតែម្តងនាពេលនេះ។ សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អង្គជំនុំជម្រះកត់សម្គាល់ថា ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ពីរដងស្របគ្នាយោងទៅរកហេតុការណ៍ដែលពាក់ព័ន្ធ កើតឡើងក្រោយចូលឆ្នាំខ្មែរ។ អង្គជំនុំជម្រះក៏កត់សម្គាល់ដែរថា នៅក្នុងចម្លើយ<ក្នុងឯកសារនោះ> វាមានភាពខុសគ្នាដែលថាលើកឡើង<ច្រើន>ដង <ដំបូងដោយមេធាវី> ដើមបណ្តឹងរដ្ឋប្បវេណី ហើយ<បន្ទាប់មកដោយ>មេធាវីការពារក្តីក៏តទល់គ្នា។ នៅទីបំផុតនៅអង្គជំនុំជម្រះ<នឹង>ពិចារណា<សម្រេចលើរឿងនេះ។ អង្គជំនុំជម្រះគិតថា វាមិនចាំបាច់សួរបន្តសួរលើបញ្ហានេះទៀតទេ។ អ៊ីចឹងទេ សូមមេធាវីបន្តសួរទៅមុខទៀត>

[១៥:៤១:១៧]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី តើលោកអាចរៀបរាប់ប្រាប់ខ្ញុំអំពី តាពាង។ តើ តាពាងគាត់ធ្វើអី គាត់មានតួនាទីអី? គាត់ជាអ្នកណា?

**ឆ៖** តាពាង ហ្នឹងខ្មែរក្រហម មេខ្មែរក្រហមនៅភូមិដារហ្នឹង នៅស្រុកកំពង់លែង។

**ស៖** លោកនិយាយថា <ជា>កម្មាភិបាលខ្មែរក្រហមនៅស្រុកហ្នឹង?<តើលោកមានន័យថាយ៉ាងម៉េច?>

**ឆ៖** គាត់មេទាហានខ្មែរក្រហមនៅស្រុកកំពង់លែងហ្នឹងតែម្តង។

**ស៖** តើលោកដឹងពីមុខងាររបស់គាត់ដោយរបៀបណា?

**ឆ៖** ប្រជាជនហៅគាត់តែមេខ្មែរក្រហមហ្នឹង។ ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** តើអ្នកណាដែល<> ប្រាប់លោកហ្នឹង <តើពួកគេជាអ្នកណា>?

[១៥:៤៣:០២]

**ឆ៖** ទាំងអស់ ទាំងខ្មែរ ទាំងយួននៅមួយភូមិដារហ្នឹងហៅទាំងអស់តែម្តង អត់មានអ្នកណាអត់ហៅ។

**ស៖** តើលោកដឹងថាគាត់ជាសមាជិកនៃបក្សកុម្មុយនីស្តកម្ពុជាទេ?

**ឆ៖** កាលហ្នឹងខ្ញុំអត់ដឹង។ ដឹងតែហៅគាត់ថាខ្មែរក្រហមហ្នឹង មេមួយខ្មែរក្រហមហ្នឹង។

**ស៖** តើត្រឹមត្រូវឬទេថា លោកទើបតែបាន<ស្គាល់ តាពាង> ប្រហែលជាមួយខែ ឬពីរខែតែប៉ុណ្ណឹងទេ? ខ្ញុំសូមសួរថ្មីឡើងវិញ។ តើរយៈពេលប៉ុនណាដែលលោកបានជួប តាពាង? តើលោកបានឃើញជួបគាត់នៅនឹងភូមិហ្នឹងរយៈពេលប៉ុនណា? អាចជាមួយអាទិត្យ ឬក៏មួយខែពីរខែ? តើរយៈពេលប៉ុនណាដែលលោកជួបគាត់ ឃើញគាត់ ហើយស្គាល់គាត់ថា តាពាង ហ្នឹង?

**ឆ៖** ស្គាល់គាត់តែអង្គាល់គាត់ជម្លៀសខ្ញុំទៅឡើងដារ ភ្នំកង្កែបហ្នឹង គាត់មកគាត់ថា រៀបឲ្យពួកខ្ញុំហ្នឹងធ្វើរោងនៅតាមហ្នឹង។ អាហ្នឹងគាត់ជាមេ គាត់ប្រាប់អ៊ីចឹង គាត់បានចូលទូកមកគាត់បាន អ្នកយៀកណាមនៅក្នុងទឹក បញ្ជានៅទូកហ្នឹងឲ្យចេញដំណើរទៅធ្វើត្រី ឲ្យយកមកធ្វើប្រហុកឲ្យគាត់ ធ្វើផ្សៀតឲ្យគាត់។

[១៥:៤៥:00]

**ស៖** អ៊ីចឹងគឺថា <គាត់>ពាក់ព័ន្ធនឹងការដែលគេជម្លៀសលោក ពាក់ព័ន្ធទៅនឹងការសម្លាប់សមាជិកក្រុមគ្រួសារ តើគាត់ហ្នឹងមានការពាក់ព័ន្ធទៅនឹងការឲ្យប្រជាជនវៀតណាមជិះទូកទៅអីដែរឬទេ? <តើលោកនិយាយអ៊ីចឹងឬ?>

**ឆ៖** គាត់ឲ្យប្រជាជនវៀតណាមនៅទឹកហ្នឹង ទៅជិះទូកមកចេញទន្លេ រកត្រី រកអីធ្វើប្រហុកឲ្យគាត់។ អ្នកណានៅលើគោក គាត់បញ្ជាដូចថា ធ្វើរោងនៅហ្នឹង ព្រលឹមឡើងវាយអាគាំងយកទៅ ជិតគល់ឈើ ដាំដំឡូងមី។

**ស៖** ខ្ញុំសូមចូលទៅសំណួរមុនរបស់ខ្ញុំ។ បើខ្ញុំយល់មិនច្រឡំទេ គាត់ចូលរួមពាក់ព័ន្ធនៅក្នុងការធ្វើសេចក្តីសម្រេចក្នុងការជម្លៀសគ្រួសាររបស់លោក ហើយក្រោយមកគឺថា គាត់ត្រូវបានទទួលរងការចោទប្រកាន់ថាបានសម្លាប់ក្រុមគ្រួសាររបស់លោក។ ហើយក្រោយមកទៀត គឺថាគាត់ចូលរួមពាក់ព័ន្ធនៅក្នុងការធ្វើសេចក្តីសម្រេចបញ្ជូនក្រុមគ្រួសារ <ហើយពាក់ព័ន្ធក្នុងការ>បញ្ជូនលោកឲ្យជិះទូកទៅវៀតណាម។ លោកកំពុងតែនិយាយថាអ៊ីចឹង?

**ឆ៖** ជិះទូកទៅវៀតណាម អត់កត់បញ្ចីទេ។ កាលនោះ គាត់ដូរទៅណាបាត់ហើយ អង្គាល់សម្លាប់ម៉ែឪខ្ញុំហ្នឹងគាត់នៅហ្នឹង។ អ៊ីចឹងដើម្បី ខ្ញុំយល់ថាគាត់នៅហ្នឹងប្រហែលមួយខែ ពីរខែតែប៉ុណ្ណឹង តែកាលដល់ខ្ញុំឃើចាប់ដល់ពេលហ្នឹង ខ្ញុំអត់ដឹងគាត់នៅណាទេ ព្រោះខ្ញុំពួននៅព្រៃ នៅទូកគេហ្នឹង អត់ប៉ានទៅណា ភូមិគេដឹងគាត់នៅហ្នឹង។

[១៥:៤៦:៥២]

**ស៖** ខ្ញុំចាប់ផ្តើមសួរម្តងទៀត។ ខ្ញុំដឹងថាពេលវេលានេះវាយូរណាស់មកហើយ។ តើលោកបានឃើញ តាពាង លើកដំបូងបំផុតនៅពេលណា លោកចាំទេ?

**ឆ៖** ចាំ ពេលគាត់ជូនខ្ញុំទៅឡើងលើគោកហ្នឹង គាត់មក គាត់ប្រាប់ឲ្យខ្ញុំធ្វើរោងនៅ ស្នាក់នៅនៅហ្នឹង។ ខ្ញុំចាំតែកន្លែងហ្នឹង។ គាត់មកទល់មុខគាត់ ហើយបានខ្ញុំចាំគាត់ត្រង់ហ្នឹងឯង។

**ស៖** លោកចាំពេលវេលាទេ ពេលហ្នឹងគឺពេលណាដែរ តើវាក្រោយថ្ងៃ១៧ ១៩៧៥ ក្រោយពេលបុណ្យចូលឆ្នាំខ្មែរ ឬក៏មុនបុណ្យចូលឆ្នាំខ្មែរ?

**ឆ៖** លោកឯងសួរខ្ញុំរឿងខែហ្នឹងវាយ៉ាប់និយាយហើយ ខ្ញុំនិយាយពីក្រោយចូលឆ្នាំខ្មែរ ខ្ញុំប្រាប់ថាក្រោយចូលឆ្នាំខ្មែរ ខ្ញុំបានឡើងលើគោកហ្នឹង។ ចូលឆ្នាំខ្មែរប្រាំពីរថ្ងៃនៅកំពង់ឆ្នាំង បានជម្លៀសខ្ញុំចូលដារហ្នឹង។

**ស៖** ដូច្នេះ គាត់ពាក់ព័ន្ធក្នុងការបញ្ជូនលោក និងក្រុមគ្រួសាររបស់លោក ឲ្យទៅនៅភូមិដារ អីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** ហើយនៅពេលគ្រួសាររបស់លោកទៅដល់ភូមិដារ តាពាង នៅទីនោះទៀតទេ?

**ឆ៖** គាត់ឲ្យខ្ញុំធ្វើរោងហ្នឹងនៅហ្នឹង បានដល់ ខ្ញុំទៅ ពុកម៉ែខ្ញុំទៅពលកម្មអស់ហើយ ហើយគាត់ទៅចូលទៅ ពួកវៀតណាមក្នុងទឹកហ្នឹងថាគាត់ទៅណាខ្ញុំមិនដឹងទេ ខ្ញុំនៅផ្ទះតែអត់ដឹង អត់ជួបគាត់។

**ស៖** លោកបាននិយាយថា គាត់<បានប្រាប់លោក> លោកទើបមានអាយុ១៣, ១៤ឆ្នាំទេ។ តើពេលហ្នឹងគាត់<ចង់>និយាយ<សំដៅថា>ឪពុកម្តាយលោក<ជាមនុស្សធំ>?

**ឆ៖** កាលហ្នឹងគាត់ប្រកាន់ មិនប្រកាន់ខ្ញុំមិនដឹងទេថា ខ្ញុំដូចជាប្រាប់មុន ថាម៉ែឪខ្ញុំហ្នឹងទៅជិតគល់ឈើដាំដំឡូងមីឲ្យគាត់ហ្នឹង ប៉ុន្តែមិនមែនគាត់ទៅ គាត់បញ្ជាទៅឲ្យមានក្រុមផ្សេងទៀតនាំភូមិហ្នឹងទៅ បានធ្វើ ឬមិនបានដូចថា ជា*(ឮមិនច្បាស់)* ពលកម្មលឲ្យខាងក្រុមហ្នឹង អត់បាន គេបាន ចងម៉ែឪខ្ញុំទៅសម្លាប់ចោល ខ្ញុំដឹង ដឹងតែប៉ុណ្ណឹងទេ។ រឿងប្រកាន់ប្រកោសអី ខ្ញុំដឹងអីទៀត។ កាលហ្នឹង ខ្ញុំបាត់ចងចាំច្រើនហើយ។

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី មិនអីទេ មួយៗ។ តាពាង គាត់នេះពាក់ព័ន្ធនៅក្នុងការបង្គាប់ឲ្យគ្រួសាររបស់លោក ក៏ដូចគ្រួសារដទៃទៀតឡើងទៅនៅភូមិដារ។ ហើយទៅដល់ភូមិដារ គាត់ក៏នៅទីនោះទៀត។ ហើយពេលទៅដល់ភូមិដារ គាត់នៅទីនោះដែរ <នៅតែចេញសេចក្តីបង្គាប់ដដែល> ។ តើ

ត្រឹមត្រូវដែរទេ?

**ឆ៖** ខ្ញុំនិយាយឲ្យលោកយល់បន្តិច។ ពីព្រោះខ្ញុំដឹងគាត់ថាជូនខ្ញុំនៅហ្នឹង ធ្វើផ្ទះហ្នឹង ធ្វើរោង នៅៗទៅ ហើយគាត់ទៅណាទៅណើ ខ្ញុំអត់ដឹងទេ។ បាទមុនហ្នឹង បើមើលមុខបានតែធ្វើរោងនៅទេ គាត់នាំទៅធ្វើរោងទេ។ បើថាពីណាឮឈ្មោះគាត់ញ៉រដៃញ៉រជើងអស់ហើយ ងាប់ខ្លួនបាត់ហើយ ក៏ឮឈ្មោះតាពាង។

**ស៖** <ត្រឡប់មក>និយាយអំពីតួនាទី មុខងាររបស់គាត់<វិញ> លោកហៅគាត់ថាជា<> កម្មាភិបាលខ្មែរក្រហម <ជាមេ តែ>វាជាពាក្យមួយទូទៅទៅហើយ។ ប៉ុន្តែការងារ មុខងារ តួនាទីពិតប្រាកដរបស់គាត់ធ្វើអ្វីដែរ? លោកដឹងទេ?

**ឆ៖** អត់ ខ្ញុំអត់ដឹង។

**ស៖** តើអាចថាគាត់ជាប្រធានភូមិៗ ភ្នំកង្កែប ឬក៏មិនមែនទេ? លោកដឹងទេ?

**ឆ៖** រឿងហ្នឹង ខ្ញុំអត់ដឹង។

[១៥:៥២:១៤]

**ស៖** អ៊ីចឹងនៅពេលដែលគាត់បង្គាប់ប្រាប់ទៅគ្រួសារលោកឲ្យសង់រោង សង់អីនុ៎ង <តើមានអ្វីកើតឡើងបន្ទាប់ទៀត?> លោកនៅចាំទេថានៅពេលគាត់បង្គាប់ឲ្យសង់រោង ហើយក្រោយមកជម្លៀសប្រជាជនរហូតដល់ពេលសម្លាប់ឪពុកម្ដាយរបស់លោក។ ចន្លោះពេលគាត់ប្រាប់ឲ្យសង់រោង ទៅដល់ពេលសម្លាប់ឪពុកម្ដាយលោកហ្នឹង មានរយៈពេលប៉ុន្មានពីគ្នា?

**ឆ៖** មួយខែជាង ប៉ុន្តែថ្ងៃធ្វើរោងហ្នឹងមានគាត់ប្រាប់តែមួយថ្ងៃហ្នឹងទេ ដល់ថ្ងៃក្រោយ អត់មានជួបមុខជួបអីគាត់ទៀតទេ។ មួយខែក្រោយមកបានម៉ែឪខ្ញុំ បានយកទៅវាយចោល ទាំងខ្ញុំផង។

**ស៖** ដូច្នេះអ្វីដែលលោកបាននិយាយខាងដើម ថាគាត់បានចូលរួមពាក់ព័ន្ធនៅក្នុងការបញ្ជូនលោក <ឡើងទូក> ទៅវៀតណាមនោះ គឺតាពាង អត់មានពាក់ព័ន្ធទេ អ៊ីចឹងមែនទេ?

**ឆ៖** អត់ទេ ខ្ញុំអត់ដឹងផង។ ពាក់ព័ន្ធក៏មិនដឹង អត់ពាក់ព័ន្ធខ្ញុំអត់ដឹង។

**ស៖** លោកដឹងទេថា ហេតុម៉េចបានជាគាត់រួមដំណើរជាមួយគ្រួសាររបស់លោក ក៏ដូចជាអ្នកភូមិនៅពេលចេញពីកន្លែងលោកហ្នឹងទៅ ហើយទៅភូមិដារហ្នឹង? ម៉េចបានគាត់ចូលរួម<ដំណើរ> ជាមួយ<លោក ឬក៏ម៉េចបានជាគាត់ទៅជាមួយលោក? តើលោកដឹងទេ?>

**ឆ៖** គាត់មេ ហើយកូនចៅគាត់ ប្រហែល១៥នាក់ បានជម្លៀសឡើងចោលទូកចោលអីនៅទឹក

នឹងទៅ។ ដើរទៅជាមួយគាត់ហ្នឹង គាត់ថាធ្វើរោងនៅតាមហ្នឹង មួយជួរហ្នឹង ធ្វើតាមហ្នឹង ប៉ុណ្ណឹងៗ។ បានធ្វើរោងរួច គាត់ដើរទៅណាទៅៗ ខ្ញុំអត់ដឹងទេ ទៅក្នុងមួយថ្ងៃនុំង។

**ស៖** តើលោកដឹង<អ្វីខ្លះ> ទេ ចន្លោះពេលពីពេលដែលគាត់បង្គាប់គ្រួសាររបស់លោក ក៏ដូចអ្នកដទៃឲ្យសង់រោង និងពេលដល់ពេលសម្លាប់<ក្រុមគ្រួសារ>របស់លោក<? ក្នុងចន្លោះពេលហ្នឹងមានអ្វីកើតឡើងដែរ?> ពីព្រោះថាមុននោះគឺមិនមានបញ្ហាអ្វីទេរវាងគ្រួសារលោកនិងគាត់ <ហើយក៏មិនមានបញ្ហាអ្វីនឹងគ្នាដែរនៅពេលជម្លៀសនោះ> រហូតដល់ភូមិដារក៏មិនមានបញ្ហាអ្វីដែរ<។> ប៉ុន្តែមួយខែក្រោយមកហាក់បីដូចជាមានបញ្ហាអ្វីមួយ។ តើលោកដឹងទេចន្លោះពេលហ្នឹងមានអ្វីកើតឡើងទៀត?

**ឆ៖** ដូចខ្ញុំជម្រាបអំមិញដែរ ធ្វើក្នុងមួយខែហ្នឹងមានកម្លាំងពលកម្ម បបរត្រកួនហ្នឹង ព្រលឹមឡើងវាយអាគាំងហើយ ស៊ីមួយចានបបរទៅ។ បានចេញដំណើរទៅធ្វើឲ្យគាត់។ ពេលថ្ងៃមួយចានត្រកួនទៀតហើយ ពេលល្ងាចមួយចានត្រកួនទៀតហើយ មានកម្លាំងឯណាធ្វើ អ៊ីចឹងដើម្បីគ្រុនក្ដៅ គ្រុនត្រជាក់។ អ៊ីចឹងដើម្បីនោះខុសតែមួយថ្ងៃទេ ថ្ងៃក្រោយកម្លាំងមកហើយ កម្លាំងមកចងយកទៅ ស្នើទៅទេ មិនសុំចង ស្នើទៅប្រជុំ។ តែប៉ុណ្ណឹងតើតែដឹងតែបាត់ខ្លួនហើយ។

**ស៖** ដូច្នេះសំណួររបស់ខ្ញុំគឺអ៊ីចេះ តើលោកមានដឹងថាមានអ្វីកើតឡើងទេ គិតពេលដែលគាត់ប្រាប់ឲ្យក្រុមគ្រួសាររបស់លោក និងអ្នកភូមិទៅសង់រោង ហើយនិង<មួយខែ>ក្រោយមកទៀត គឺដល់ពេលសម្លាប់ឪពុកម្ដាយរបស់គាត់។ <តើមានរឿងអីមួយខែមុនហ្នឹង? សូមឆ្លើយ> បើលោកដឹង<។>

**ឆ៖** ខ្ញុំអត់ដឹងទេ កាលចន្លោះហ្នឹងខ្ញុំអត់ដឹងទេ ប៉ុន្តែខ្ញុំដឹងថាម៉ែឪខ្ញុំហ្នឹងវាគ្រុនរងាញាក់អ៊ីចឹងធ្វើការមិនរួច កាប់គល់ឈើ លីមិនរួច បានព្រលឹមឡើងយកទៅវាយចោលទៅ។ តែប៉ុណ្ណឹង ខ្ញុំដឹងតែប៉ុណ្ណឹង។

[១៥:៥៧:២១]

**ស៖** តើឪពុករបស់លោកធ្វើអ្វីដែរ មាន<មុខរបរអ្វីដែរ>មុនពេលគេចាប់ខ្លួនគាត់?

**ឆ៖** តួនាទីទៅហ្នឹងខ្ញុំប្រាប់ហើយ ថាចិតគល់ឈើៗហ្នឹង ឲ្យជម្រះដីហ្នឹង ដាំដំឡូងមី។ ដាំដំឡូងមី ប៉ុន្តែគាត់ឈឺយកទៅវាយចោលហ្នឹង។

**ស៖** ប្រហែលជាសំណួរខ្ញុំមិនច្បាស់ទេមើលទៅ។ <ខ្ញុំចង់មានន័យអ៊ីចេះ> តើគាត់<មានមុខរបរអ្វីដែរ នៅ>មុនពេលខ្មែរក្រហមឡើងកាន់កាប់អំណាច? <គាត់មានតួនាទីអ្វីដែរ?> តើគាត់អាច

ថាជាទាហានរបស់របបលន់ នល់ ដែរទេ? ឬក៏គាត់ជាទាហានវៀតណាមខាងត្បូង ឬក៏មិនធ្វើអ្វីទេ? បាទ អ៊ីចឹងសួរម្តងទៀត ថាតើគាត់មានតួនាទី ឬធ្វើអ្វីដែរមុនពេលគេជម្លៀសគាត់ចេញនោះ?

**ឆ៖** បាទ ម៉ែឪ ខ្ញុំកើតលើស្រុកឫស្សីដង្គួចហ្នឹងហើយបានមកកើតលើក្បាល ចេញក្បាលខ្ញុំចេញឫស្សីដង្គួចហ្នឹងដែរ ប៉ុន្តែគាត់អត់មានធ្វើស្អីទៅខុសស្អីទេ បានគាត់រកស្រែ រកត្រី ដាក់មងវាយសន្ទូចតែប៉ុណ្ណឹងទេ។

**ស៖** អ៊ីចឹងឪពុកម្តាយរបស់លោក ក៏ដូចសមាជិកដទៃទៀត គឺមិនមានពាក់ព័ន្ធក្នុងការវាយប្រយុទ្ធប្រឆាំងទៅនឹងខ្មែរក្រហមអីទេ <មុនពួកគេឡើងកាន់អំណាច, អ៊ីចឹងឬ?> គឺឪពុករបស់លោកគ្មានធ្វើអីក្រៅពីនេសាទត្រីហ្នឹងទេ អ៊ីចឹងអី?

**ឆ៖** បាទៗ។

**ស៖** ហើយនៅពេលដែល តាពាង គាត់ដឹងថាគ្រួសាររបស់លោក សមាជិកគ្រួសាររបស់លោក <ថា>ជាអ្នកណាទៅ ហើយគឺថាក្រោយមកមួយខែក្រោយពេលជម្លៀស តាពាង ក៏សម្រេចចាប់ខ្លួនគ្រួសាររបស់លោក។ <> ប៉ុន្តែតើលោកមានឮ បានឮពីអ្នកដទៃថាមូលហេតុអីបានជាគេចាប់ខ្លួន <គ្រួសារ>យកទៅសម្លាប់ចោលហ្នឹងទេ?

**ឆ៖** ខ្ញុំជម្រាបហើយជម្រាបទៀត ដូចខ្ញុំនិយាយអំមិញដែរ ថាឡើងដល់ហ្នឹង ឲ្យឪខ្ញុំ ម៉ែខ្ញុំ បងខ្ញុំហ្នឹង ទៅចិតគល់ឈើហ្នឹង ដាំដំឡូងមី។ ដាំដំឡូងមីហ្នឹង គាត់ឈឺ គាត់ចិតមិនរួចទេ គាត់លើមិនរួចទេ។ អ៊ីចឹង ដើម្បីថាមួយថ្ងៃហ្នឹង ថ្ងៃក្រោយយក ស្នើហើយ ស្នើទៅហើយ។

**ស៖** ខ្ញុំត្រឡប់ទៅនិយាយពី តាពាង ហើយនិងការដែលគាត់ស្គាល់គ្រួសាររបស់លោក។ លោកអាចជម្រាបជូនតុលាការបានទេ តាពាង នេះ តាពាង ស្គាល់គ្រួសាររបស់លោកអស់ពេលប៉ុន្មានដែរ? <ប៉ុន្មានសប្តាហ៍?> ប៉ុន្មានខែ? ប៉ុន្មានឆ្នាំ មុនពេលគេយកគ្រួសាររបស់លោក<ជម្លៀសទៅភូមិដារ> ?

**ឆ៖** បាទ អាហ្នឹងខ្ញុំអត់យល់ ខ្ញុំអត់ដឹងទេ ដឹងស្គាល់ មិនស្គាល់ ខ្ញុំអត់ដឹងទេ។ កាលហ្នឹង ខ្ញុំអត់ដឹងទេ។

[១៦:០១:០៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។

សវនាការនៅថ្ងៃនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការ

សម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី០៨ ខែធ្នូ ឆ្នាំ២០១៥ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងបន្តធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សី ជឿង យ៉ាំង ចែត បញ្ចប់ -- អ៊ំ! ស្ដាប់ដើមបណ្ដឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត បញ្ចប់ ហើយនិងចាប់ផ្ដើមស្ដាប់សាក្សីដែលមានរហស្សនាម 2-TCW-945 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាដែលបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណ ជឿង យ៉ាំង ចែត ដំណើរសវនាការស្ដាប់សក្ខីកម្មរបស់លោក ក្នុងឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីនៅមិនទាន់ចប់នៅឡើយទេ។ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូន លោក យ៉ាំង ចែត ត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅ និងសូមអញ្ជើញគាត់ត្រឡប់មកចូលរួមសវនាការនៅថ្ងៃស្អែក ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីរនាក់ត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក៕

សម្រាកចុះ!

*(សវនាការផ្អាកនៅម៉ោង ១៦:០២ នាទី)*